ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Apr-2016, 10:23
CMS/CFO: Sann Rada

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៨នាទី**

**សវនាការលើកទី៣៩០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោក ឡៅ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ប៊ុន ឡឹងចូយ (2-TCW-838) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ សាក្សី៖ លោក ម៉ុន ឡើងចូយ** (2-TCW-838)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៣

សួរដោយលោក ខេល លីសាក់ ផ្ដើមពី ........ ទំព័រ ៦

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី ........ ទំព័រ ៥០

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្តីកម្មសាក្សីដែលមានរហស្សនាម 2-TCW-838 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ មន្ទីរសន្តិសុខភ្នំក្រោល។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ មានរហស្សនាម 2-TCW-838។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនង ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែករួចហើយ កាលពីព្រឹកមិញនេះ ហើយសាក្សីរូបនេះមានមេធាវីប្រឹក្សា គឺលោកស្រីមេធាវី សុក សុជាតា។

សូមអរគុណលោកប្រធាន។

[០៩:១០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួន ក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាង ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យខុសភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺខ្នង ឈឺចង្កេះរ៉ាំរ៉ៃ អង្គុយយូរ - - មិនអាចអង្គុយយូរបាន វិលមុខពេលបំលាស់ទី និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកនួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:១១:២១]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅទៀតនេះ អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី និងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សី និងមេធាវីប្រឹក្សា ចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ខ្ញុំបាទ ឈ្មោះ ប៊ុន ឡឹងចូយ បាទ។

**ស៖** អរគុណ លោក ប៊ុន ឡឹងចូយ។ តើមាន លោកមានឈ្មោះមួយផ្សេងទៀត ឬក៏ឈ្មោះហៅក្រៅដែរឬទេ?

**ឆ៖** បាទ ឈ្មោះដើមខ្ញុំ ចាន់ ប៊ុនលឹត បាទ។

**ស៖** បាទ អរគុណ ហើយលោកប្រើប្រាស់ផ្លូវការនៅក្នុងអត្តសញ្ញាណប័ណ្ណ ពលរដ្ឋខ្មែរសព្វថ្ងៃហ្នឹង ឈ្មោះណាមួយ? ឈ្មោះ ប៊ុន ឡឹងចូយ ឬក៏ឈ្មោះ ចាន់ ប៊ុនលឹត?

**ឆ៖** បាទ ឈ្មោះ ប៊ុន ឡឹងចូយ បាទ។

**ស៖** បាទ អរគុណ លោក ប៊ុន ឡឹងចូយ។ ហើយតើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំកើត ថ្ងៃ២២ ខែ៣ ១៩៥៣ បាទ។

**ស៖** លោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** កំណើតខ្ញុំបាទ នៅភូមិកោះម្បើល ឃុំជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរីបាទ។

**ស៖** បាទ អរគុណ។ ហើយចុះទីលំនៅបច្ចុប្បន្ននេះ តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិដោះក្រមុំ ឃុំសុខដុម ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ហើយឥឡូវគេហៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី បាទ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបរអីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទ អតីតអនុប្រធានមន្ទីរព័ត៌មាន ខ្ញុំចូលនិវត្តន៍ហើយបាទ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** បាទ ឪពុកខ្ញុំបាទឈ្មោះ ចាន់ ប៊ុនឡឹង។ ម្តាយឈ្មោះ ដាំ ថន។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សាវ៉ាវ៉ាន់ លី មានកូនប្រាំនាក់ បាទ។

[០៩:១៦:១៥]

**ស៖** បាទ អរគុណ។ ហើយលោក ប៊ុន ឡឹងចូយ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** ហើយលោកស្បថនៅចំពោះមុខអ្នកតាដំបងដែក ដែលនៅពីកើតសាលសវនាការហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆ៖** បាទ ខ្ញុំបានស្បថរួចហើយ បាទ។

**ស៖** បាទ អរគុណ លោក ឡឹង ប៊ុនចូយ។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោក ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជម្រះសួរចំពោះលោក លើកលែងតែសំណួរណា ឬក៏ការសុំឲ្យលោកធ្វើអត្ថាធិប្បាយណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់ នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

[០៩:១៨:០៧]

ហើយលោក ប៊ុន ឡឹងចូយ ណ៎ះ! តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេរយៈពេលកន្លងមក? ហើយបើសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

**ឆ៖** បាទ មានបានសម្ភាសនៅផ្ទះខ្ញុំបាទពីរដង បាទ។ ហើយនៅសណ្ឋាគារ អឿន សក្ខណា ខេត្តមណ្ឌលគិរីមួយដងដែរ បាទ។

**ស៖** ហើយនៅៗមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល បានអានន្ធូវកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយកាលពីពេលមុន ដែលលោកអះអាងអំមិញថា ចំនួនពីរដងនៅផ្ទះរបស់លោក ហើយនិងនៅៗទីក្រុង នៅទីក្រុងមណ្ឌលគិរីហ្នឹងចំនួនមួយលើកនោះ ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ បានមើលដែរ ហើយយប់មិញ ហើយនិងពេលយប់ម្សិលមិញ បាទ។

**ស៖** បាទ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវសមស្រប ស៊ីសង្វាក់គ្នា ទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានមើលមានកន្លែងខ្លះ គាត់និយាយរលូនតាមចម្លើយ មានកន្លែងខ្លះ គាត់សរសេរបានចុង ភ្លេចដើម សរសេរដើមភ្លេចចុង។ អ៊ីចឹងជួនកាល វាពិបាកខ្ញុំតាមដានណាស់។

[០៩:២០:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ឡឹងចូយ នៅពេលនេះលោកបានទទួលជំនួយប្រឹក្សាមេធាវីដែលអង្គជំនុំជម្រះផ្ដល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើររបស់លោកហើយ។ ហើយលោកមេធាវីប្រឹក្សា លោកស្រី -- គឺលោកស្រី -- មេធាវីប្រឹក្សាគឺលោកស្រី សុខ សុជាតា ណ៎។ ក្នុងការសួរដេញដោលសាក្សីរូបនេះអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។

មុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គនៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញបាទ!

**លោក ឌេល លីសាក់៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរលោកស្រីចៅក្រម មេធាវីការពារក្ដី ហើយនិងភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ឌេល លីសាក់ ខ្ញុំនឹងសួរសំណួរលោកមួយចំនួននៅថ្ងៃនេះ។ ខ្ញុំចាប់ផ្ដើមជាមួយសំណួរមួយចំនួនអំពីប្រវត្តិផ្ទាល់ខ្លួនរបស់លោក។ លោកបានបញ្ជាក់នៅក្នុងបទសម្ភាសន៍របស់លោកថាលោកបាន<>ចូលព្រៃ ហើយចូលបដិវត្តន៍ ចលនាតស៊ូក្នុងឆ្នាំ១៩៦៦ ឬ១៩៦៨ តើនៅពេលណាមួយ លោកបានក្លាយទៅជាសមាជិកបក្សដែរឬទេ? បើបែបនោះមែន តើលោកក្លាយទៅជាបក្ខជននៅថ្ងៃ ខែ ឆ្នាំណាដែរ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ ខ្ញុំបានចូលព្រៃឆ្នាំ១៩៦៨ ក្នុងខែឧសភា ទេ។ ហើយបាន -- អត់បានចូលបក្សទេ បើនិយាយចំ ខ្ញុំអត់មាន -- អត់ទាន់មានសិទ្ធិចូលបក្ខជននឹងគេទេ ជាយុវជនធម្មតា បាទ។

**ស៖** តើលោកក្លាយជាបក្ខជនដែរឬទេ <> ប៉ុន្មានឆ្នាំក្រោយពីចូលព្រៃហ្នឹង បាទ?

**ឆ៖** រហូតដល់ឆ្នាំ៧៥ ក៏ខ្ញុំអត់បានចូលបក្សដែរបាទ។

[០៩:២៣:០៥]

**ស៖** ចុះក្រោយពីឆ្នាំ១៩៧៥ តើលោកធ្លាប់<ក្លាយ>ជាសមាជិក<បក្សទេ មិនថា>ជាសមាជិកត្រៀម សមាជិកនៅក្នុងសម្ព័ន្ធយុវកក ឬក៏ជាបក្ខជនក្នុងស្ថាប័នណាមួយដែរឬទេ?

**ឆ៖** ក្នុងឆ្នាំ៧៥ ខ្ញុំបានចូលយុវកក ជាប្រធានក្រុមផង។ មានប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំឆ្នាំទេ នៅពេលដែលលោកជាសមាជិកយុវកក ហើយជាប្រធានក្រុមនោះ?

**ឆ៖** ខ្ញុំចាំថ្ងៃខែហ្នឹង ដូចជាមិនចាំ ប៉ុនចាំតែឆ្នាំទេ ឆ្នាំ៧៥ ខ្ញុំគេជ្រើសរើសឲ្យចូលជាសម្ព័ន្ធយុវកកហ្នឹង ហើយឲ្យខ្ញុំធ្វើមេក្រុម គ្នាមានចំនួនប្រាំ ប្រាំមួយនាក់ហ្នឹង បាទ។

**ស៖** ឥឡូវនេះយើងនឹងចាប់ផ្ដើមពីចំណុចដែលថា សូមឲ្យលោកនិយាយដោយសង្ខេប ហើយរៀបរាប់អំពីតួនាទី មុខតំណែងនានា <និងទីតាំងដែលលោកឈរជើងក្នុងរបបខ្មែរក្រហម>ពីឆ្នាំ១៩៧៥ ខែមេសា រហូតដល់ខែមករា ឆ្នាំ១៩៧៩ តើលោកមានតំណែងអ្វីខ្លះ ហើយឈរជើង ឬក៏ធ្វើការនៅកន្លែងណាខ្លះ សូមលោករៀបរាប់ដោយសង្ខេបជូនអង្គសវនាការ?

**ឆ៖** បាទខ្ញុំ -- កាលឆ្នាំ៧៥ ខ្ញុំជាអង្គរក្សរបស់ កាស៊ី។ គាត់ជាលេខាស្រុកកែវសីមា មកដល់ឆ្នាំ៧៧ ខែ០២។ ថ្ងៃទី២២ ខែ០២ គេបានចាប់គាត់ឲ្យមកនូវសន្តិសុខនៅកោះញែកនេះ គឺក-១៦ ហើយ

01225726


ខ្ញុំក៏គេទៅតាមយកមករស់នៅជាមួយគាត់បានប្រហែលជាងមួយខែ បានគេយកខ្ញុំទៅនៅបំបែកពីគាត់ ដើម្បីគេយកគាត់ទៅសម្លាប់។ អ៊ីចឹងទៅខ្ញុំ បើគិតទៅកាលដែលរស់នៅជាមួយគាត់រយៈពេលប្រហែល មិនពេញពីរឆ្នាំផង ពីរឆ្នាំជាងហ្នឹង។ បើនិយាយពីមុនតាំងពីការតស៊ូពីដំបូងមក នៅជាមួយគាត់យូរដែរ នៅតាំងពី៧៣នោះ ជាអង្គរក្សរបស់គាត់នោះ។ បើដល់៧៥ហ្នឹង ខ្ញុំបានចូលយុវកកហ្នឹង គឺនៅក្នុងឆ្នាំ ៧៥ទេ។ បាទ សូមអស់។

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺបញ្ហាមួយចំនួន នៅក្នុងបទសម្ភាសន៍<របស់លោកជាមួយ>ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5178, ខ្មែរ ERN 00197860, អង់គ្លេស 00274099, បារាំង ERN 00485184 នេះជាអ្វីដែលលោកបាននិយាយ<>នៅក្នុងបទសម្ភាសន៍នោះជូនទៅអ្នកស៊ើបអង្កេត។ សូមដកស្រង់៖ "មុនចូលទៅកោះញែក ខ្ញុំជាអនុលេខា<>នៅក្នុងមន្ទីរស្រុកកែវសីមា ពីព្រោះឪពុកមាខ្ញុំ កាស៊ី ជាលេខាស្រុក។ ខ្ញុំធ្វើជានីរសាររបស់គាត់ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៥។ ខ្ញុំធ្វើការជាអនុលេខាពីឆ្នាំ១៩៧៥ ដល់១៩៧៧។" ចប់សេចក្ដីដកស្រង់។ ខ្ញុំសូមផ្អាកត្រឹមហ្នឹងសិន ហើយសូមឲ្យលោកបំភ្លឺជូនតុលាការ។

តើខ្លឹមសារនេះរំឭកការចង់ចាំរបស់លោកអំពីមុខតំណែងរបស់លោកហើយនឹងពេលវេលាដែរឬទេលោកសាក្សី? និយាយដោយជាក់លាក់ តើត្រូវដែរឬទេ ដែលលោកធ្លាប់ធ្វើជាអនុលេខារបស់<> មន្ទីរស្រុកកែវសីមា ពីឆ្នាំ១៩៧៥ ដល់១៩៧៧?

[០៩:២៨:១២]

**ឆ៖** បាទ ខ្ញុំសូមបដិសេធ។ ធម្មតាអង្គរក្សមិនអាចធ្វើជាអនុលេខាគេបានទេ។ ការដែលឆ្លើយខ្ញុំមិនបានឆ្លើយចំត្រង់ហ្នឹងទេ ខ្ញុំអត់មានជាអនុលេខាទេ ខ្ញុំជាអង្គរក្ស។ សូមអស់។

**ស៖** លោកក៏បានប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលដែលគេសម្ភាសលោក គឺឯកសារយោងគឺ E3/5636, ខ្មែរ 00042465, អង់គ្លេស 00711200, បារាំង 00727123។ នេះជាអ្វីដែលលោកបានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីមុខតំណែងរបស់ខ្លួន។ "នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំគឺជាអង្គរក្សរបស់លេខាស្រុកកែវសីមា។ នៅក្នុងឆ្នាំ១៩៧៤-៧៥ ខ្ញុំជាប្រធានមន្ទីរស្រុកកែវសីមា។ ក្នុងឆ្នាំ១៩៧៦-៧៧ ខ្ញុំត្រូវបានជម្លៀសជាមួយ<ពូ>កាស៊ី។" លោកសាក្សី ហេតុអ្វីក៏ថាមជ្ឈមណ្ឌលឯកសារ<>កម្ពុជា ហើយនិង<>សហចៅក្រមស៊ើបអង្កេត <បង្ហាញ>ថាលោក<> មានតំណែងខ្ពស់ជាងអ្វីដែលជាអង្គរក្ស <នៅពេលក្រោយមក គឺ>ពីឆ្នាំ<១៩៧៥> ហើយនិងឆ្នាំ<១៩៧៦>។ <កិច្ច-

សម្ភាសន៍របស់លោកទាំងពីរ បានបញ្ជាក់ពីចំណុចនេះ លោកសាក្សី។ តើលោកអាច>ពន្យល់<បានទេ?>

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា អ្នកសរសេរប្រហែលជាច្រឡំ អនុលេខាមិនមែនជាការតូចទេ សូមលោកវិភាគសិន។ ធម្មតាខ្ញុំជាយុវជន ក្រោយពីធ្វើអង្គរក្សគេ បានឲ្យត្រឹមតែប្រធានមន្ទីរស្រុកហ្នឹង អនុប្រធានមន្ទីរស្រុកហ្នឹង។ អនុប្រធានមន្ទីរស្រុក បើប្រៀបធៀបជាឋានៈវិញ ប្រហែលជាប្រធានការិយាល័យរបស់ខេត្តទេ វាមិនបានស្មើនឹងប្រធានមន្ទីរខេត្តផង។ អ៊ីចឹងទេ អស់លោកត្រូវវិភាគមើលថា តើចម្លើយរបស់ខ្ញុំហ្នឹងត្រឹមត្រូវដែរឬក៏អត់? វាមិនអាចទេដែលខ្ញុំជាយុទ្ធជន ហើយបានឡើងទៅដល់អនុលេខាធិការនោះវិញវាមិនអាចទេ វាគ្មានតែម្ដង គ្មានក្រឹត្យក្រមដែលគេឲ្យធ្វើអ៊ីចឹងផង។ ប៉ុន្តែខ្ញុំឆ្លើយថា ខ្ញុំជាអង្គរក្សត្រឹម៧៥ បន្ទាប់មកខ្ញុំបានធ្វើជាអនុប្រធានមន្ទីរ កាន់ក្រុមយុវកកហ្នឹងចំនួនមួយក្រុម។ ប៉ុន្តែប្រធានរបស់ខ្ញុំហ្នឹង គឺលោក គាត់ជាជនជាតិទេ គាត់ឈ្មោះ បងប៉ុប គាត់ជាប្រធាន ខ្ញុំជាអនុគាត់ ក្នុងមន្ទីររបស់ កាស៊ី ហ្នឹង។ កាស៊ី គាត់លេខាស្រុកបាទ។ ហើយខ្ញុំមុនដំបូងជាអង្គរក្សរបស់គាត់។ បន្ទាប់មកបានគាត់ឡើងមកឲ្យធ្វើអនុប្រធានមន្ទីរ។ វាមិនអាចឡើងទៅដល់អនុលេខាទេ បាទ។ អ៊ីចឹងសូមអស់លោកវិភាគ។ សូមអស់។

[០៩:៣២:០៣]

**ស៖** បាទ ខ្ញុំនឹងព្យាយាមយល់តទៅទៀត។ <ដូច្នេះតួនាទីរបស់លោក មិនមែន>ជាអនុលេខា<ទេ>។ <នៅពេលណាមួយនោះ លោកបានធ្វើជា>អនុប្រធាន<>មន្ទីរស្រុក តើអ្វីដែលខ្ញុំយល់នេះត្រូវតាមការពិត ដែលលោកបានធ្វើកាលនោះ ដែរឬទេ?

**ឆ៖** បាទ បើតាមខ្ញុំដឹង ខ្ញុំធ្វើកាលហ្នឹងវាជាឋានៈតូចតាចទេ ជាឋានៈមន្ទីរៗស្រុក វាមិនបានស្មើនឹងឋានៈគណៈស្រុកទេ។ អ៊ីចឹងទេ បើលោកម៉ែទៅលើថា ខ្ញុំស្មើនឹងអនុលេខានោះ វាស្មើហ្នឹងចៅហ្វាយស្រុក ឬក៏អនុស្រុកហ្នឹងមិនអាចទេ។ បាទ អាហ្នឹងខ្ញុំមិនឯកភាពទេ បាទ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ លោកបានបញ្ជាក់ថា មិនមែនជាអនុលេខាទេ ប៉ុន្តែនៅពេលណាមួយលោកបានក្លាយទៅជាអនុប្រធាននៅមន្ទីរមួយ។ តើលោកនៅចាំដែរឬទេ ពេលដែលលោកក្លាយទៅជាអនុប្រធានមន្ទីរមួយនោះ នៅខែឆ្នាំណា?

**ឆ៖** បាទ ខ្ញុំចាំប្រហែលជាក្នុងខែ៦ ឆ្នាំ៧៥ បាទ ក្រោយពីរំដោះភ្នំពេញហើយ បាទ។

**ស៖** តើអ្នកណាជា<អនុ>លេខាស្រុកស្ថិតនៅក្រោមបញ្ជារបស់ឪពុកមាលោកឈ្មោះ កាស៊ី

នោះ<>?

**ឆ៖** បាទ សូមជម្រាបដែរថា គាត់ជាលេខាបាទ មិនមែនគាត់ជា -- នេះទេ។ កាស៊ី ជាលេខា អនុលេខារបស់គាត់ ឈ្មោះ ចិន្តា បាទ។ បន្ទាប់មកទៀត សមាជិករបស់គាត់ ទី១ ឈ្មោះ កុង, ទី២ ឈ្មោះ ខាំ, គឺស្រុក ក្នុងស្រុកគាត់។ ហើយបន្ទាប់មកទៀត នៅមានខាងទាហាន នៅមានខាងពេទ្យដែលជាគណៈស្រុកហ្នឹងចំនួនប្រាំនាក់។ គិតតាំងពីលេខា អនុលេខា រហូតដល់សមាជិក។ សរុបទៅប្រាំនាក់។

**ស៖** សូមអរគុណដែលលោកសាក្សីបានបំភ្លឺជូនតុលាការ។ ហើយលោកក៏បានបញ្ជាក់ផងដែរថា នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ <លោក និង>ឪពុកមារបស់លោកត្រូវបានប្តូរទីតាំងអំពីមន្ទីរស្រុកកែវសីមា ចេញទៅកន្លែងផ្សេង។ តើលោកអាចជម្រាបតុលាការបានទេ ហេតុអ្វីបានគេប្តូរតំណែង ឬក៏ទីតាំង<ពូ>របស់<លោក> ហើយដំបូងគេបញ្ជូន<លោក>ទៅកន្លែងណា <នៅ>ពេលដែលលោកចាកចេញពី<>ស្រុកកែវសីមានោះ?

[០៩:៣៥:៣៦]

**ឆ៖** បាទ ខ្ញុំ នៅចាំខ្លះ។ ពេលដែលគាត់ គេដកយកមក ដកនៅតំបន់១០៥ ខេត្តមណ្ឌលគិរីនេះ គឺមុន ក្នុងខែ០២ ឆ្នាំ៧៧។ មូលហេតុដែលនេះ ក៏ដោយសារគាត់ បានគាំទ្រសមាជិកស្រុករបស់គាត់ហ្នឹងមានខុសសីលធម៌បាទ ដែលគាត់គាំទ្រ គាត់អត់រាយការណ៍ទៅថ្នាក់លើ ។បានដឹង ក៏ត្រូវគាត់មានទោស គេទម្លាក់គាត់ហើយ គេយកគាត់មកតំបន់ទុកតាមដាន ដើម្បីធ្វើការពិនិត្យ និងរង់ចាំដល់ថ្ងៃគាត់ គេចាប់គាត់យកទៅសម្លាប់ បាទ។ ហើយពេលហ្នឹងដែរ ខ្ញុំបាទ ក៏ក្រោយមក ប្រហែលជាពីរថ្ងៃគេមកយកខ្ញុំទៅ យកមកដាក់ការដ្ឋានជាមួយគ្នា ដំបូងហ្នឹងធ្វើការជាមួយគ្នាទេ បានប្រហែលជាមួយខែ គេបានជម្លៀសខ្ញុំទៅ បំបែកខ្ញុំចេញពីគាត់ដើម្បីគេយកគាត់ទៅសម្លាប់។ ខ្ញុំក៏បានទៅនៅរយ៉។ រយ៉ហ្នឹងជាការដ្ឋានមួយ កន្លែងបង្កបង្កើនផលជាសេដ្ឋកិច្ចមួយដ៏ធំដែរ។ ក្នុងហ្នឹងមានប្រធានមន្ទីរពាណិជ្ជកម្ម ឈ្មោះ ចាន់ថន ជាប្រធានដែលគ្រប់គ្រងនៅទីនោះ។ ប្រធានមន្ទីរមួយទៀតគឺ ប្រធានពាណិជ្ជកម្មហ្នឹង បើយើងនិយាយមានប្រធានមន្ទីរមួយទៀត គឺជាប្រធានមន្ទីរការដ្ឋានហ្នឹង ឈ្មោះ ខាំ ភឹង ដែលគាត់គ្រប់គ្រងផ្ទាល់ ហើយគាត់អ្នកដឹកនាំធ្វើស្រែធ្វើអីហ្នឹង និងគ្រប់គ្រងដែលអ្នកនៅការដ្ឋានហ្នឹងបាទ។ សូមអស់។

**ស៖** សូមអរគុណ។ លោកសាក្សីនៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថា នៅពេលដែលគេដកលោកចេញពីកែវសីមា គឺ<ដំបូងឡើយគេ>បញ្ជូន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកមកមន្ទីរ ក-១៦ ហើយក្រោយមកទៀត គេបញ្ជូនលោកទៅការដ្ឋានមួយឈ្មោះថា ការដ្ឋានរយ៉។ តើវាពិតជាអ៊ីចឹងមែនទេ ដែលថានៅពេលដែលគេបញ្ជូនលោកមកពីស្រុកកែវសីមា<ហ្នឹង គេ>បញ្ជូនមកមន្ទីរ ក-១៦ <សិន ឬក៏គេ>បញ្ជូន<លោក>មកការដ្ឋានរយ៉<តែម្ដង?>

**ឆ៖** បាទជាការពិត បាទ។

**ស៖** ចុះលោកនៅមន្ទីរក-១៦ អស់រយៈពេលប៉ុន្មានដែរ មុននឹងគេបញ្ជូនលោកមកកាន់ការដ្ឋានរយ៉នេះ?

**ឆ៖** បាទ តាមខ្ញុំចាំយូរដែរ ប្រហែលជាពីរបីខែដែរបាទ ព្រោះតាំងពីថ្ងៃ២២ គេដឹកពីកែវសីមាមកនៅក-១៦ ហើយគេឱ្យខ្ញុំអារឈើ ធ្វើសាលាបានមួយគ្រឿងទៀតបាទ ទម្រាំខ្ញុំបានទៅនៅរយ៉នោះ គឺពីខែពីរ រហូតដល់ខែមិថុនានេះ នៅពេលដែលស្ទូងស្រូវបាទ។ អ៊ីចឹងវាពីរបីខែដែរ។

**ស៖** ហើយលោកបានឆ្លើយថាលោកនៅជាមួយ<ពូ>របស់លោកឈ្មោះ កាស៊ី ប្រហែលជាមួយខែ។ តើពេលហ្នឹង លោកនៅជាមួយ<គាត់>នៅមន្ទីរក-១៦ ឬក៏<ក្រោយមកទៀត>នៅឯការដ្ឋានរយ៉?

[០៩:៤០:០០]

**ឆ៖** បាទ នៅក-១៦ ព្រោះគាត់គេយកមកត្រឹមហ្នឹងទេ។ ខ្ញុំទេដែលទៅដល់រយ៉នោះ។

**ស៖** ចុះលោកមានវត្តមាននៅមន្ទីរក-១៦ ដែរ<ទេ> នៅពេលឪពុកមារបស់លោក កាស៊ី ហ្នឹង ត្រូវបានគេចាប់ខ្លួន?

**ឆ៖** បាទ នៅជាមួយគ្នាហ្នឹង រយៈ -- មួយរយៈពេល។ ដល់គេជិតចាប់គាត់ហ្នឹង បានគេជម្លៀសខ្ញុំចេញ បាទ។

**ស៖** ធ្វើម៉េចបានជាលោកអាចដឹងបានថា ឪពុកមារបស់លោក កាស៊ី នេះ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** បាទ ដោយសារការចៃដន្យដែរ។ មានបងប្អូនជីដូនមួយ គាត់បានទៅគាស់កូនចេក គេឱ្យគាត់ទៅគាស់កូនចេក គាត់បានឃើញគេចាប់គាត់តែម្ដង ហើយគាត់ត្រឡប់ទៅកន្លែងអង្គភាពរយ៉វិញ គាត់បានរាយការណ៍ប្រាប់ខ្ញុំថា គេចាប់ហើយ បាទ។ តែប៉ុណ្ណឹង។

**ស៖** តើលោកអាចបញ្ជាក់ចំណុចមួយជូនតុលាការបានទេថា តើខ្លួនលោកផ្ទាល់នេះ មានត្រូវបានគេចោទថា ប្រព្រឹត្តកំហុសអ្វីដែរទេ បានជាគេដកលោកចេញមកពី<តួនាទីនៅ>ស្រុកកែវសីមា ឬក៏ដោយសារតែ ការចោទប្រកាន់ទៅលើឪពុកមារបស់លោកទេ?

[០៩:៤១:៥៧]

**ឆ៖** បាទ តាមខ្ញុំដឹង ប្រហែលជាអត់មានកំហុសអីទេខ្ញុំ គឺគេមិនទុកចិត្តដោយសារតែឪពុកមាខ្ញុំហ្នឹងឯង បាទ។

**ស៖** ដូច្នេះ លោកបញ្ជាក់ថា នៅពេលដែលគេដកលោកចេញពីមន្ទីរស្រុកកែវសីមា គេបញ្ជូនលោកមកមន្ទីរក-១៦ ពីខែកុម្ភៈ ទៅមិថុនា ឆ្នាំ៧៧។ ហើយក្រោយមក នៅខែមិថុនា ឆ្នាំ១៩៧៧ <> គឺបញ្ជូនមកការដ្ឋានរយ៉។ តើលោកអាច<>ជម្រាបជូនតុលាការបានទេ ទីតាំងការដ្ឋានរយ៉ហ្នឹង ស្ថិតនៅត្រង់កន្លែងណាដែរ?

**ឆ៖** បាទ ទីតាំងរយ៉ហ្នឹង គឺនៅស្រុកកោះញែក បាទ ក្រោមក-១៧ ភ្នំក្រោល ចម្ងាយប្រហែលជា៨គីឡូ តែប៉ុណ្ណឹង បាទ។

**ស៖** លោកថា វាស្ថិតនៅក្រោមមន្ទីរក-១៧។ <តើ>មន្ទីរក-១៧ ហ្នឹងជាមន្ទីរអ្វីដែរ?

**ឆ៖** បាទ មន្ទីរក-១៧ហ្នឹង ជាមន្ទីរតំបន់១០៥ហ្នឹងតែម្តង បាទ។ បន្ទាប់ពី១៧ បាន ១៦។ ១៦ នេះ ជាមន្ទីរអនុប្រធានរបស់តំបន់ទេ បាទ។

**ស៖** តើ<មន្ទីរ> ក-១៦ និង ក-១៧ នៅជិតគ្នាដែរទេ? តើមន្ទីរ ក-១៦ និងមន្ទីរ ក-១៧ វានៅចម្ងាយពីគ្នាប្រហែលជាប៉ុន្មានម៉ែត្រដែរ?

**ឆ៖** បើតាមពីមុន ហើយនិងឥឡូវហ្នឹងវាឆ្ងាយដែរ។ បើគិតទៅ វាប្រហែលជា២គីឡូជាង។

**ស៖** សូមបញ្ជាក់ម្តងទៀតលោក។ ខ្ញុំសួរនៅក្នុងឆ្នាំ១៩៧៧ តើមន្ទីរទាំងពីរស្ថិតនៅចម្ងាយ២គីឡូម៉ែត្រពីគ្នា នៅក្នុងឆ្នាំ១៩៧៧ ឬក៏ពេលហ្នឹង មន្ទីរពីរហ្នឹង វានៅជាប់គ្នាតែម្តង?

[០៩:៤៥:00]

**ឆ៖** បាទ អត់ទេ មន្ទីរហ្នឹងដាច់ឆ្ងាយតាំងពីយូរហើយ មិនមែននឹងនេះទេ តាំងពីចាប់ផ្តើមធ្វើកសាងនៅកោះញែក ឆ្នាំ៧៥ហ្នឹង គេបានលើកមន្ទីរក-១៧ ទៅដាក់លើភ្នំក្រោលដែលបច្ចុប្បន្ននេះ បាទ ហើយ ក-១៦ គេដាក់កន្លែងចាស់ដដែលនៅជាប់អូរច្បារនេះបាទ។ ហើយត្រូវឆ្លងទឹកអូរច្បារនៅខែភ្លៀង អត់មាននេះទេ អត់មានផ្លូវឡានឆ្លងបានទេ បាទ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះ។ សំណួរចុងក្រោយអំពីទីតាំងនៃការដ្ឋានរយ៉។ តើទីតាំង<នោះនៅកន្លែងណា បើធៀបទៅនឹង>មន្ទីរ ក-១៧? <នៅទិសណា>? ហើយតើមន្ទីរ ក-១៧ នេះ មានចម្ងាយប៉ុន្មានពីការដ្ឋានរយ៉?

**ឆ៖** បាទ បើតាមខ្ញុំស្មានប្រហែលជាយើងថា៨គីឡូ ក៏ប្រហែលជាមិនដល់ដែរ ខ្ទង់៦ ទៅ៧ ឬ

ក៏៨គីឡូហ្នឹង ព្រោះមិនអាចវាស់ស្ទង់បានទេ ព្រោះការធ្វើដំណើរជំនាន់ហ្នឹងធ្វើដំណើរថ្មើរជើងបាទ ប៉ុន្តែបើសិនជាផ្លូវមានផ្លូវត្រឹមត្រូវ ប្រហែលជាមិនដល់ប៉ុណ្ណឹងទេ។

**ស៖** តើលោកស្ថិតនៅក្រោមការចាប់ខ្លួន ឬក៏អត់ទេនៅពេលដែលលោកនៅការដ្ឋានរយ៉? ខ្ញុំមិនច្បាស់ត្រង់ចំណុចនេះតាមរយៈចម្លើយលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ តើលោកស្ថិតនៅក្រោមការចាប់ខ្លួន ឬក៏អត់ទេនៅពេលដែលគេយកលោកមកដាក់នៅការដ្ឋានរយ៉នោះ?

[០៩:៤៧:៤០]

**ឆ៖** បាទ អត់ទេ។ ខ្ញុំគ្រាន់តែជាគេឃុំខ្លួនជា -- គ្រាន់តែការពារ ហើយនិងឃុំខ្លួនតែប៉ុណ្ណឹងទេ មិនបានចាប់ មិនបានចង ឬក៏មិនបានវៃខ្នោះទេ បាទ។

**ស៖** សូមអរគុណ។ លោកថាលោកទៅនៅឯការដ្ឋានរយ៉នៅខែមិថុនា ១៩៧៧ តើលោកនៅ<>ការដ្ឋាននេះអស់រយៈពេលប៉ុន្មាន?

**ឆ៖** បើតាមខ្ញុំសង្កេតមើល ព្រោះវាភ្លេចដែរ ពីខែ៦ ដល់ខែ១២។ ខែ១២ ខ្ញុំបាត់ឈឺហើយបាទ។ ខ្ញុំធ្វើការនៅហ្នឹងបានត្រឹមខែ១២ បានធ្វើការជាមួយគេ ដល់នេះខ្ញុំចាប់ឈឺៗខ្ញុំមកសម្រាកពេទ្យ។ នៅក្នុងខែ១២ ដាច់ខែ១២ហ្នឹង ចូលខែ០១ មកដល់ខែ០២ អ៊ីចឹងវារយៈពេលប្រាំពីរ ប្រាំបីខែប៉ុណ្ណឹងបាទ។ ខ្ញុំបានមកដេកពេទ្យហ្នឹង ខែ០២ហើយបាទ។

**ស៖** ចុះលោកសម្រាកនៅមន្ទីរពេទ្យអស់រយៈពេលប៉ុន្មាន?

**ឆ៖** ខ្ញុំគិតថាខ្ញុំសម្រាកពេទ្យយូររហូតដល់ថ្ងៃរំដោះតែម្តង បាទ។ ដល់ថ្ងៃរំដោះហើយ ០៧មកវាហ្នឹងហើយ អត់បានដើររួចទេ ព្រោះខ្ញុំឈឺខ្វិនជើងម្ខាងបាទ ប៉ុន្តែខ្ញុំចេញពីពេទ្យហ្នឹងទៅសម្រាកនៅផ្ទះរយៈពេលមួយខែក៏រំដោះតែម្តង។ តាមការពិតមិនដល់មួយខែផងហ្នឹង។

[០៩:៥០:០៣]

**ស៖** សូមអរគុណដែលបានបញ្ជាក់អំពីពេលវេលានូវអ្វីដែលបានកើតចំពោះលោកនៅក្នុងរបបនោះ។ ម្តងនោះលោកនិយាយអំពីការចាប់ខ្លួនឪពុកមារបស់លោក កាស៊ី។ តើឪពុកមារបស់លោកហ្នឹងមានប្រពន្ធកូនទេ? ហើយបើគាត់មានប្រពន្ធ មានកូនហ្នឹង តើមានអ្វីកើតឡើងទៅដល់ប្រពន្ធកូនរបស់គាត់នៅពេលគេចាប់ខ្លួនគាត់?

**ឆ៖** បាទ គាត់មានប្រពន្ធកូនតើ! ប្រពន្ធគាត់ពេលដែលគេចាប់គាត់ហ្នឹង គេបានធ្វើមីទ្ទិងហើយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេប្រកាសហើយគេបញ្ជូនមកសហករណ៍វិញ បាទ។ កាលនោះគាត់មានកូនមើល៍ ប្រាំមួយ ប្រាំពីរនាក់ ហើយកូនចៅគាត់ឥឡូវស្លាប់តែមួយទេ ក្រៅពីហ្នឹងនៅរស់ទាំងអស់។ ស្លាប់ដោយសារជំងឺទេ។ សូមអស់។

**ស៖** ឥឡូវនេះខ្ញុំសុំចូលទៅសួរលោកអំពីប្រព្រឹត្តការណ៍ដែលបានកើតឡើងនៅក្នុងតំបន់របស់លោកក្នុងសម័យខ្មែរក្រហម។ ដំបូងខ្ញុំសុំសួរថាតើមានអ្វីកើតឡើងនៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅមណ្ឌលគិរី? តើលោកដឹងទេថាមានអ្វីកើតឡើងទៅដល់អតីតទាហានរបប លន់ នល់ និងអតីតមន្ត្រីរដ្ឋកាលរបប លន់ នល់?

**ឆ៖** បាទ ខ្ញុំពិបាកឆ្លើយដែរ ពីព្រោះខេត្តមណ្ឌលគិរីមិនមែនរំដោះនៅថ្ងៃ១៧ មេសា ទេ បាទ។ ព្រោះរំដោះតាំងពីឆ្នាំ៧០មក បើខ្ញុំលើកទៅវាប៉ះពាល់ហ្នឹងរបបពីរ។ បាទ អ៊ីចឹងមិនអាចនិយាយបានទេ។ ពីព្រោះរបបក្រៅពីជំនាន់ហ្នឹង ក្នុងរបបវាយលន់ នល់ផង។ នៅសម្តេចឪមិនទាន់រត់ទៅប៉េកាំងផង អ៊ីចឹងទេ ខ្ញុំមិនអាចនិយាយបាន។ ពីព្រោះរបបកាលសង្គ្រាមហ្នឹង មិនមែនទើបវាយភ្លាម បែកភ្លាមឯណា។ អ៊ីចឹងរយៈពេលតាំងពី៦៨ មកដល់៧០ មកដល់៧៥ វាយូរណាស់។ របបនេះខ្ញុំធ្លាប់ឆ្លងកាត់ច្រើនណាស់ ប៉ុន្តែខ្ញុំដូចជាពិបាកក្នុងការឆ្លើយបាទ។

[០៩:៥២:០៣]

**ស៖** អ៊ីចឹងខ្ញុំសុំសួរលោកតាមរបៀបផ្សេង។ គិតពីឆ្នាំ១៩៧៥ មកដល់៧៦ តើប្រជាជនប្រភេទណាដែលត្រូវប្រឈមមុខទៅនឹងការចាប់ខ្លួន <ឬសម្លាប់>នៅក្នុងតំបន់១០៥ នេះ?

**ឆ៖** បាទ សូមបញ្ជាក់ដែលថា ប្រជាជនដែលប្រឈមមុខជាមួយនឹងចាប់ខ្លួនមានច្រើនដែរ មានច្រើនប្រភេទ។ ទី១ ប្រជាជនថ្មីបាទ ប្រជាជនមកពីភ្នំពេញយើងហ្នឹង ឬមកពីខេត្តដទៃបាទ ដែលគេជម្លៀសទៅមណ្ឌលគិរីហ្នឹង គេមិនអាចទុកចិត្តបាន។ ទី២ គឺចំពោះរបបទាហានចាស់ដែលសំណល់ពីមុន ដែលគាត់មានការកែប្រែ ដូចថាវាសម ហើយធុញទ្រាន់ហ្នឹងរបបខ្មែរក្រហមហ្នឹង ហើយគាត់អាចមានការប្រឆាំងខ្លះ និងទី៣ចំពោះប្រជាជនដូចថាធុញទ្រាន់នឹងការហូបរួម ស៊ីរួមបាទ ហើយដកហូតសម្ភារៈឯកជន ជាទ្រព្យសម្បត្តិ ជាវត្ថុ ឬក៏ជាអ្វីៗផ្សេងៗដែរជាកម្មសិទ្ធិរបស់បុគ្គលគេ។ អ៊ីចឹងអ្នកដែលគេសម្លាប់ហ្នឹង គឺប្រឈមមុខចំពោះជនទាំងហ្នឹងបាទ។ បន្ទាប់ទៀតក្រោយមកគឺ មានការចោទប្រកាន់ខ្មែរ-ស, កា.ហ្សេ.បេ, សេ.អ៊ី.អា ចូលយួន និងសំខាន់បំផុត គឺចូលយួនហ្នឹងតែម្តង។ តែចូលយួនហើយងាប់ហើយ។ អាហ្នឹងវ៉ៃទាំងខ្សែតែម្តង។ បាទ សូមអស់ហើយ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងត្រឡប់មកសួរចំណុចខ្លះៗដែលលោកទើបឆ្លើយអម្បាញ់មិញនេះ។ ខ្ញុំសូមអានចម្លើយរបស់លោក ឆ្លើយជូនមន្ត្រីស៊ើបអង្កេត<នៃការិយាល័យសហចៅក្រមស៊ើបអង្កេត> គឺឯកសារ E3/5178, ខ្មែរ 00197857, អង់គ្លេស 00274095, បារាំង 00485180 ដល់ 81។ នេះគឺជាអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ "ជនរងគ្រោះ (ត្រង់នេះលោកយោងទៅឆ្នាំដំបូងៗ) ជនរងគ្រោះដែលត្រូវបានគេសម្លាប់ដោយសារតែ<ការចោទប្រកាន់ថា>មានសាច់ញាតិជាប់ជាមួយនឹងស្តេច, លន់ នល់ ជាទាហាន ប៉ូលិស រាជការ អតីតមេឃុំ <ឬ>ជំទប់ ហើយក្រោយមកទៀត <ក្នុងឆ្នាំ១៩៧៧> ជនរងគ្រោះត្រូវបានគេចោទថា ចូលដៃជាមួយវៀតណាម"។ បញ្ចប់ការដកស្រង់។ ទាក់ទងទៅនឹងអតីតទាហាន និងមន្ត្រីរដ្ឋការ របបលន់នល់ តើអ្នកទាំងអស់នោះត្រូវប្រឈមមុខទៅនឹងការចាប់ខ្លួន ចោទប្រកាន់ ឬក៏តែអ្នកណាដែលមានបុណ្យស័ក្តិធំដុំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៥៧:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយសារថា ខ្ញុំជឿថា ចម្លើយជាក់លាក់នោះ គឺទាក់ទងទៅនឹងបរិបទមួយដែលត្រូវបានចោទជាសំណួរឡើងនេះ គឺថា ពេល<>គេបានសួរ<គាត់>អំពីស្ថិតិប្រជាជន គេបានសួរអំពីតួនាទីរបស់គាត់ជាអនុប្រធានមន្ទីរព័ត៌មានខេត្តមណ្ឌលគិរីក្នុងឆ្នាំ<៩៣> ដែលក្នុងបរិបទនោះ គឺថា មើលទៅហាក់ដូចជាគាត់ឆ្លើយទាក់ទងទៅនឹងតួនាទីរបស់គាត់<នេះទេ> គឺមិនពាក់ព័ន្ធ<ទាល់តែសោះទៅនឹងក្រុមគោលដៅដែលបានបញ្ជាក់នោះ>ទេ។ ការដែលយកតែឃ្លាមួយអម្បាញ់មិញយកមកសួរបែបនេះ<ខ្ញុំជឿ>ថាមិនត្រឹមត្រូវទេ។ ខ្ញុំសូមជំទាស់ គួរតែយកអត្ថបទនេះទាំងមូល ចំណុចនេះអានទាំងស្រុងតែម្តង។ ដោយសារថា<ពេលនេះយើងដឹងថាគាត់មានតួនាទីអ្វីហើយ>នៅពេលនោះ <វាហាក់ដូចជាមានការសង្ស័យខ្លាំងណាស់ថា នៅពេលនោះ> គាត់មិន<ស្ថិតនៅក្នុងតួនាទីណាមួយក្នុងការ>ដឹងអំពីការចោទប្រកាន់បែបនេះទេ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបសង្ខេបទេ។ សាក្សីគាត់ធ្វើការឲ្យមារបស់គាត់ជាលេខាស្រុក

<នៅក្នុងមន្ទីរស្រុក>។ ដូច្នេះ គាត់ពិតណាស់ថា មានការដឹងអំពីបញ្ហាទាំងអស់នេះ។ <>បើសិនមេធាវីការពារក្តីចង់ដឹង លម្អិតនោះ គឺថាដល់វេនគាត់សួរ ពេលនោះគាត់សួរលម្អិតបន្ថែមពីលើចំណុចខ្ញុំសួរទៅទៀតទៅបាន ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់របស់មេធាវី វ៉ិចទ័រ កូប៉េ លើសំណួរចំពោះសំណួរនេះ។ ហើយសាក្សីបើចាំនូវសំណួរ ចូរឆ្លើយតបទៅនឹងសំណួរ ចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី <ដើម្បីជាជំនួយដល់>លោក សំណួររបស់ខ្ញុំមុនហ្នឹង សួរថាតើទាហានលន់ នល់ទាំងអស់ និងមន្ត្រីរដ្ឋការលន់ នល់ទាំងអស់ ប្រឈមមុខទៅនឹងការចាប់ខ្លួន ឬក៏តែមន្ត្រី ឬក៏ទាហានណាដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់ទេ?

[០៩:៥៩:៤៨]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ត្រង់នេះខ្ញុំសូមឆ្លើយខ្លះៗដែរ ព្រោះកន្លងមក ដែលខ្ញុំធ្លាប់បានដឹង បានឃើញ ជាពិសេសគឺទាហានចាស់ហ្នឹង មានអ្នកខ្លះក៏រស់ទាល់បច្ចុប្បន្នដែរ មិនមែនថាអាក្រក់ទាំងអស់ទេ បាទ។ ប៉ុន្តែចំពោះទាហានចាស់មួយចំនួនដែល ដូចថា មានចរិតអីចេះអីចុះទៅ មានគេតាមដានក្រោយមក គេអាចរើសទៅយកវៃចោលអីចឹងដែរ។ ប៉ុន្តែពីមុនមក តាំងពីឆ្នាំ៧០ហ្នឹង ពេលរំដោះមណ្ឌលគិរីហ្នឹងទាហាននៅទាំងអស់ មានសម្លាប់មេៗខ្លះមួយចំនួន តែកូនទាហាននៅៗច្រើន។ ដល់ក្រោយមក មានការលត់ដំនៅក្នុងសហករណ៍ហ្នឹង។ ជួនកាល ធម្មតា គាត់ជាទាហានចាស់អីចឹង គាត់ជាអតីតទាហាន គេតែងតែតាមឃ្លាំមើលគាត់ និងតាមដានគាត់នូវអត្តចរិត និងអាដែងនេះគាត់។ ចុងក្រោយមក ក៏គាត់ល្អទៅ ក៏ល្អរហូតទៅ គាត់នៅរស់ទាល់បច្ចុប្បន្ន។ ជួនកាលទៅ គេយកគាត់ទៅវៃចោល ដោយសារគាត់ដូចថា ទ្រាំមិនបានជាមួយនឹងរបបហ្នឹង បាទ។ ហើយចំណែកក្រោយមកនេះ ក៏ដូចតែគ្នា ព្រោះគាត់ជាប្រជាជនទូទៅទៅហើយ លែងមានអតីតទាហានចាស់ទៀតហើយមកដល់៧៥នេះ។ គឺអីចឹង គេគ្រាន់តែថា គេនឹកទៅតាមវណ្ណៈ។ ហើយក្នុងពេលហ្នឹង បើតាមខ្ញុំយល់ថា ៧៥នេះ មិនសូវសម្លាប់ទាហានចាស់ ហើយនិងប្រជាជនប៉ុន្មានទេ បាទ។ ភាគច្រើន គឺសម្លាប់កម្មាភិបាល ហើយនិងយុទ្ធជន ទាហាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្លួនឯងតែម្តង។ បានជាខ្ញុំលើកនេះ គឺការពិតដែលធ្លាប់ឃើញមក ដូចជាក្រុមពួកខ្ញុំដែលនៅកែវសីមា ដែលគេយកទៅវ៉ៃចោលនេះ មិនមែនប្រជាជនផងហ្នឹង សុទ្ធតែបុគ្គលិកក្នុងស្រុក ក្នុងមន្ទីរ បាទ។ អ៊ីចឹង សូមអស់ប៉ុណ្ណឹង។

[១០:០២:00]

**ស៖** ខ្ញុំសូមអានសម្រង់ដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/5636, ខ្មែរ ERN 00042469, អង់គ្លេស 00711205, បារាំង 00727126។ នេះ គឺជាអ្វីដែលលោកបានឆ្លើយជូន មជ្ឈមណ្ឌលឯកសារកម្ពុជា អំពីឆ្នាំដំបូងៗនៃរបបខ្មែរក្រហម។ សូមដកស្រង់៖ “មិនមែនប្រជាជនធម្មតា នោះទេ ដែលត្រូវបានគេសម្លាប់នោះ។ ហើយមានតែអតីតទាហានលន់នល់ ដែលមានបុណ្យស័ក្តិធំៗ តាំងពីស័ក្តិ៤ ស័ក្តិ៥ ទើបយកទៅសម្លាប់ចោល។ ឯអ្នកកូនទាហានឋានៈតូចតាច ត្រូវគេប្រមូលយក ទៅរៀនសូត្រ លត់ដំ។ ហើយបើសិនណាជាពួកគេតវ៉ា គឺថានឹងត្រូវគេបញ្ជូនខ្លួនចេញទៅបាត់”។ <ហើយបន្តទៅចម្លើយបន្ទាប់ទៀត> “ពីឆ្នាំ១៩៧៥ ដល់៧៧ មានតែខ្សែមន្ត្រីដែលមានបុណ្យស័ក្តិខ្ពស់ ខ្ពស់ទេ ទើបយកទៅសម្លាប់ចោល។ ចំណែកប្រជាជនវិញ គឺថាតិចតួចណាស់ ដែលត្រូវបានគេយក សម្លាប់ចោល។” បញ្ចប់ការដកស្រង់។

តើត្រឹមត្រូវដែរទេលោកសាក្សី ថាអ្នកដែលប្រឈមមុខទៅនឹងការចាប់ខ្លួនសម្លាប់នៅឆ្នាំដំបូងៗ គឺមានតែអ្នកទាំងឡាយណាដែលមានបុណ្យស័ក្តិធំខ្ពស់ក្នុងរបបលន់ នល់ទេ តើអ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** តើលោកនៅចាំដែរឬទេ អ្នកណាជាអ្នកណែនាំថា តើឋានន្តរសក្តិ ឬក៏អ្នកមានបណ្តាស័ក្តិ ឋានៈណាដែលត្រូវជាគោលដៅនៃការបោសសម្អាតជាដើមហ្នឹង?

**ឆ៖** បាទ បើតាមដឹង បើសិនជាមានមេមួយធំអ៊ីចឹង កូនចៅរបស់គាត់ហ្នឹង ប្រហែលជាចាប់ តាំងពី និយាយរួម ចាប់តាំងពីមេក្រុម មេកងឡើង ក៏មិនអាចនៅបានដែរ ព្រោះគេវាយៗតាមខ្សែ។ បើ ខ្សែមួយនាក់ក្បត់ កូនចៅរបស់គាត់ ឬក៏ខ្សែរបស់គាត់ហ្នឹង ក៏មិនៗសល់ទេ បាទ។ អ៊ីចឹងទេ បើខ្ញុំ និយាយពីរបប៧៥ហ្នឹង គាត់ធ្វើតែចំពោះកម្មាភិបាល។ ហើយកម្មាភិបាលមានចៅហ្វាយស្រុក ឬក៏មាន មេកងធំ កងតូច កងវរៈអ៊ីចឹងទៅ អ៊ីចឹងទេ កូនចៅរបស់គេវាច្រើនបាទ។ អ៊ីចឹងទេ បោសសម្អាតៗតាម ខ្សែអ៊ីចឹងបាទ។ ជួនកាលទៅមានអ្នកខ្លះទៅជាប់សាច់ញាតិផ្សេង គេមិនអាចយកទៅបាន ប៉ុន្តែទាស់តែ គាត់ហ្នឹង អត់មានពាក់ព័ន្ធ--

[១០:០៥:២០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។ អញ្ជើញលោកមេធាវីវ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសង្កេតឃើញថា លោកប្រធានខ្ញុំមិនថាការបកប្រែបានត្រឹមត្រូវបានល្អទេ។ សំណួរសួរ<> អំពីជោគវាសនារបស់អតីតទាហានលន់ នល់ បាទ អ្នករដ្ឋការលន់ នល់។ ហើយ<សាក្សី>និយាយអំពីកម្មាភិបាលខ្មែរក្រហមទៅវិញ។ ខ្ញុំជឿជាក់ថាគាត់និយាយពីការបោសសម្អាត។ ខ្ញុំមិនច្បាស់ថាតើការបកប្រែដោយផ្ទាល់ ឬក៏មានការភ័ន្តច្រឡំដោយសាក្សីគាត់ច្រឡំទេ។ អ៊ីចឹងសូមឲ្យមានការបញ្ជាក់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី សូមលោករង់ចាំបន្តិចរហូតដល់<សាក្សីឆ្លើយចប់សិន។> បន្ទាប់មកលោកអាចផ្តល់សេចក្តីសង្កេត។ <ប៉ុន្តែការនិយាយ>កាត់<សាក្សី ខណៈគាត់កំពុងតែឆ្លើយ ដូចករណីនេះ គឺមិនមែនជាមធ្យោបាយដែលត្រូវធ្វើទេ>។

**លោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរសំណួរមួយចំនួនទៀតអំពី<>មន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំកែប្រែនៅក្នុងតំបន់<មណ្ឌលគិរី>ដែលលោកបានរស់នៅៗកាលនោះ។ តើមន្ទីរអប់រំ ឬក៏មន្ទីរសន្តិសុខនៅតំបន់១០៥ហ្នឹងមានអ្វីខ្លះចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ តើមន្ទីរសន្តិសុខអ្វីខ្លះដែលស្ថិតនៅក្នុងតំបន់របស់លោកនាកាលនោះ បាទ?

[១០:០៧:១៦]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ មន្ទីរសន្តិសុខនៅមណ្ឌលគិរីនេះ បើតាមខ្ញុំដឹងមានមន្ទីរសន្តិសុខមួយកន្លែងទេ ប៉ុន្តែមន្ទីរកែប្រែមានមួយកន្លែងទៀត។ មន្ទីរសន្តិសុខហ្នឹងគេហៅមន្ទីរ ក-១១ ជាកន្លែងៗគេ -- កន្លែងគុកដែលគេដាក់មនុស្សហ្នុង។ ហើយដល់មន្ទីរកែប្រែកន្លែងនេះមួយទៀត គឺគេដាក់នៅណងឃីលឹក។ អ៊ីចឹងទេបើអ្នកដែលរួចទោសដូចថាទោសស្រាលបន្តិចហ្នឹង គេអាចជូនទៅហ្នឹងដើម្បីកែប្រែ។ មានតែពីរកន្លែងទេ ប៉ុន្តែបើសិនជាការដ្ឋានវិញ បើអ្នកសន្តិសុខទាំងអស់ហ្នឹង ឬមួយក៏ឧទាហរណ៍ថាបើសិនជាមានការខុសឆ្គងអីពីកំប៉ិកកំប៉ុក ដូចជាសីលធម៌អីហ្នឹង គេអាចជូនទៅរយ៉ ឬក៏ជូនទៅតាមសហករណ៍

ផ្សេងៗអីចឹងទៅ។ មានការដ្ឋានមួយទៀត ក៏គេមិនទាន់ដាក់ថាជាសន្តិសុខដែរ ប៉ុន្តែគេដាក់ថាការដ្ឋានពាមជីមៀត នេះគេចាប់ទាហានចាស់ពីសង្គមមុនក្នុងរបបលន់ នល់ របបសម្ដេចឪ ហើយយកទៅដាក់នៅទីនោះជាកន្លែងគេលត់ដំទាហានចាស់បាទ។ ហ្នឹងគេដាក់ៗឈ្មោះថាជីមៀតនៅជីមៀតបច្ចុប្បន្នហ្នឹងជាឃុំជីមៀតចាស់ពីដើមមក។ ហើយណងឃីលីកនេះ ជាកន្លែងសន្តិសុខសម្រាប់កែប្រែ ហើយ ក-១១ នេះ វាជាគុកហ្នឹងបាទ។ ហើយជាប់នៅកណ្ដាលស្រុកកោះញែកសព្វថ្ងៃហ្នឹង។

[១០:០៩:១៩]

**ស៖** ដើម្បីឲ្យលោកបំភ្លឺ នៅពេលដែលលោកនិយាយ<អំពីមន្ទីរសន្តិសុខ> ក-១១ <> តើលោកចង់និយាយអំពីមន្ទីរសន្តិសុខ <ក-១១>ដែលស្ថិតនៅ<ក្នុង>បរិវេណយោធា<តំបន់> ឬក៏លោកនិយាយពីមន្ទីរសន្តិសុខដែលស្ថិតនៅ<>ជិតទៅនឹងទំនប់ភ្នំក្រោល? សូមលោកបំភ្លឺ បាទដែលលោកនិយាយថាមន្ទីរសន្តិសុខនៅ ក-១១ហ្នឹង តើដូចម្ដេចបាទ?

**ឆ៖** បាទ សូមបញ្ជាក់បន្តិចកន្លែងនេះ។ គ្រាន់តែថាមន្ទីរសន្តិសុខហ្នឹង វាមិន -- គេឈ្មោះផ្សេងខ្ញុំអត់ចាំទេ ប៉ុន្តែវានៅជាប់នឹងមន្ទីរៗក-១១ បាទ ជាប់នឹងទំនប់ភ្នំក្រោលហ្នឹងគឺជាកន្លែងគុក ប៉ុន្តែមិនដឹងគេដាក់ឈ្មោះម៉េច ខ្ញុំអត់ចាំបាទ ប៉ុន្តែនៅហ្នឹងគេដាក់ ក-១១ ជាកន្លែងទាហានបាទ។ សូមអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារង។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីយើងនិយាយអំពីមន្ទីរសន្តិសុខនៅតំបន់១០៥។ ឥឡូវនេះ ខ្ញុំសូមអានសម្រង់មួយលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ឯកសារ E3/5178, ខ្មែរ ERN 00197862, អង់គ្លេស 00274101, បារាំង 00485186។ នេះគឺជាអ្វីដែលលោកឆ្លើយពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ។ សូមដកស្រង់៖ "ក-១១ ជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន ហើយអ្នកជាប់ឃុំឃាំងត្រូវបញ្ជូនទៅណងឃីលឹក បើសិនណាជាគេ<ចាត់ទុកថា>អាចកែប្រែខ្លួនបាន <ហើយនិងបញ្ជូនទៅ>ភ្នំក្រោល<បើគេចាត់ទុកថា ជាអ្នកទោសធ្ងន់>។ ឱកាសនៃការរស់រានមានជីវិត<>គឺ<តិចតួចណាស់សម្រាប់អ្នកណា>ដែល<គេ>បញ្ជូនទៅភ្នំក្រោល<>"។ បញ្ចប់ការដកស្រង់។ តើចំណុចនេះរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី? តើត្រឹមត្រូវដែរទេថា កន្លែងនៅក-១១ គឺជាកន្លែងឃុំខ្លួនបណ្តោះអាសន្ន? ហើយមន្ទីរសន្តិសុខនៅភ្នំក្រោល គឺសម្រាប់អ្នកទោសកម្រិតធ្ងន់<នោះ>។ ត្រឹមត្រូវ<>ទេ?

[១០:៣៥:០០]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ពិតមែន។

**ស៖** អ្នកទោសប្រភេទណាដែលគេចាត់ទុកថា អ្នកទោសកម្រិតធ្ងន់? <តើធ្វើម៉េចទើបលោកដឹងថា អ្នកទោសធ្ងន់>ត្រូវ<បាន>បញ្ជូនទៅមន្ទីរសន្តិសុខភ្នំក្រោល?

**ឆ៖** បាទ អ្នកទោសដែលធ្ងន់ជាងគេនៅនុ៎ង គឺអ្នកទោសក្បត់ ឬក៏ចូលយួនហ្នឹងតែម្តងបាទ។

**ស៖** ហើយលោកបានឆ្លើយថា ឱកាសរស់ហ្នឹងគឺថា មានតិចតួចណាស់សម្រាប់អ្នកដែលគេបញ្ជូនទៅមន្ទីរសន្តិសុខភ្នំក្រោល។ គឺលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ធ្វើម៉េចបានជាលោកដឹងអំពីជោគវាសនាបែបនេះ?

**ឆ៖** បាទ ព្រោះមានអ្នករស់ខ្លះដែរបាទ មិនមែនស្លាប់ទាំងអស់ទេ។ អ្នករស់ហ្នឹងគឺបច្ចុប្បន្នគាត់នៅម្នាក់ពីរនាក់ដែរបាទ។

01225739



**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ មានអ្នករស់រានមានជីវិតប៉ុន្មាននាក់ដែរពីមន្ទីរសន្តិសុខភ្នំក្រោល? <តើ>លោកដឹង <នរណា>ដែលរស់រានមានជីវិតមកទល់ពេលនេះ?

**ឆ៖** បើតាមខ្ញុំដឹងច្បាស់មានប្អូនថ្លៃខ្ញុំម្នាក់ដែលគាត់ទើបស្លាប់ខែមុនទេបាទ ប៉ុន្តែគាត់បានជាប់គុកជាមួយ កាស៊ី ដែរបាទ។ ហើយគាត់បានរស់រានមានជីវិត គេលែងគាត់មកវិញ។

**ស៖** ចំណុចនេះគឺតាមពិតគឺខ្ញុំត្រូវសួរបន្ទាប់នេះ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតក៏ដូចមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកមានសាច់ញាតិត្រូវបានគេឃុំខ្លួននៅភ្នំក្រោល។ លោកថាសាច់ថ្លៃរបស់លោកគេឃុំនៅទីនុ៎ង។ តើសាច់ញាតិរបស់លោកសរុបទាំងអស់មានប៉ុន្មាននាក់ដែលគេឃុំខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោល? ហើយមូលហេតុអីបានជាគេបញ្ជូនសាច់ញាតិរបស់លោកទៅឃុំខ្លួននៅភ្នំក្រោល?

**ឆ៖** បាទ កាលនុ៎ងគេចាប់ពួកគាត់ហ្នឹងមិនមែនចាប់ហើយយកទៅសម្លាប់ភ្លាមទេ គឺគេដាក់ឱ្យនៅជាប់គុកហ្នឹងរយៈពេលមួយអាទិត្យអីចឹងទៅ។ ហើយអ្នកណាដែលស្រាលទៅ គេអាចបញ្ជូនទៅកែប្រែនៅណងឃីលីក អ្នកណាធ្ងន់ទៅក៏គេយកទៅវ៉ៃចោលដែរ។ អីចឹងនៅរស់រានមានហ្នឹងមានតិចតួចដូចជាមាន -- ខ្ញុំមិនចាំឈ្មោះដែរទេបាទ ប៉ុន្តែចាំច្បាស់មានតែឈ្មោះ វៀង ប្អូនថ្លៃខ្ញុំហ្នឹង ដែលគេចេញមកពីហ្នឹង ហើយគាត់បានរៀបរាប់ប្រាប់ពីរឿងរ៉ាវខ្លះៗដែលគាត់ធ្លាប់ជាប់គុកនៅក្នុងពន្ធនាគារទីនោះ។

[១០:៣៨:៣៧]

**ស៖** តើលោកមានសាច់ញាតិណាដទៃទៀតត្រូវបានគេបញ្ជូនទៅឃុំខ្លួននៅភ្នំក្រោល ហើយ<> មិនរស់រានមានជីវិតពីរបបនោះដែរទេ?

**ឆ៖** បាទ សូមរៀបរាប់អ្នកដែលខ្ញុំចាំទេបាទ មានអ្នកដែលគេចាប់ស្រែករជាមួយខ្មោចឪពុកមាខ្ញុំហ្នឹង តាកាស៊ី ហ្នឹង មានបីបួននាក់ហ្នឹងអត់មានមកវិញទេ។ ហើយចំពោះគ្នាពួកគាត់ច្រើនដែរ រាប់មិនអស់ទេព្រោះ -- ដែលគាត់អត់បានមកវិញដែរ។ តាមខ្ញុំដឹងឃើញមកតែម្នាក់ពីរនាក់ ប៉ុន្តែម្នាក់ហ្នឹងខ្ញុំចាំច្បាស់ គឺជាប្អូនថ្លៃខ្ញុំ ហើយប៉ុន្មាននាក់ហ្នឹងខ្ញុំអត់ចាំទេ ព្រោះគេទៅស្រុកទៅស្រែគេវិញអស់ បាទ។

**ស៖** តើសាច់ញាតិ<ទាំងអស់ជា>អ្នកដែលគេចាប់ខ្លួន<នៅពេល>ជាមួយគ្នានឹងឪពុកមារបស់លោកឈ្មោះ កាស៊ី <> ឬក៏មិនមែនទេ?

**ឆ៖** បាទ ជាប់សាច់ញាតិជិតភូមិផងជាមួយហ្នឹងដែរ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេអំពីមន្ទីរសន្តិសុខភ្នំក្រោល? តើមន្ទីរសន្តិសុខមួយ

នេះមានទ្រង់ទ្រាយលក្ខណៈរបៀបម៉េចដែរ?

**ឆ៖** បាទ មន្ទីរសន្តិសុខនេះ បើប្រៀបធៀបទៅមិនបានស្មើក្រោលគោមួយទេ បាទ ប៉ុន្តែអាចដាក់មនុស្សបានច្រើនដែរប្រហែលជាខ្ទង់១០០ អីនាក់។ វាជាជញ្ជាំងឫស្សីប្រក់ស្បូវ ហើយដាក់ចម្រូងជុំវិញមិនអាចរត់បានអី បាទ។ អ្នកណារត់មានតែ -- មិនដែលឃើញមានឮថារត់រួចផង។

**ស៖** តើខ្លួនលោកផ្ទាល់បានឃើញមន្ទីរសន្តិសុខនេះដោយផ្ទាល់ភ្នែក ឬក៏អត់ទេ? ហើយបើសិនជាបានឃើញមែន តើលោកបានឃើញមន្ទីរសន្តិសុខភ្នំក្រោល<នៅ>ណា<>?

**ឆ៖** បាទ ព្រោះកន្លែងមន្ទីរសន្តិសុខហ្នឹង ផ្លូវយើងធ្លាប់ដើរ ដើរកាត់ហ្នឹងតែម្តង ប៉ុន្តែយើងមិនអាចចូលទៅក្នុងបានទេបាទ ប៉ុន្តែក្រឡេកមើលឃើញពីចម្ងាយ ប្រហែលជាខ្ទង់ ១០០ម៉ែត្រអីហ្នឹង ៥០ម៉ែត្រអីហ្នឹង ដើរកាត់សៀរៗហ្នឹងពីណាក៏ឃើញដែរ។

**ស៖** តើលោកដឹងថា អ្នកណាជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខភ្នំក្រោល?

**ឆ៖** បាទ អ្នកគ្រប់គ្រងសន្តិសុខមន្ទីរភ្នំក្រោលឈ្មោះ ផៃ បាទ។

**ស៖** តើ ផៃ នេះជាអ្នកណា? តើ ផៃ នេះស្ថិតនៅក្នុង<>អង្គការ <ឬក៏អង្គភាពអ្វីរបស់>តំបន់<នោះ>?

**ឆ៖** បាទ ផៃ នេះគាត់ជាអ្នកស្រុកហ្នឹងទេ។ គាត់ជាទាហាន។ ដំបូងគេឲ្យគាត់ធ្វើទាហាន ជាមេបញ្ជាការទាហានស្រុក គឺស្រុកអូររាំង។ បន្ទាប់មក គេយកមកឲ្យគាត់កាន់មន្ទីរសន្តិសុខហ្នឹងតែម្តង។

[១០:៤៣:១៧]

**ស៖** តើពេលនុ៎ង គាត់ជាទាហានតំបន់ ដែលគ្រប់គ្រងបញ្ជាដោយ<ប្រធានយោធាតំបន់> តាសុភា ឬក៏យ៉ាងណា?

**ឆ៖** បាទ គាត់ជាទាហានស្រុកទេបាទ គាត់មេបញ្ជាការទាហានស្រុក តែក៏ក្រោមការដឹកនាំរបស់ សុភា ដែរ ព្រោះ សុភា ធំ។

**ស៖** ខ្ញុំចង់សួរលោកថា តើលោកដឹងយ៉ាងដូចម្តេចដែរ អំពីការសម្លាប់អ្នកទោសនៅភ្នំក្រោល? តើលោកដឹងថា គេមានយកអ្នកទោសនៅភ្នំក្រោលយកទៅសម្លាប់ដែរទេ?

**ឆ៖** បាទ នេះតាម ខ្ញុំដឹងតាមរយៈដែលអ្នកចេញពីគុកហ្នឹងទេបាទ។ មានម្តងម្កាលអ៊ីចឹងទេ គេយកឡានមកដឹកយកទៅ។ ប៉ុន្តែខ្ញុំមិនដឹងចំនួន អត់ដឹងចំនួនគេយកទៅម្តងៗនោះទេ។

**ស៖** តើគេយកអ្នកទោសទៅសម្លាប់ចោលនៅឯណាដែរ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ជួនកាល បើតិចតួច អត់មានឡានដឹក គេសម្លាប់ជិតៗហ្នឹង គេអត់យកទៅឆ្ងាយទេ បាទ។ បើច្រើនទ្រង់ទ្រាយ អាហ្នឹងគេដឹកឡានយកទៅសម្លាប់ផ្លូវទៅក្រចេះ។ មិនអាចសម្លាប់នៅក្បែរនុំងបានទេ។

**ស៖** តើលោកស្គាល់កន្លែងមួយឈ្មោះថា ត្រពាំងព្រីងដែរទេ?

**ឆ៖** បាទ ត្រពាំងព្រីង ផ្លូវទៅក្រចេះ ផុតផ្លូវបំបែកទៅរយ៉ បាទ។

**ស៖** តើត្រពាំងព្រីង មានចម្ងាយប៉ុន្មានពី<ការដ្ឋាន>រយ៉<ដែល>លោក<នៅនោះ>?

**ឆ៖** បាទ មិនឆ្ងាយពេកទេ តែ ៣-៤គីឡូប៉ុណ្ណឹង បាទ។

**ស៖** តើលោកមានដែលមានឱកាសធ្វើដំណើរទៅកាន់ត្រពាំងព្រីងដែរទេ? ហើយ<>តើលោក<បាន>ឃើញថា មានអ្វីកើតឡើងនៅត្រង់ទីតាំងនេះ?

**ឆ៖** បាទ តាំងពីនុំងមក មិនដែលទៅទេ គ្រាន់តែដើរសៀរៗ ចម្ងាយប្រហែលជា១គីឡូដី ឃើញតែស្នាមគេឈូសឆាយអីចឹង ក្រលេកមើលឃើញមាន គេប្រាប់ថាកន្លែងសម្លាប់មនុស្សតែប៉ុណ្ណឹង។ ខ្ញុំអត់បានចូលទៅដល់ទេ បាទ។ សូមជម្រាប។

[១០:៤៧:៤៤]

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត គឺឯកសារ E3/5178, ERN ជាភាសាខ្មែរ 00197858, អង់គ្លេស 00274096 ដល់ 97, បារាំង 00485181 ដល់ 82។ បាទ <នេះជាអ្វី>ដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត។ សូមដកស្រង់៖ "ទីតាំងសម្លាប់មនុស្សហៅថា ត្រពាំងព្រីង មានចម្ងាយប្រមាណ៤គីឡូម៉ែត្រពីកោះញែក គឺស្ថិតនៅតាមផ្លូវចេញពីកោះញែក ទៅកាន់ខេត្តក្រចេះ។ គេយកត្រាក់ទ័រទៅជីករណ្ដៅធំៗ ហើយគេឈូសដីទៅលុបវិញនៅពេលសម្លាប់មនុស្សហើយ។ ខ្ញុំបានឃើញរណ្ដៅហ្នឹងផ្ទាល់ភ្នែក។ ទីកន្លែងសម្លាប់មនុស្សហ្នឹង គេបានយកឡានប៊ុលដូហ្ស៊ី យកទៅឈូសដីលុប។ ខ្ញុំបាន<រស់នៅ>ទីតាំង<>សម្លាប់មនុស្ស<នេះ ក្នុងរយៈពេលដែលគេសម្លាប់មនុស្ស>។"

ហើយក្រោយមកទៀត នៅក្នុងកិច្ចសម្ភាសន៍នេះ ពីរបីទំព័រខាងក្រោម លោកបានឆ្លើយថា លោកធ្លាប់បានធ្វើដំណើរ ហើយឆ្លងកាត់ទីតាំងត្រពាំងព្រីងនេះ មើលឃើញពីចម្ងាយ។ តើលោកអាចបញ្ជាក់ជូនតុលាការថា លោកពិតជាបានទៅត្រពាំងព្រីង ហើយលោកពិតជាបានឃើញគេយកត្រាក់ទ័រទៅជីករណ្ដៅ ដើម្បីសម្លាប់មនុស្សមែន<ទេ>? តើលោកអាចជម្រាបជូនបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ លោកប្រធាន។ ដូចការជំទាស់លើកទី១របស់ខ្ញុំ គឺការដកស្រង់ <នេះ>ក្រៅបរិបទនេះហើយ។ <>គាត់<ផ្តល់ភ័ស្តុតាងនេះ>ពាក់ព័ន្ធទៅនឹងការប្រមូល<>ទិន្នន័យអ្នកស្តាប់ ចន្លោះពីឆ្នាំ<៩៨ -- ៨៣> ដល់៨៥។ <ច្បាស់ណាស់ គឺពាក់ព័ន្ធទៅ>ដល់ថ្ងៃចងកំហឹង <ហើយគាត់បានចូលរួមប្រមូលផ្តុំមនុស្ស។ ដូច្នេះហើយ ចំណុចនេះ ដែលគាត់បានផ្តល់ភស្តុតាងរបស់គាត់នោះ>។ ហើយក្រោយមកគាត់និយាយពីត្រពាំងព្រីងនេះ គាត់និយាយថាគាត់ឮពីគេទេ។ អ៊ីចឹង <ការសួរក្រៅបរិបទ ដោយមិននិយាយថា សក្ខីកម្មនេះបានមកពីព័ត៌មានក្រោយឆ្នាំ៧៩ទេ នេះគឺជាមូលហេតុ>ខ្ញុំ<>ជំទាស់ចំពោះការសុំសួរសំណួរនេះ<>។

**លោក ឌេល លីសាក់៖**

<លោកប្រធាន ចម្លើយរបស់>គាត់បាននិយាយថា <>គាត់បានឃើញផ្ទាល់ភ្នែក។ យ៉ាងដូច្នេះឯងទើបខ្ញុំសួរបញ្ជាក់ឲ្យបានច្បាស់ថាតើអ្វីដែលគាត់ឃើញផ្ទាល់ភ្នែកនោះគឺអ្វីខ្លះ? ហើយគាត់ឮពីគេ ឮយ៉ាងដូចម្តេច? អ៊ីចឹង<ការជំទាស់របស់មេធាវីការពារក្តីគឺមិនត្រូវទេ។ ពាក្យនោះគឺមានច្បាស់ណាស់នៅក្នុងកិច្ចសម្ភាសន៍របស់គាត់។ ប៉ុន្តែខ្ញុំពិតជាមានបំណងចង់ដឹងថា តើគាត់បានដឹងរឿងនោះផ្ទាល់ខ្លួនពីអ្វីខ្លះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

<គាត់មិនសួរអំពីអ្វីដែលបានឃើញទេ ប៉ុន្តែគាត់សួរអំពីពេលវេលាដែល>បានឃើញ<ទៅវិញ>?

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<បរិបទនោះលោកបានផ្តល់ជូនហើយ ឥឡូវនេះ។>

[១០:៥១:១៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះសំណួរគឺយ៉ាងដូច្នេះលោកសាក្សី។ តើលោកពិតជាបានឃើញរថយន្តត្រាក់ទ័រជីករណ្តៅនៅត្រពាំងព្រីងនោះមែនទេ? ហើយបើបានឃើញមែន តើលោកឃើញគេយកត្រាក់ទ័រទៅជីករណ្តៅនេះនៅពេលណា?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ រណ្តៅនេះមិនចំពោះតែយើងទេ អ្នកណាក៏គេឃើញដែរបាទ ព្រោះកាលដែលគេធ្វើ

ផ្លូវហ្នឹង គេឈូសនៅជិតផ្លូវហ្នឹង ចម្ងាយប្រហែល១០០ម៉ែត្រ ហើយក៏ជិតផ្លូវខ្ញុំចេញចូលទៅរយ៉ដែរ វាអត់ឆ្ងាយទេ។ ប៉ុនអាចអ្នកណាក៏មើលឃើញៗដែរ ប៉ុនគ្រាន់តែថាវាហួសពីទីតាំងមនុស្សនៅតែប៉ុណ្ណឹង ប៉ុន្តែអារឿងដែលសម្លាប់នោះ យើងមិនបានទៅឃើញគេទេ ប៉ុន្តែគ្រាន់តែថាមានទាហានម្នាក់ គាត់បានប្រាប់ថាកន្លែងគេឈូសសម្រាប់កប់មនុស្ស តែប៉ុណ្ណឹង សូមអស់។

[១០:៥២:២៧]

**ស៖** តើលោកបានឃើញហ្នឹងឃើញនៅក្នុងរបបនោះ ចន្លោះពីឆ្នាំ៧៥ ទៅដល់ ៧៨ <>ដែលលោកឃើញគេជីករណ្ដៅចម្ងាយ១០០ម៉ែត្រពីផ្លូវជាតិ? ហើយតើលោកអាចជម្រាបជូនតុលាការបានទេថាហេតុអីបានជាលោកធ្វើដំណើរទៅទីនោះ ជាឱកាសយ៉ាងដូចម្ដេចដែរ ដែលទើបឲ្យលោកឃើញគេជីករណ្ដៅនោះ?

**ឆ៖** បាទ គេជីកហ្នឹងគេជីកក្នុងចន្លោះឆ្នាំ៧៧ ទេបាទ។ ហើយធម្មតាខ្ញុំធ្លាប់ចេញចូលតាមហ្នឹង ខ្ញុំនៅរយ៉ ខ្ញុំធ្វើនៅការដ្ឋានរយ៉ហ្នឹង ខ្ញុំចេញចូលរហូតពីណាក៏ឃើញដែរ ក្រឡេកមកចម្ងាយប្រហែល១គីឡូដីឃើញហើយ បាទ។

[១០:៥៣:៣៣]

**ស៖** លោកក៏ទើបតែឆ្លើយថាគេបានប្រាប់លោកនូវអ្វីដែលបានកើតឡើងនៅត្រពាំងព្រីងគឺទាហាន<តំបន់>ម្នាក់ជាអ្នកប្រាប់លោក។ តើទាហាន<តំបន់>នេះឈ្មោះអី <>អ្នក<ដែល>ប្រាប់លោកអំពីទីតាំងនេះ?

**ឆ៖** បាទ គាត់មិនមែនទាហានស្រុកទេ គឺគាត់ទាហានតំបន់ អ្នកយាមខ្ញុំហ្នឹងតែម្តងបាទ។ គាត់ឈ្មោះ ប៊ុន។

**ស៖** តើលោកដឹងថា ប៊ុន គឺជាទាហានម្នាក់ -- កងទ័ពម្នាក់ក្នុងចំណោមកងទ័ពដែលទទួលរ៉ាប់រងសម្លាប់មនុស្សនៅត្រពាំងព្រីងហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ អត់ទេ គាត់អ្នកយាម ពួកខ្ញុំអ្នកធ្វើស្រែទេ បាទ។

**ស៖** នៅពេលលោកធ្វើការនៅការដ្ឋានរយ៉ តើលោកដែលឃើញគេយកឡានធំៗដឹកមនុស្ស<តាមផ្លូវ>សំដៅទៅកាន់ទីតាំងត្រពាំងព្រីងនេះដែរទេ?

**ឆ៖** បាទកាលខ្ញុំនៅរយ៉ គេដឹកមនុស្សយកទៅសម្លាប់នេះ ក៏អត់ដឹងថាយកទៅដាក់ហ្នឹងដែរ ប៉ុន្តែគេចាប់មនុស្សហើយ គេឃុំពួកខ្ញុំឲ្យធ្វើមីទ្និងនៅហ្នឹង គេយកឡានទៅបាត់មិនដឹងគេយកទៅសម្លាប់

នៅណាអត់ដឹងផង ដាក់ពីរឡាន បីឡានយកទៅ ចាប់ខ្សែប្រពន្ធកូន តាចាន់ថន តាជួនបាទ។

[១០:៥៥:៤៣]

**ស៖** នៅពេលដែលលោកនិយាយថាគេដឹកមនុស្សយកចេញទៅបាត់តាមរថយន្តធំៗហ្នឹង តើ<លោកនិយាយអំពីអ្នកដែល>គេ<បញ្ជូន>ចេញពីការដ្ឋានរយ៉ហ្នឹង ឬក៏<អ្នកទាំងអស់នេះ ត្រូវ>គេដឹកចេញពីទីកន្លែងផ្សេងទៀត? សូមលោកបញ្ជាក់ចំណុចនេះឲ្យបានច្បាស់បន្តិចមើល?

**ឆ៖** បាទ បើតាមខ្ញុំដឹង ខ្ញុំនៅទីនោះគេយកពីរយ៉បាទ។

**ស៖** ខ្ញុំសូមអានសម្រង់មួយដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតគឺ E3/5178, ERNជាភាសាខ្មែរ 00197861, អង់គ្លេស 00274099, បារាំង 00485185 លោកបានឆ្លើយថា៖ "មន្ទីរ ក-១១ គឺជាទីតាំងបន្ទាយទាហានសព្វថ្ងៃ។ កាលខ្ញុំនៅការដ្ឋាន<នេះ>ខ្ញុំបានឃើញមនុស្សប្រហែល ៣០នាក់ត្រូវបានគេ<ដឹក>ចេញចូលពីរបីថ្ងៃម្តង។ <> ជនរងគ្រោះដែលគេដឹកចេញ គឺគេយកទៅសម្លាប់ចោល"។ ដូច្នេះ ចំណុចត្រង់នេះច្បាស់ហើយលោកសាក្សីថា នៅពេលដែលលោកនិយាយថាលោកនៅការដ្ឋានហើយលោកឃើញគេដឹកមនុស្ស ៣០នាក់ចេញចូលពីពីរបីថ្ងៃម្តង។ តើលោកឃើញនេះ ឃើញ<>ត្រង់កន្លែងណា?

[១០:៥៧:៤០]

**ឆ៖** បាទ គេធ្លាប់ដឹក ដឹកចេញពីកន្លែងសន្តិសុខហ្នឹង តាមផ្លូវកាត់តាមផ្លូវមុខមន្ទីរហ្នឹង យើងបរទេសគោតាមហ្នឹងទៅ ដើរកាត់គេហ្នឹងទៅ ជិតនឹងទេបាទ។

**ស៖** បាទ ខ្ញុំសូមសួរបញ្ជាក់ឲ្យបានច្បាស់លាស់អ្នកទាំងនេះគឺថាមិនមែនគេដឹកចេញពីការដ្ឋានរបស់លោកទេ គឺជាប្រជាជនដែលគេដឹកចេញមន្ទីរសន្តិសុខ។ អ៊ីចឹងឬក៏យ៉ាងណាលោក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ឆ្លើយ!

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ គេដឹកពីកន្លែងមន្ទីរសន្តិសុខ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** តើមានឱកាសណាមួយដែលលោកបានឃើញឡានធំៗ<>ដឹកមនុស្ស <ដែល>លោកស្គាល់<ថាជា>ប្រជាជន<>ចេញពី<មន្ទីរ>ស្រុកកែវសីមា<ដែរទេ? តើលោកចងចាំទេ? ហើយតើ

លោកអាចរៀបរាប់ព្រឹត្តិការណ៍នោះក្នុងសវនាការនេះបានទេ>?

**ឆ៖** បាទមានថ្ងៃមួយហ្នឹង ថ្ងៃខ្ញុំគេជម្លៀសទៅរយ៉ហ្នឹង គឺគេឱ្យខ្ញុំឃ្វាលក្របីចំនួន ២២ក្បាល។ ពេលហ្នឹង ខ្ញុំប្អូនខ្ញុំហើយហ្នឹងមួយក្រុមខ្ញុំហ្នឹង បានដេញក្របីកាត់មន្ទីរពាណិជ្ជកម្មខេត្តហ្នឹងគឺកន្លែង តាជួន ដែលគាត់ជាមន្ទីររបស់គាត់ ហើយខ្ញុំស្រេកទឹកពេក ខ្ញុំបានទៅសុំទឹកគេផឹក។ ពេលនោះ ខ្ញុំឃើញឡានមួយដែលឈរជាប់មុខមន្ទីរហ្នឹង ហើយក្បែរធុងទឹក ខ្ញុំបានសុំទឹកគេផឹក គេថា ដងទឹកនៅពុយទៅ។ ខ្ញុំក៏បឺដុងទឹកខ្ញុំ ជ្រមុជចូលទៅ ខ្ញុំផឹកៗ ឮគេនិយាយ ឮខ្ញុំនិយាយអ៊ីចឹង អ្នកនៅលើហ្នឹងគេស្គាល់ឈ្មោះខ្ញុំ គេបានសុំទឹកខ្ញុំផឹកបាទ។ ពេលនោះ ខ្ញុំបានឮគ្នាខ្ញុំអ្នកនៅមន្ទីរស្រុកកែវសីមា គេប្រាប់ខ្ញុំថា "ពួកខ្ញុំគេចាប់អស់ហើយ ៨០នាក់ជាង។ ពួកខ្ញុំមិនដឹងស្លាប់ ឬរស់ទេ។ តើឯងនៅរស់ដែរឬអត់?" ខ្ញុំថា "ខ្ញុំនៅរស់ទេ" ហើយអត់ហ៊ាននិយាយឮទេ និយាយតិចៗ។ ពេលនោះ ខ្ញុំក៏ប្រញាប់ប្រញាល់ ខ្ញុំថាមិនអាចយកទឹកឱ្យអ្នកឯងបានទេ។ បើខ្ញុំយកទឹកឱ្យអ្នកឯង ខ្ញុំក៏ប្រហែលជាស្លាប់ដូចគ្នា។ អ៊ីចឹងខ្ញុំក៏ប្រញាប់ប្រញាល់ យកទឹកប្រញាប់ទៅឱ្យគ្នាខ្ញុំនៅកន្លែងចងក្របី បាទ។ នេះជាការពិត។

[១១:០១:២២]

**ស៖** ពេលដែលលោកនិយាយថា "គ្នាលោកជាង៨០នាក់" <ត្រូវបានចាប់ខ្លួន> តើអ្នកទាំងនោះគឺជាអ្នកណា? <តើក្រុមមនុស្ស>៨០នាក់នុ៎ង<ជាអ្នកណា ដែលគេចាប់ខ្លួននោះ>?

**ឆ៖** បាទ អាចចាំឈ្មោះបានពីរបីនាក់ដែរ មិនបានទាំងអស់ទេបាទ ព្រោះមានប្រជាជនខ្លះមួយចំនួន ហើយក៏មានអ្នកធ្វើការនៅក្នុងមន្ទីរស្រុកហ្នឹងមួយចំនួន ហើយទាហានមួយចំនួន។ អ្នកនៅនុ៎ងក៏មានឈ្មោះ ជាប្រធានមន្ទីរមួយ ឈ្មោះប៉ុប គាត់ជនជាតិព្នង, ឈ្មោះ ប៊ុ គាត់ជនជាតិខ្មែរ។ ហើយនៅបងប្អូនមួយចំនួនទៀត ច្រើនដែរ ដែលខ្ញុំចាំហ្នឹងបើសិនជាអាចសរសេរ ខ្ញុំអាចសរសេរបាន។ បើនិយាយហ្នឹងមាត់ហ្នឹង ដូចវាភ្លេចយូរពេកហើយ បាទ។

**ស៖** មិនជាថ្វីទេលោក លោកបានឆ្លើយបញ្ជាក់ឈ្មោះច្រើនដែរហើយ។ តែខ្ញុំសួរថា តើក្នុងចំណោមមនុស្សជាង ៨០នាក់ហ្នឹង ជាសាច់ញាតិរបស់លោក ឬក៏ជាអ្នកជាប់ខ្សែ ខាំ ភួន <ដែលធ្លាប់ធ្វើជាអនុលេខាតំបន់នោះ> ឬក៏<មនុស្ស៨០នាក់នោះជាក្រុមផ្សេង>? សូមលោកបញ្ជាក់ចំណុចនេះឱ្យបានច្បាស់បន្តិចមើល៍។

**ឆ៖** បាទ ខ្សែនេះ មិនមែនខ្សែ ខាំ ភួន ទេ គឺខ្សែ កាស៊ី បាទ ព្រោះកូនចៅរបស់ កាស៊ី បាទ។ ហើយក៏មិនមែនសាច់ញាតិខ្ញុំដែរ បាទ គាត់អ្នកផ្សេងៗទេបាទ គ្រាន់តែស្គាល់គ្នា ធ្លាប់រស់នៅជាមួយគ្នា

ធ្វើការជាមួយគ្នាតែប៉ុណ្ណឹង។

**សៈ** ឥឡូវនេះ ខ្ញុំប្ដូរទៅប្រធានបទមួយផ្សេងទៀត។ តើលោកនៅចាំដែរឬទេ ថាតើលោក ខៀវ សំផន ធ្លាប់ទៅធ្វើទស្សនកិច្ចនៅតំបន់របស់លោកដែរឬទេ? ក្នុងករណីដែលលោកធ្លាប់ឃើញ តើលោកនៅចងចាំពីហេតុការណ៍អ្វីខ្លះនៅក្នុងពេលនោះ?

**ឆៈ** បាទ តាមខ្ញុំចាំ ឆ្នាំ៧៤ ពួកខ្ញុំទៅច្រូតស្រូវជួយតំបន់ហ្នឹងគេនៅមន្ទីរតំបន់ហ្នឹង តាញ៉ុន តានេះគាត់ដកកាំភ្លើងពួកខ្ញុំអស់។ ពួកខ្ញុំជាអង្គរក្សទេ ហើយគ្នាពួកខ្ញុំ តាមស្រុកៗហ្នឹងច្រើនគ្នាបាទ គ្រប់ស្រុក។ ដល់គេដកកាំភ្លើងពួកខ្ញុំអស់ ខ្ញុំឆ្ងល់ថា ហេតុអីបានគេដកកាំភ្លើង? ដល់មានឈ្មោះម្នាក់ហ្នឹងគាត់អនុប្រធានមន្ទីរ ក-១៦ ហ្នឹងគាត់ប្រាប់ថា លោក ខៀវ សំផន នឹងអញ្ជើញមកដល់ដើម្បីមកទស្សន-កិច្ចនៅខេត្តយើងនេះ។ ហើយចាំបាច់ដកកាំភ្លើងដែរវ៉ី? គេថា អត់ទេ គេអត់ទុកចិត្ត។ អ៊ីចឹងគេមាន អង្គ-រក្សការពាររបស់គេហើយ។ ហើយគេដកកាំភ្លើងពួកខ្ញុំទុកទៅ។ អ៊ីចឹងដល់ពេលហ្នឹង ពួកខ្ញុំអ្នកច្រូតស្រូវអត់បានចាប់អារម្មណ៍អីទេ មិនដឹងថាគាត់មកឬអត់ តាំងពីហ្នឹងមកក៏បាត់រហូត។ តែខ្ញុំចាំបានលោក ហ៊ូ នឹម បានចូលទៅដល់ទីតាំងនោះ ហើយបានចាប់ដៃខ្ញុំផ្ទាល់បាទ ប្រហែលឆ្នាំ៧១ ចូល៧២ បាទ។ អានេះបានជួបផ្ទាល់។ បើលោក ខៀវ សំផន ខ្ញុំអត់បានជួបទេ អត់បានឃើញទេ គ្រាន់តែឮតែគេប្រាប់។

**សៈ** តាមដែលខ្ញុំយល់ត្រឹមត្រូវលោកខ្លួនលោកផ្ទាល់មិនបានឃើញលោក ខៀវ សំផន និងគណៈប្រតិភូរបស់គាត់ដោយផ្ទាល់ភ្នែកទេ នៅពេលដែលគាត់បានទៅមណ្ឌលគិរី។ តើអ៊ីចឹងត្រូវដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

[១១:០៥:៤៩]

**សៈ** ខ្ញុំចង់អានជូនលោកស្ដាប់អំពីសម្រង់នៅឯកសារ E3/5178, ខ្មែរ 00197866, អង់គ្លេស 00274104, បារាំង 00485190។ នេះជាអ្វីដែលលោកបាននិយាយអំពីលោក ខៀវ សំផន។ សូមដកស្រង់៖ "ឆ្នាំ១៩៧៤ ខៀវ សំផន ប្រធានរដ្ឋ ប្រធានរណសិរ្សមកទស្សនកិច្ចមណ្ឌលគិរីនៅម្ដុំ ក-១១ ពេលដែលខ្ញុំកំពុងច្រូតស្រូវ" បន្ត "គាត់មកប្រហែលពីរបីថ្ងៃ ហើយបាន<ទៅមើល>អូរបួនក្រោម ស្រែហ៊ុយ <និងសំណង់>ទំនប់។ <គាត់មកជាមួយប្រតិភូដែល>មានគ្នាច្រើន <>មានឡានប្រាំមួយសរុបទាំងអស់<៦គ្រឿង>។" ចប់សេចក្ដីដកស្រង់។ <> ដោយហេតុថាលោកមិនបានឃើញគណៈប្រតិភូទេ តើហេតុអ្វីលោកដឹងថា លោក ខៀវ សំផន មកទស្សនកិច្ចនៅក-១១ ហើយទៅមើលការដ្ឋានសាងទំនប់នៅអូរបួនក្រោមនោះ។ លោកដឹងដោយរបៀបណា?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** សូមទោស តាមដែលនេះគឺប្រធាន អនុប្រធានមន្ទីរក-១១ ហ្នឹងគាត់បាននិយាយប្រាប់។ ប៉ុន្តែបានឃើញឡានហ្នឹងគេបើកចុះបើកឡើងនៅខាងលើ ពួកខ្ញុំនៅកណ្តាលស្រែទេបាទ។ ឃើញតែឡាន ប៉ុន្តែយើងអត់ឃើញខ្លួនគាត់ទេបាទ។ ប៉ុន្តែឡាន មិនដឹងជាឡានរបស់គាត់ ឬរបស់ឡានពីណា ប៉ុន្តែគេប្រាប់ថាគាត់ ប្រធានមន្ទីរគាត់ប្រាប់ថាគាត់ អនុប្រធានមន្ទីរហ្នឹង។

**ស៖** សូមឲ្យលោកបំភ្លឺ តើ<>អនុប្រធានក-១១ ជា<មន្ទីរ>កងយោធា<>តំបន់ហ្នឹង <ជាអ្នកប្រាប់លោក ឬក៏អនុប្រធាន ក-១៦ ដែលជាមន្ទីរពាណិជ្ជកម្មតំបន់?>។ <តើ>លោក<អាច>បំភ្លឺចំណុចនេះ<បានទេ>?

**ឆ៖** បាទ គាត់ជាអនុប្រធានក-១៦ ហ្នឹង ជាអនុប្រធានមន្ទីរទេ ហើយគាត់ខាងស៊ីវិល។

**ស៖** សំណួរមួយចុងក្រោយ តើៗការដ្ឋានទំនប់អូរបួនក្រោមហ្នឹង គេចាប់ផ្តើមកសាងនៅពេលណា? គឺការដ្ឋានទំនប់នេះគេចាប់ផ្តើមសាងសង់នៅពេលណា?

[១១:០៨:០២]

**ឆ៖** បាទ បើតាមខ្ញុំដឹងអូរបួនក្រោម អូរបួនលើ នេះគេកសាងស្រករគ្នាអង្កាល់ឆ្នាំ៧៥។ ហើយសម្រេច៧៧ ហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំវិលទៅរកសំណួរមួយចំនួនទាក់ទងទៅនឹងហេតុការណ៍ជាក់លាក់មួយចំនួនដែលកើតឡើងនៅក្នុងតំបន់របស់លោកនាកាលនោះ។ ទី១ តើលោកនៅចាំឬទេថាមានហេតុការណ៍មួយដែលថា បុរសមួយក្រុមមកពី -- ប្រហែលជាមកស្រុកកែវសីមា ព្យាយាមរត់គេចខ្លួនទៅប្រទេសវៀតណាម។ នៅពេលមួយប្រហែលជានៅក្នុង<>ឆ្នាំ១៩៧៧។ តើលោកនៅចាំហេតុ-ការណ៍ហ្នឹងឬទេ?

**ឆ៖** បាទ ចាំបាន។ កាលហ្នឹងមាន១៨នាក់ បានរត់ចេញពីមន្ទីរ ក-១៦ ប៉ុន្តែខ្ញុំបាទអត់ចាំថ្ងៃខែឆ្នាំទេបាទ ចាំតែឆ្នាំ១៧៧ ពាក់កណ្តាលឆ្នាំ៧៧ ហ្នឹង ចុង៧៧ហ្នឹង បាទ ប្រហែលជាក្នុងខែ៧ ឬក៏ខែ៨។

**ស៖** តើលោកដឹងដែរឬទេ មូលហេតុអ្វីបានជាមនុស្ស<ប្រុស>មួយក្រុម១៨នាក់នេះបានព្យាយាមរត់គេច ខ្លួនទៅប្រទេសវៀតណាម?

**ឆ៖** បាទ សូមជម្រាបថា មនុស្សទាំងនេះគឺមានការពាក់ព័ន្ធនឹងរឿង កាស៊ី គេសម្លាប់។ កាស៊ីគេសម្លាប់ ព្រោះគាត់ជាបក្ខជន ដោយ កាស៊ី អ្នកយកគាត់ បញ្ចូលគាត់ ចូលក្នុងគណបក្ស។ គាត់ឃើញគេសម្លាប់ កាស៊ី គាត់ប្រហែលជាភ័យ គាត់ព្រមបបួលកូនចៅរត់ ដើម្បីភៀស -- ដើម្បីគេចខ្លួន បាទ។

**ស៖** តើលោកនៅចាំឈ្មោះមនុស្សខ្លះទេ នៅក្នុងចំណោមមនុស្ស<ប្រុស>១៨នាក់ ដែល<> បានគេចខ្លួន ដោយសារមានបញ្ហាកើតឡើងចំពោះលោក កាស៊ី នោះ? នៅចាំឈ្មោះអ្នកទាំងហ្នឹងខ្លះទេ?

[១១:១២:០៦]

**ឆ៖** បាទ នៅចាំខ្លះដែរ។ កាលនោះមានឈ្មោះ សៀន គេហៅ ញ៉ុន, ឈ្មោះ ឡាំ, ឈ្មោះ ឡាន ឈ្មោះ ខ្លា, ឈ្មោះ ប៊ុននឿន ហើយក្នុងហ្នឹងមានពូខ្ញុំម្នាក់ដែរឈ្មោះ វុន ក្រៅពីហ្នឹងកូនចៅមួយចំនួនខ្ញុំភ្លេចខ្លះទៅហើយ អត់ចាំឈ្មោះដែរ។

**ស៖** តើ នឿន ហ្នឹងជាអ្នកណា? គាត់មានតំណែងជាអ្វី?

**ឆ៖** ប៊ុននឿន ជាជនជាតិម្នាក់នៅស្រុកកែវសីមាទេ ហើយគាត់ជាមេក្រុម បាទ។

**ស៖** ប្រហែលជាខ្ញុំអានមិនត្រូវ។ ខ្ញុំមិនយោងទៅលើ<>ប៊ុននឿន ទេ ខ្ញុំ<និយាយសំដៅ> ឈ្មោះម្នាក់ទៀតឈ្មោះ នុន ជាប្រធានមន្ទីរដែលគ្រប់គ្រងបុរស១៨នាក់ដែលរត់គេចខ្លួន។ ចុះប្រធាននៃក្រុមមនុស្ស ១៨ នាក់<ដែលរត់គេចខ្លួន>នោះ គាត់ឈ្មោះអី? ខ្ញុំចង់សួរលោកអ៊ីចេះវិញ?

**ឆ៖** បាទ លោក អាដែងហៅឈ្មោះខុសហើយ ឈ្មោះពិតប្រាកដហ្នឹងឈ្មោះ ញ៉ុន មិនមែន នុន ទេបាទ ញ៉ុន។ គាត់ជាប្រធានមន្ទីរ ក-១៦ ហើយក៏គាត់ជាប្រធានក្រុមអ្នករត់ នាំគ្នារត់ហ្នឹងដែរបាទ។

**ស៖** សូមអរគុណ។ ខ្ញុំអានមិនត្រូវឈ្មោះ ញ៉ុន នេះទេ ជាភាសាខ្មែរ។ ចុះមនុស្សម្នាក់ឈ្មោះ ឡាំ តើ ឡាំ នេះអ្នកណា? <>

**ឆ៖** បាទ ឡាំ កាលហ្នឹងគាត់ជាយុទ្ធជនធម្មតាទេ គាត់ដូចអត់មានតំណែងអីផង ប៉ុន្តែគាត់គ្រាន់នៅក្នុងក្រុមហ្នឹងទាំងអស់។

**ស៖** តើលោកដឹកទេគឺថា ឡាំ នៅរស់ទេ បន្ទាប់ពីរត់គេចខ្លួន? ហើយគាត់បានត្រឡប់មកប្រទេសកម្ពុជាក្រោយពីរបៀបកម្ពុជាប្រជាធិបតេយ្យហ្នឹងបានរលំទៅ។ តើលោកដឹងថាអ៊ីចឹងទេ?

**ឆ៖** បាទ គាត់នៅរស់ទាល់សព្វថ្ងៃហ្នឹង បាទ។

[១១:១៥:០០]

**ស៖** ខ្ញុំចង់អានជូនលោកនូវសេចក្តីដកស្រង់មួយ អំពីកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់មនុស្សម្នាក់ឈ្មោះ ឡាំ គឺឯកសារ E3/5221 <>, ខ្មែរ ERN <00236701>, អង់គ្លេស 00239491, បារាំង 00267790។ នេះជាអ្វីដែល ឡាំ បានរៀបរាប់អំពីហេតុការណ៍នេះ សូមដកស្រង់៖ "នៅឆ្នាំ១៩៧៧ ប្រធានរបស់ខ្ញុំ ឈ្មោះ ញ៉ុន បានចូលរួមកិច្ចប្រជុំមួយ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយលេខាតំបន់បានប្រាប់គាត់ថា មនុស្សនៅកែវសីមា គឺជាជនក្បាលយួនខ្លួនខ្មែរ ហើយក៏បានក្បត់អង្គការ។ ដូច្នោះ ញុន បានត្រឡប់មកប្រាប់កម្មាភិបាលក្រោមបង្គាប់ ដើម្បីរត់គេចខ្លួនទៅវៀតណាម ពីព្រោះខ្លាចគេសម្លាប់។ អ្នកទាំងអស់នោះដែលរត់គេចខ្លួនជាមួយ ញុន រាប់ទាំងខ្ញុំ ឡាំង ហើយនិងមនុស្សមួយចំនួនទៀត។ អ្នកដែលរត់គេចខ្លួនជាមួយខ្ញុំ ដែលរាប់ទាំងក្មេងៗមួយចំនួនផង ក៏បានវង្វេងនៅក្នុងព្រៃ ហើយបានត្រឡប់មកភូមិកន្លែងវិញ ក្រោយមក គឺត្រូវបានគេចាប់ខ្លួន ហើយយកទៅសម្លាប់ដោយអង្គការ។" ចប់សេចក្តីដកស្រង់។

ឡាំ បាននិយាយថា មានកិច្ចប្រជុំមួយដោយនៅក្នុងកិច្ចប្រជុំនោះ លេខាតំបន់ថា មនុស្សទាំងអស់នៅក្នុងស្រុកកែវសីមា គឺជាមនុស្សក្បាលយួនខ្លួនខ្មែរ។ តើលោកសាក្សីខ្លួនឯង លោកធ្លាប់បានឮពីអង្គប្រជុំមួយនោះដែរឬទេ?

**ឆ៖** បាទ ការដែលប្រជុំ តាមតែធ្លាប់ឮ គេមិនដែលបង្ហើបឱ្យយើងដឹងថា គេចោទថា យួនខ្លួនខ្មែរទេ ប៉ុន្តែជាពាក្យចចាមអារ៉ាមទៅក្រៅ មាន បាទ។

**ស៖** ខ្ញុំចង់សួរលោកអំពីប្រពន្ធៗរបស់ក្រុមមនុស្ស<ប្រុសៗ>១៨នាក់<ដែលបានរត់គេចខ្លួននោះ>។ តើប្រពន្ធរបស់ពួកគេទៅជាមួយទេ ឬក៏ពួកគាត់នៅតំបន់១០៥ដដែលទេ ពេលដែលប្តីៗរបស់ពួកគាត់បានរត់គេចខ្លួននោះ?

**ឆ៖** បាទ បើតាមខ្ញុំដឹង ពេលដែលប្តីគាត់រត់ទៅហ្នឹង ស្អែកឡើង ឃើញគេចាប់ប្រពន្ធកូនហ្នឹងយកទៅអស់ហើយ គេអត់ទុកទេ។

[១១:១៨:២១]

**ស៖** តើលោកដឹងដែរឬទេថា ប្រពន្ធៗ និងកូនៗ ត្រូវគេចោទថាប្រព្រឹត្តកំហុសអ្វីដែរឬទេ ឬក៏គេចាប់ពួកអ្នកទាំងនោះដោយមូលហេតុថា ប្តីៗ ឬក៏ឪពុករបស់គេបានរត់គេចខ្លួន?

**ឆ៖** បាទ អត់បានដឹងដែរ ព្រោះគេចាប់យកទៅប្រហែលជាតាមការស្មានរបស់ខ្ញុំតែប៉ុណ្ណឹង ថា គេចាប់នេះ គឺដោយសារតែប្តី និងឪពុករបស់គេរត់ទៅយួន។ អ៊ីចឹងបានគេចាប់ទៅនោះ។ ម្យ៉ាង ខ្ញុំក៏អត់បានឃើញក្នុងពេលដែលគេចាប់ដែរ ព្រោះហេតុការណ៍នេះ ខ្ញុំបានចេញពី ក-១៦ ខ្ញុំទៅនៅរយ៉បាត់ហើយ បាទ។

**ស៖** តើលោកបានដឹងពីហេតុការណ៍ហ្នឹងដោយរបៀបណា?

**ឆ៖** បាទ ធម្មតាមន្ទីរពី ក-១៦ មកមន្ទីរក្នុងតំបន់ហ្នឹង ជុំវិញតំបន់ ទាំងពីកន្លែងខ្ញុំនៅរយ៉ហ្នឹង

ដូចថា បើមានការ ហេតុការណ៍អី ក៏គេមកប្រាប់យើង ឬក៏គេប្រកាសប្រាប់ទូទៅតែអ៊ីចឹង។ អ៊ីចឹងអាចដឹងតាមរយៈដែលប្រកាសប្រាប់ហើយ។

**ស៖** តើលោកនៅចាំឈ្មោះប្រពន្ធរបស់បុរសទាំងឡាយដែលបានរត់គេចខ្លួនទៅវៀតណាមទេ? ប្រពន្ធរបស់ពួកគាត់នោះមានឈ្មោះអ្វីខ្លះ តាមដែលលោកចាំនោះ?

**ឆ៖** បាទ ចាំបានពីរ បីនាក់ដែរ។ ឈ្មោះប្រពន្ធញ៉ុន ឈ្មោះ គឹម ហ៊ីន។ គឹម ហ៊ីន នេះបានរកឃើញនូវឯកសារនៅគុកទួលស្លែង បាទ។ ហើយប្រពន្ធ ញ៉ុន នេះ ឈ្មោះ គឹម ហ៊ីន, ប្រពន្ធឡាំ ឈ្មោះ លី, ប្រពន្ធឡាន ឈ្មោះ ហឿន។ និងចំពោះប្រពន្ធ ប៊ុននឿន ឈ្មោះ ហន។ ហើយក្រៅពីហ្នឹង ខ្ញុំអត់ចាំដែរទេបាទ សូមអស់។

[១១:២០:៥៥]

**ស៖** តើលោកដឹងឬទេមានអ្វីកើតឡើងចំពោះប្រពន្ធៗ និងកូនៗរបស់បុរសទាំងអស់នោះក្រោយពីគេចាប់ខ្លួនពួកគាត់ទៅ តើជោគវាសនារបស់គាត់ដូចម្ដេច?

**ឆ៖** បាទ ប្រហែលជាអត់ឃើញទាល់វាល់ថ្ងៃ។ បាត់រហូត ប្រហែលជាគាត់មិនដឹងយ៉ាងណាទេ បើសិនជាគាត់រស់ ប្រហែលជាឃើញមុខហើយ ឬមួយក៏គេយកមកគុកទួលស្លែង ឬមួយក៏គេសម្លាប់តាមផ្លូវអស់ អត់ដឹង។ សូមអស់។

**លោក ឌេល លីសាក់៖**

លោកប្រធាន សូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំចង់ផ្ដល់ឯកសារមួយជូនទៅសាក្សីដើម្បីពិនិត្យមើល។ ឯកសារ E3/1645 – E3/1645 ជាបញ្ជីដែលមានអ្នកទោសច្រើនជាង<១៤០>មកពីមណ្ឌលគិរី <តំបន់១០៥> គឺមកកងពល<៩២០> បាទ ដែល<បានចូលទៅ>ដល់<ស-២១> គឺថ្ងៃទី<២៣> ខែវិច្ឆិកា ឆ្នាំ១៩៧៧ បាទ ហើយខ្ញុំ<នឹងសួរសាក្សីរូបនេះ អំពីឈ្មោះមនុស្សមួយចំនួននៅក្នុងបញ្ជីនេះ។> សូមអនុញ្ញាតតុលាការផ្ដល់ជូនឯកសារ<>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

**លោក ឌេល លីសាក់៖**

លោកសាក្សី ខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ចំណុចមួយចំនួន<នៃ>បញ្ជីអ្នកទោសស-២១។ ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានបិទចំណាំ គឺថាទំព័រ២ ដែលខ្ញុំចង់ឲ្យលោកផ្តោតអារម្មណ៍លើចំណុចទាំងនោះ ជាពិសេសទៅចំពោះអ្នកទោសដែលមានឈ្មោះ និងលេខ១០៦ ដល់១០៩, ១៣០ <និង> ១៣៥ ដល់១៣៨, ១៤០ <និង> ១៤២ <ដល់> ១៤៣។ ដើម្បីឲ្យលោកងាយស្រួល ឈ្មោះ<ទាំងអស់នោះ>ខ្ញុំបានគូសជាពណ៌លឿង <> សូមឲ្យលោកមើលឈ្មោះទាំងនោះនៅទំព័រដែលខ្ញុំបានសម្គាល់នោះ ឈ្មោះដែលខ្ញុំគូសសញ្ញាពណ៌លឿងហ្នឹង គឺសរុបទៅមាននារី១២នាក់ សូមឲ្យលោកជម្រាបតុលាការ តើលោកស្គាល់ឈ្មោះណាមួយខ្លះ ក្នុងករណីដែលលោកស្គាល់ថាតើ<ស្ត្រី>ទាំងនោះ<ជាអ្នកណា>?

*(សាក្សីអានឯកសារ)*

[១១:២៥:១៤]

**ឆ៖** សូមជម្រាបថា ក្នុងនេះមើលមួយគ្រួសអ៊ីចឹងដូចអត់ស្គាល់ទេបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំប្រាប់លោកពីមនុស្សមួយចំនួននៅក្នុងបញ្ជីនេះ។ ឥឡូវនេះគឺចាប់ផ្តើមពីលេខរៀង ១៣០ គឺជាស្ត្រីម្នាក់ដែលឈ្មោះ សេង ព្រីន ហៅ គឹម ហ៊ីន។ គេកំណត់ថាជាប្រពន្ធរបស់បាទឈ្មោះ <ស្រីស ញ៉ុន>។ លោកបានបញ្ជាក់<>ពីខាងដើម ពីរបីនាទីមុន <អំពី>នារី<ម្នាក់>ដែលរៀប<ជាមួយញ៉ុន> នោះ ឈ្មោះថា គឹម ហ៊ីន តើលោក<អាច>ប្រាប់តុលាការ<បានទេ> ថាតើមនុស្សដែលមាន<លេខ> ១៣០ហ្នឹង តើគាត់ជាប្រពន្ធរបស់ ញ៉ុន ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប! អញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះ។ <> ដោយសង្កេតឃើញថាពាក់ព័ន្ធទៅ<នឹងការ>កត់សម្គាល់<ពីខាងដើម និងសំណួរអំពី>ឯកសារនេះ គឺសហព្រះរាជអាជ្ញា<មិន>បាន<បង្ហាញឯកសារទេ។> <>អ្នកទោសនារី<ទាំងអស់>ដែលបញ្ជាក់ក្នុងបញ្ជីនេះ គឺ<ដំបូងបង្អស់ហើយ ដែល>យោងទៅ<ដល់យុទ្ធនារី មិនថាយុទ្ធនារី>មកពី ក-១៦ ឬ ក-១១ ហើយ<និងយោងផងដែរថា>ជាប្រពន្ធរបស់<អ្នកទាំងនោះ>។ <ប៉ុន្តែការបង្ហាញភ័ស្តុតាងថា ពួកគេត្រូវបានកំណត់ត្រឹមតែថា>ជាប្រពន្ធរបស់អ្នកទាំងអស់នោះ <គឺមិនគ្រប់គ្រាន់ទេ។ ជាបឋមនោះ ត្រូវតែកំណត់ថាពួកគេ>ជា <យុទ្ធនារីសិន>។

**លោក ឌេល លីសាក់៖**

ខ្ញុំក៏ចង់សួរឲ្យសាក្សីហ្នឹងបញ្ជាក់ ថាតើអ្នកណាខ្លះមកពីមន្ទីរ ក-១៦? ហើយក៏ចង់ឲ្យគាត់បញ្ជាក់អត្តសញ្ញាណពីឈ្មោះ ហើយក៏ជាប្រពន្ធរបស់អ្នកណា? អ៊ីចឹងខ្ញុំសួរ<សំណួរដំបូង>ទៅសាក្សីថា មនុស្សនៅលេខរៀង១៣០ តើគាត់ជាប្រពន្ធរបស់ ញ៉ុន ដែរឬទេ? ដែលលោកនិយាយថា ញ៉ុន គឺជាប្រធានមន្ទីរ ក-១៦ <និងជាមេក្រុមមនុស្ស១៨នាក់>ដែលបានរត់គេចខ្លួនទៅវៀតណាមនោះ?

[១១:២៨:១៧]

**ប្រធានអង្គជំនុំ៖**

លោកៗមើលលេខរៀង! មើលឈ្មោះលេខរៀង១៣០។ មេធាវីប្រឹក្សាសាក្សីអាចចង្អុលជួយគាត់ ចង្អុលបង្ហាញលើ១៣០ ហើយគាត់ពិនិត្យមើលតាមខ្ទង់ហ្នឹងទៅ តាមតារាង១៣០ តាំងពីដើមដល់ចប់ទៅ លោកអាចឆ្លើយតបហ្នឹងសំណួរនេះបានដែរឬទេ ស្គាល់ទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ សូមជម្រាប ឈ្មោះ គឹម ហ៊ីន នេះ ខ្ញុំអត់បានដឹងឈ្មោះដើមគាត់ទេ។ ប៉ុន្តែគេដាក់ឈ្មោះគាត់នៅក្នុងកាលដែល គាត់រត់ -- ប្តីគាត់រត់នេះ គាត់ឈ្មោះ គឹម ហ៊ីន។ គឹម ហ៊ីន គឺគាត់ជាប្រពន្ធរបស់ ញ៉ុន គាត់មានកូនមួយនាក់ កូនប្រុស នៅពេលចាប់ខ្លួនទៅហ្នឹង ខ្ញុំបាទអត់នៅកន្លែងហ្នឹងទេបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយប្រពន្ធរបស់បុរស១៨នាក់ដែលរត់គេចខ្លួន តើពួកគេធ្វើការនៅ ក-១៦ ដែរឬទេ? <>

**ឆ៖** បាទ ពួកគេនៅ ក-១៦ ជាបុគ្គលិករបស់មន្ទីរតែប៉ុណ្ណឹងបាទ។ គេធ្វើការតាមឋានៈរបស់គេ ជាយុវជនធម្មតាបាទ ជាបុគ្គលិកធម្មតាបាទ។ ដោយឡែក គឹម ហ៊ីន នេះ គាត់ជាមេក្រុមរបស់ស្រីៗទាំងអស់នេះបាទ។

[១១:៣០:០០]

**ស៖** ពេលដែលខ្ញុំសួរលោក ឲ្យលោក<>ប្រាប់ឈ្មោះ<>ប្រពន្ធរបស់អ្នកទាំងនោះ ហើយលោកនិយាយអំពីប្រពន្ធរបស់ឡាំ ឈ្មោះថា លី។ សុំឲ្យលោកមើល<លេខ>១៤២ នៅក្នុងបញ្ជី <គឺមានស្ត្រីម្នាក់>គេហៅថា ឈ្មោះថា ស្រ៊ុន លី ហើយនៅក្នុងសេចក្តីពន្យល់នោះ គឺថា ប្រពន្ធរបស់ឡាំ។ តើនេះជាមនុស្សម្នាក់ដែលលោកជម្រាបតុលាការពីខាងដើមថា <>ជាប្រពន្ធរបស់ឡាំ ដែលប្តីរបស់

គាត់ ឡាំ ហ្នឹង រត់ទៅប្រទេសវៀតណាម។ តើម្នាក់ហ្នឹងមែនឬទេ?

**ឆ៖** បាទ មែន បាទ។

**ស៖** លោកបាននិយាយពីនារីម្នាក់ឈ្មោះ ហឿន ដែល<រៀបការជាមួយ ឡាង> សូមលោក <មើលទៅលេខ១០៦ នៅក្នុងបញ្ជី> នៅទំព័រពីខាងដើម<>១០៦ <គឺស្ត្រីម្នាក់>ឈ្មោះថា ញឹង ហឿន ដែលជាប្រពន្ធរបស់ <ឡាង> តើជាមនុស្សដដែលដែលលោកប្រាប់តុលាការពីខាងដើម គឺថាគាត់ជាប្រពន្ធរបស់បុរសម្នាក់ក្នុងចំណោម១៨នាក់ដែលរត់ទៅវៀតណាម។ តើឈ្មោះហ្នឹងមែនឬទេ?

**ឆ៖** បាទ មែន បាទ។

**ស៖** តើលោកបានឮពីអ្វីៗដែរទេថា ហេតុអ្វីបានជាប្រពន្ធរបស់អ្នកទាំងអស់នេះ ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅស-២១ នោះ? តើលោកបានឮអ្វី <>ពីមូលហេតុហ្នឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់នឹងសំណួរនេះ។ ដូចដែលខ្ញុំជំទាស់ពីខាងដើមដែរ។ <ជាការពិត គ្រាន់តែនិយាយថា ពួកគេជាប្រពន្ធរបស់អ្នកទាំងនោះ។ ជាបឋមត្រូវតែយោងថា ពួកគេជាយុទ្ធនារីសិន។ ក្នុងការនិយាយថា ពួកគេត្រូវបានចាប់ខ្លួន ដោយសារតែពួកគេ>ជាប្រពន្ធរបស់អ្នកហ្នឹង <គឺយើងយកឯកសារនេះទៅចាប់ផ្តើមពីចំណុចដំបូងមកហើយ។ ការធ្វើដូច្នេះមិនត្រឹមត្រូវ>ទេ។ <វាហាក់ដូចជាថា ពួកគេត្រូវបានចាប់ខ្លួន> ព្រោះពួកគាត់ហ្នឹងជាយុទ្ធនារី <ធ្វើការជាយុទ្ធនារីនៅក្នុងមន្ទីរជាក់លាក់។ ហើយការបន្តនិយាយថា ពួកគេត្រូវបានចាប់ខ្លួន ព្រោះពួកគេជាប្រពន្ធអ្នកទាំងអស់នោះ គឺមិនត្រឹមត្រូវទេ។ ខ្ញុំសូមជំទាស់>។

**លោក ឌេល លីសាក់៖**

មេធាវីហាក់ដូចជាព្យាយាមបង្ហាញភស្តុតាងដោយខ្លួនឯង មិនត្រឹមត្រូវទេ លោកប្រធាន។

[១១:៣៣:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីបំពេញបន្ថែមទៅនឹងការដែលគេជំទាស់<>លោកមេធាវី កូប៉េ ប៉ុន្មាននាទីមុននេះ សហព្រះរាជអាជ្ញាក៏បានសួរ<>សំណួរអ៊ីចឹងដែរ ទៅនឹងសាក្សី ហើយគាត់បានឆ្លើយហើយថា គាត់មិនដឹង

ទេ ថាហេតុអ្វីបានជាគេចាប់ខ្លួនប្រពន្ធរបស់បុរសទាំងនោះ <ហើយគាត់ក៏បាននិយាយរួចហើយពីខាងដើមនោះ។> គាត់ថា <គាត់អាច>ទាញការសន្និដ្ឋាន<បាន> ប៉ុន្តែខ្លួនគាត់ ក៏គាត់<មិនដឹងដែរថាហេតុអ្វីបានជាប្រពន្ធរបស់បុរសទាំងនោះត្រូវបានចាប់ខ្លួននោះ>។

**លោក ខេល លីសាក់៖**

លោកប្រធានសុំអនុញ្ញាតសួរសំណួរឡើងវិញ។ សុំ<សួរសំណួរ>ចុង<ក្រោយរបស់ខ្ញុំមុនពេលសម្រាក>។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** <>លោកសាក្សី ខ្ញុំពិនិត្យមើលអ្វីដែលលោកបាននិយាយនៅក្នុងបទសម្ភាសន៍ E3/5636 – E3/5636, ខ្មែរ 00042484, អង់គ្លេស 00711224, បារាំង 00727140 លោកបាននិយាយនៅទីនេះ ពីការចាប់ខ្លួនប្រពន្ធរបស់ ញុន។ "សំណួរ៖ តើ <គឹម ហ៊ីន> ហ្នឹងត្រូវបានចាប់ខ្លួនដោយហេតុតែប្តីរបស់គាត់ ឬដូចម្តេច? ចម្លើយ៖ គាត់មិនបានខុសអីទេ គេចាប់ខ្លួនគាត់ដោយហេតុថា ប្តីរបស់គាត់តែប៉ុណ្ណោះ។ ហើយប្រពន្ធៗរបស់ប្តីដែលគេរត់ទៅវៀតណាមហ្នឹង ត្រូវបានគេចាប់ខ្លួនទាំងខ្សែ។" ចប់សេចក្តីដកស្រង់។ លោកសាក្សី តើលោកចង់មានន័យដូចម្តេចនៅពេលលោកប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺថា ខ្សែ<ខាង>ប្រពន្ធៗរបស់អ្នករត់ទៅវៀតណាម ត្រូវគេបានចាប់ខ្លួនហ្នឹង <>តើលោកចង់សំដៅអត្ថន័យដូចម្តេច?

[១១:៣៥:០០]

**ឆ៖** បាទ រឿងនេះ ខ្ញុំបានជម្រាបរួចហើយថា ខ្ញុំអត់យល់ ព្រោះធម្មតាជំនាន់នុ៎ងបើសិនជាគេមានប្តីក្បត់អីចឹងគេមិនទុកប្រពន្ធ ឬកូន ឬក្រុមគ្រួសារ ឪពុកម្តាយទេបាទ គេសម្លាប់តាមរយៈហ្នឹងហើយ។ ដូច្នេះ ដែលខ្ញុំលើកឡើងនេះ លោកសួរអំមិញ ខ្ញុំដូចជាអត់យល់ ព្រោះថារបបខ្មែរក្រហមតែសម្លាប់ឪពុកហើយ ត្រូវសម្លាប់កូន សម្លាប់ប្រពន្ធទៅ។ ដល់ពេលលោកសួរអំមិញ ខ្ញុំអត់យល់ៗបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ បាទ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់

កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ -- នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៦ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួលោកសាក្សី។ យើងបានពិភាក្សាអំពីស្ត្រីមួយចំនួនដែលនៅមន្ទីរក-១៦ ដែលពួកគាត់ជាប្រពន្ធរបស់បុរសមួយចំនួនដែលរត់គេចខ្លួនទៅវៀតណាម ហើយក្រោយមកគេចាប់ពួកនារីទាំងនោះមកស-២១។ ហើយខ្ញុំក៏ចង់ដឹងអំពីកូនៗរបស់ពួកគាត់ដែលត្រូវគេចាប់ខ្លួន។ តើ ញុន ហើយ និងប្រពន្ធរបស់គាត់ គឹម ហ៊ីន ហ្នឹងមានកូនដែរឬទេ? ហើយតើ<>គេចាប់កូនរបស់គាត់ដែរទេ ពេលដែលគាត់បានរត់ទៅវៀតណាម<>នោះ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ គេចាប់ទាំងកូន បាទ។

**ស៖** នៅក្នុងបទសម្ភាសន៍ ឌី.ស៊ី.ខេម នោះគឺថា ឯកសារ <E3/5636> ខ្មែរ 00042484, អង់គ្លេស 00711225, បារាំង 00727141។ លោកបាននិយាយថា សូមដកស្រង់៖ "នៅពេលដែល គឹម ហ៊ីន ត្រូវបានចាប់ខ្លួន គាត់មានកូន<ម្នាក់>។ គេបានចាប់ខ្លួនគាត់ជាមួយនឹងកូនតូចមួយ។" សូមចប់សេចក្តីដកស្រង់។ គឺនៅក្នុងឯកសារ E3/5636។ តើលោកដឹងដូចម្តេចថា គេចាប់ខ្លួន <គឹម> ហ៊ីន នេះ

ជាមួយនឹងកូនតូចមួយផងនោះ?

**ឆ៖** បាទ ពេលនុ៎ង បើតាមខ្ញុំចំណាំ ខ្ញុំអត់បាននៅទីនោះទេ ព្រោះនៅរយ៉ៈនេះ។ ពេលគេទៅចាប់ពួកគាត់ហ្នឹង គឺគេទៅចាប់នៅក-១៦ទេ។ អ៊ីចឹងដល់ពេលចាប់បោសសម្អាតដល់ចុងក្រោយមក ដឹងថាគេយកទាំងកូនទៅតែម្ដង។ អ៊ីចឹងខ្ញុំអត់បានលម្អិតទេ បាទ សូមទោស។

[១៣:៣៦:៥៥]

**ស៖** តើលោកនៅចាំទេ អ្នកណាដែលប្រាប់រឿងនេះទៅលោក?

**ឆ៖** បាទ ពេលគេចាប់ពួកគាត់ទៅហ្នឹង គឺប្រធានមន្ទីរនីមួយៗតែងតែធ្វើមីទ្ទិងប្រជុំ ហើយប្រកាស។ អ៊ីចឹងដឹងតាមៗរយៈប្រធានមន្ទីរប្រកាសហ្នឹងឯង។

**ស៖** លោកបាននិយាយអំពី ការប្រកាស<មួយចំនួន>របស់<>ប្រធានការដ្ឋានរយ៉ <នៅក្នុងកិច្ចសម្ភាសន៍របស់លោក ក្រោយពេលព្រឹត្តិការណ៍ទាំងអស់នេះកើតឡើង ដូចជា >បន្ទាប់ពីឪពុកមារបស់ខ្លួនត្រូវបានគេចាប់ខ្លួនហើយ បន្ទាប់មកគឺអ្នកមួយចំនួនបានរត់ទៅវៀតណាម ហើយបន្ទាប់ពីមានការ<ស្លាប់របស់ ឡាំង និង ខាំ ភូន> ថាតើមាន<ការចាប់ខ្លួនមនុស្ស>នៅការដ្ឋានរយ៉<ទេ> បន្ទាប់<ពីមានព្រឹត្តិការណ៍ទាំងនេះ>មកនោះ?

**ឆ៖** បាទ ពេល ញូន រត់ហ្នឹងគឺខាងរយ៉ ខាងគ្រប់អង្គភាព មិនមែនតែចំពោះតែរយ៉ទេ គេមានការជ្រួលច្របល់ ហើយមានគេពង្រាយកម្លាំងទ័ពឲ្យទៅប្រចាំការគ្រប់មន្ទីរហ្នឹង ដើម្បីការពារពួកយើងអត់បានដឹងអីហ្នឹង។ ហើយពេលនោះ ពេលយប់ ពេលថ្ងៃធ្វើការហ្នឹងសុទ្ធតែមានទាហានយាមហើយបាទ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ<របស់លោក ដោយ>ការិយាល័យសហចៅក្រមស៊ើបអង្កេតឯកសារ E3/5178, ខ្មែរ <00197865>, អង់គ្លេស 00274103, បារាំង 00485189។ <> លោកបានឆ្លើយថា សូមដកស្រង់៖ “មនុស្សប្រាំមួយនាក់ត្រូវបានចាប់ខ្លួននៅការដ្ឋានរយ៉ បន្ទាប់ពីហេតុការណ៍ របស់ <ស្វាយ និង> កាស៊ី<>កើតឡើង <មនុស្សជាង៣០នាក់>នៅក្នុងខ្សែរបស់ ចាន់ ថន <ត្រូវបានចាប់ខ្លួន>នៅក្នុងការដ្ឋានរយ៉ បន្ទាប់ពីមានហេតុការណ៍ការ ខាំ ភូន។” សូមលោករៀបរាប់ជម្រាបតុលាការថា តើ<>អ្នកណាជាអ្នកចាប់ខ្លួន<អ្នកទាំងនេះក្រោយព្រឹត្តិការណ៍នោះ>? <>ហើយគេចាប់ខ្លួនមនុស្សនៅការដ្ឋានរយ៉ហ្នឹង ចាប់ដោយរបៀបណា?

[១៣:៤០:០០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំជម្រាប។ ការដែលចាប់ខ្លួននៅរយ៉លើកដំបូង កាលដែលមានឧប្បត្តិហេតុ ស្វាយបានបាញ់កម្មាភិបាលស្លាប់ពីរនាក់។ ស្វាយ ជាលេខាស្រុកកោះញែក។ ពេលនោះ កាស៊ី មិនទាន់គេចាប់ទេ ហើយក៏បានដេញប្រតាប់ប្រតាយទៅក៏ ស្វាយ រត់ខ្លួន រត់រួច គេចខ្លួនរួច។ ចុងក្រោយ ស្វាយ បានទៅបាញ់មនុស្សម្នាក់ដែលជាអ្នកកាន់ម៉ាស៊ីនភ្លើងខាងពេទ្យទេ ខាងពេទ្យតំបន់ បាញ់អត់ត្រូវ ដល់គាត់បាញ់វិញទៅត្រូវពោះវៀន ធ្លាយពោះវៀនក៏ទៅចងកស្លាប់ទៅ។ ពេលនោះ កាស៊ី ក៏ត្រូវគេចាប់ អ៊ីចឹងអ្នកមួយចំនួនហ្នឹងក៏គេចាប់ បាទ ហើយនៅមន្ទីររយ៉កន្លែងខ្ញុំនៅហ្នឹង គេបានចាប់មួយថ្ងៃហ្នឹងប្រាំប្រាំមួយនាក់ហ្នឹងត្រឹមត្រូវ។ ក្នុងនោះមានឈ្មោះ ចៀន, ឈ្មោះ មឿន, សួង, ឈ្មោះ ភីន និងឈ្មោះ យ៉ន, ឈ្មោះផាន។ បាទខ្លះខ្ញុំអត់សូវចាំដែរបាទ ខ្ញុំរៀងភ្លេចដែរ។

**ស៖** ដើម្បីឲ្យយើងប្រាកដថាខ្ញុំសួរលោកអំពីមនុស្សដែលត្រូវបានគេចាប់ខ្លួនការដ្ឋានរយ៉។ តើមនុស្សទាំងអស់ដែលលោករៀបរាប់នេះ<ត្រូវ>គេចាប់ខ្លួននៅៗ<ការដ្ឋានរបស់លោកឬ?> តើអ្នកណាជាអ្នកមកចាប់ខ្លួនពួកគេ? <តើមាន>អ្នក<>ណា<ខ្លះ>មក<ការដ្ឋាននោះ ហើយ>ចាប់ខ្លួនអ្នកទាំងហ្នឹង? ហើយគេចាប់ដោយរបៀបណា?

**ឆ៖** បាទ គេមកពីតំបន់ បាទ។ ហើយអ្នកចាប់ហ្នឹងគឺប្អូនឈ្មោះ ហម ហ្នឹងហ្នង ឈ្មោះ អន ស៊ី ហើយនិង សុទ១ ជាប្រធានកម្មករ។ ហើយ អន ស៊ី ហ្នឹងគាត់ពេលដំបូងគាត់ជំនួស កាស៊ី ទៅប្រចាំនៅស្រុកកែវសីមា ជាលេខាស្រុក ក្រោយមកដែលគេរើពីកែវសីមា គាត់មកនៅតំបន់ មិនដឹងជាគាត់មាននាទីអីទេ ខ្ញុំអត់បានចាំទេបាទ។

[១៣:៤៣:០៦]

**ស៖** ខ្ញុំចង់សួរលោកអំពីឯកសារមួយទៀតនៅក្នុង<>ឯកសារភស្តុតាង លោកសាក្សី គឺឯក-សារ E3/156 – E3/156 គឺជាសារទូរលេខមកពីលេខាតំបន់ឈ្មោះ សារុន គឺចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨ "ចម្លងជូន ប៉ុល ពត, នួន ជា និងមន្ទីរ៨៧០ សុំការណែនាំមកពីមេដឹកនាំបក្សក្នុងទីក្រុងភ្នំពេញ" ហើយកថាខណ្ឌទី៣ក្នុងទូរលេខនេះនិយាយថា "សមមិត្តសុទ ប្រធានរោងចក្រជួសជុល បានប្រព្រឹត្ត<ខុស>សីលធម៌ជាមួយស្ត្រីម្នាក់។ ឥឡូវនេះ<>បានចាប់ខ្លួនហើយ បុរស និងស្ត្រីនោះត្រូវបានចាប់ខ្លួន។ សមមិត្តនេះ<ពីមុនមកមានជាប់ពាក់ព័ន្ធនឹង>ចម្លើយសារភាពរបស់ជនក្បត់<>ឈ្មោះ អាជួន។ ហើយនៅពេល<នោះខាងតំបន់នៅ>បានតាមដានពីសកម្មភាព<វាថែមទៀត។> ប៉ុន្តែឥឡូវនេះ <វា> បានពាក់ព័ន្ធនឹងអំពើខុសសីលធម៌ ហើយត្រូវបានចាប់ខ្លួននិងឃុំខ្លួន។ ពាក់ព័ន្ធនឹងបញ្ហានេះ សូមផ្តល់ជា

មតិយោបល់ពី<កម្រិតទុកដាក់ត្រឹមណា ហើយបញ្ជូនទៅណា>។” អ៊ីចឹង ខ្ញុំចង់សួរលោកថា <បុគ្គលដែលជាប្រធានបទរបស់ទូលេខនេះ ផ្ញើចេញពី សារុន ទៅមេដឹកនាំនៅភ្នំពេញ គឺ>សមមិត្ត សុទ ដែលជា<>ប្រធាននៃរោងចក្រជួសជុល តើលោកស្គាល់សមមិត្ត សុទ នេះដែរឬទេ?

**ឆ៖** បាទស្គាល់ ប៉ុន្តែគាត់ជាប្អូនរបស់ សូភា ផ្ទាល់បាទ។

[១៣:៤៥:១៨]

**ស៖** តើគាត់ជាមនុស្សដដែល ដែលលោកនិយាយ<មួយស្របក់មុននោះ>ថា <>ជាប្រធានកម្មករ<នោះ>ឬ<>?

**ឆ៖** មានតែមួយបាទ។

**ស៖** តើលោកបានដឹងទេ សុទ ហ្នឹងក្រោយមកគាត់យ៉ាងម៉េចដែរ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៨? តើគាត់បានរស់រានមានជីវិតពីរបបហ្នឹងដែរឬទេ?

**ឆ៖** បាទ ចាប់តាំងពីហ្នឹងមកអត់ឮគាត់ទេ។ ពីព្រោះគាត់គេចាប់យកទៅបាត់ហើយ អត់ដឹង។

**ស៖** តើលោកនៅចាំដែរឬទេ តើ សុទ ហ្នឹងជាអ្នកស្រុកកំណើតមកពីណា? គាត់នៅមណ្ឌលគិរីដែរឬទេ?

**ឆ៖** គាត់ស្រុកកំណើតជាមួយខ្ញុំបាទ។

**ស៖** <តើ>ខ្ញុំយល់ត្រឹមត្រូវ<ដែរឬទេថា>លោកមិនដែលបានជួប សុទ ជាថ្មីម្តងទៀតទេ ចាប់តាំងពីឆ្នាំ១៩៧៨ មកហ្នឹង គឺមិនដែលឃើញមុខគាត់ទេ ត្រូវទេអ៊ីចឹង?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** សារទូរលេខនេះយោងទៅរកថា សុទ បានទៅប្រព្រឹត្តខុសសីលធម៌ជាមួយស្រីម្នាក់។ តើលោកបានឮអ្វីខ្លះអំពីហេតុការណ៍នេះទេ? តើលោកស្គាល់នារីនោះទេ ដែលថាគេចោទថា សុទ មានខុសសីលធម៌ជាមួយនារីនោះ តើនារីនោះឈ្មោះអ្វី លោកដឹងស្គាល់ទេ?

[១៣:៤៧:២៦]

**ឆ៖** បាទស្គាល់ គាត់ជាអ្នកនៅជាមួយខ្ញុំនៅការដ្ឋានហ្នឹងដែរបាទ គឺឈ្មោះ នី។ ស្រីហ្នឹងឈ្មោះ នី។ គាត់ជា -- ឪពុកម្តាយគាត់ចិន។

**ស៖** សារទូរលេខនេះគឺចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨ និយាយផងដែរថា នារី<នោះ>ក៏ត្រូវបានចាប់ខ្លួនផងដែរ។ តើលោកដឹងទេថា <មានអ្វីកើតឡើងចំពោះ> នី <?> តើក្រោយមកគាត់រស់រាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានជីវិតពីរបបហ្នឹងដែរឬទេ?

**ឆ៖** បាទ ប្រហែលជាអត់ដឹងដែរ ព្រោះតាំងពីហ្នឹងមកបែកគ្នារហូត អត់ចាំ អត់បានដឹង។

**ស៖** បាទ ខ្ញុំបានចម្លើយលោកហើយ។ អ៊ីចឹងខ្ញុំក៏ចង់សួរលោកអំពីបុគ្គលមួយចំនួនដែលធ្វើការនៅមន្ទីរ ក-១៧ ដែលជាមន្ទីររបស់លេខាតំបន់។ តើលោកស្គាល់មនុស្សពីរនាក់មានឈ្មោះថា ធិន ហើយម្នាក់ទៀតឈ្មោះ វឺន – វឺន លុយ <>គាត់<>ធ្វើការនៅ ក-១៧ ហើយ<តើ>លោក<អាច> ប្រាប់តុលាការ<បានទេ>ថាតើ<មានអ្វីកើតឡើងចំពោះ> ធិន ហើយនិង លុយ ហ្នឹង <>ក្នុងរបបខ្មែរក្រហម?

**ឆ៖** បាទ ខ្ញុំស្គាល់ឈ្មោះ ធិន មិនមែនឈ្មោះ ទិន ទេ ឈ្មោះ ធិន – "ធ-ិ-ន" គាត់ឈ្មោះ ធិន មានប្រពន្ធកូនហើយ គាត់ជាប្រធានមន្ទីរ ក-១៧។ ក្រោយមកគាត់ខុសសីលធម៌ដូច សុទ ដែរ ត្រូវបានគេចាប់ខ្លួនយកទៅដាក់នៅការដ្ឋានណងឃើលីក។

**ស៖** តើ ធិន ជាសាច់ញាតិរបស់លោកដែរឬទេ? តើគាត់បានរួចរស់ជីវិតពីរបបហ្នឹងទេ?

**ឆ៖** បាទ រួចរស់ ទើបគាត់ស្លាប់ឆ្នាំទៅនេះឯង បាទ។

**ស៖** ចុះ<ចំពោះ>មនុស្សម្នាក់ <>ដែលមកធ្វើការជំនួស ធិន <ជាប្រធាន>ក-១៧ ដែលលោករៀបរាប់ថា មនុស្សនេះឯង លោកស្គាល់គាត់តាំងពីឆ្នាំ១៩៧០មក។ តើ<អ្វីកើតឡើងចំពោះ> វឺន <ឡាយ ឬ> ឡយ <ខ្ញុំមិនច្បាស់ក្នុងការអានឈ្មោះគាត់ទេ តើមានអ្វីកើតឡើងចំពោះអ្នក>ដែលមកជំនួស ធិន <ដែល>ជាប្រធាន<មន្ទីរ> ក-១៧ <>នេះ?

[១៣:៥១:១៥]

**ឆ៖** បាទ ពេលខ្ញុំមកដេកពេទ្យហ្នឹង ខ្ញុំបានឃើញ តាឡយ ហ្នឹង ទៅយកខ្ញុំនៅរយ៉ ខ្ញុំអត់ដឹងថាគាត់ជា ជំនួស ធិន ទេ។ តែឃើញទៅ គាត់បានប្រាប់ខ្ញុំថា គាត់បានជំនួស តាធិន ហ្នឹងធ្វើជាប្រធានមន្ទីរ ក-១៧ ហ្នឹង។ ហើយពេលហ្នឹង ក-១៧ ក៏មានឈ្មោះ សារុន ដែលជំនួស ហាម តាំងពីហ្នឹងមក។ ដល់ពេលហ្នឹងគាត់ប្រាប់ខ្ញុំ ខ្ញុំបានស្គាល់គាត់។ តែដល់ចុងក្រោយមកទៀត ប្រហែលជាជិតហ្នឹងរំដោះ ៧មករា ហ្នឹង ឮថា តាឡយ ហ្នឹងគេត្រូវចាប់ទៀត។ ប៉ុន្តែខ្ញុំអត់បានដឹងទេ ខ្ញុំបានមកសម្រាកពេទ្យហើយបាទ។

**ស៖** សំណួរ តើលោកធ្លាប់បានជួបឡយ ហ្នឹង តាឡយ ហ្នឹងម្តងទៀតទេ ចាប់តាំងពីឆ្នាំ១៩៧៨មក?

**ឆ៖** អត់ទេ ជួបតែម្ដងដែលគាត់យកឡានដឹកខ្ញុំមកមន្ទីរពេទ្យហ្នឹងបាទ។

**ស៖** លោកប្រធាន គឺថា ដើម្បីកំណត់ត្រានោះគឺថា បញ្ជីឯកសារ<ស-២១ គឺ>E3/2251 ហើយនិង E3/1651 បានកត់ត្រាថា វីន ឡុយ គឺជាប្រធានមន្ទីរ១០៥ គឺថា ចូលស-២១ គឺថ្ងៃទី២០ តុលា ឆ្នាំ១៩៧៨។ ហើយនិង ខ្ញុំនឹងចូលទៅដល់ប្រធានបទចុងក្រោយ។ បាទ ជាបញ្ហាទូទៅដែលខ្ញុំនឹងសួរលោកសាក្សីនៅថ្ងៃនេះ ដែលទាក់ទងទៅនឹងប្រទេសវៀតណាម ហើយនិងជនជាតិវៀតណាម។ ដំបូងសូមឲ្យលោកជម្រាបតុលាការ តើប្រជាជនវៀតណាមមានបញ្ហាអ្វីដែរនៅក្នុងខេត្តមណ្ឌលគិរីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលហៅកាត់ថា "ខ្មែរក្រហម"?

**ឆ៖** បាទ ខ្ញុំមិនច្បាស់ទេ សូមលោកបញ្ជាក់ម្ដងទៀត។ អត់មានទាក់ទងនឹងប្រជាជនវៀតណាមទេបាទ។

[១៣:៥៤:០០]

**ស៖** សំណួររបស់ខ្ញុំគឺថា តើមានជនជាតិវៀតណាម <> ឬក៏ជនជាតិ<ភាគតិច>វៀតណាមរស់នៅក្នុងខេត្តមណ្ឌលគិរីដែរទេ <នៅ>ខែមេសា ឆ្នាំ១៩៧៥មក? បើមានពួកគេរស់នៅ តើមានរឿងអីកើតឡើងចំពោះពួកគេ <នៅក្នុងរបប>នោះ?

**ឆ៖** បាទ បើខ្ញុំចាំមិនភ្លេចទេ គឺជនជាតិវៀតណាមដែលជាជនជាតិភាគតិចនៅមណ្ឌលគិរីនេះ គឺដូចអត់សូវមានទេ មានតិចតួច ប៉ុន្តែប្រហែលជា បើអាចសម្លាប់ៗមុនពេល មុនឆ្នាំ៧៥ បាទ។ ប៉ុន្តែក៏មានតិចតួចបំផុតដែរ។ បើមានប្រហែលជាអត់នៅដែរ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីចូរលោកឆ្លើយតបទៅអ្វីដែលលោកបានដឹង បានឮ បានឃើញ បានធ្វើការកត់សម្គាល់ ឬក៏សង្កេតដោយផ្ទាល់បានហើយ។ អ្វីដែលលោកមិនដឹង គឺកុំលោក កុំឆ្លើយស្មានបាទ វាប្រហែលអីចេះ អីចុះគឺជាការស្មានទេ បាទ។ បើលោកមិនដឹង គឺឆ្លើយថាមិនដឹងទៅវាច្បាស់លាស់ជៀសវាងការខុសកាតព្វកិច្ច ព្រោះកាតព្វកិច្ចករណីយកិច្ចរបស់សាក្សីចំពោះមុខអង្គជំនុំជម្រះត្រូវតែឆ្លើយតែការណ៍ ដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ បានចងចាំ បានកត់សម្គាល់ ឬក៏សង្កេតដោយផ្ទាល់ ពាក់ព័ន្ធនឹងនូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរពីបញ្ហាមួយចំនួនដែលលោកឆ្លើយទៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌល

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឯកសារកម្ពុជាគឺ E3/5636 គឺខ្មែរ ERN 00042474, អង់គ្លេស 00711212, បារាំង <00727131>។ លោកបាននិយាយពីបញ្ហាវត្តមានរបស់ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា ហើយនិងការដកចេញនៅកងទ័ពវៀតណាមចេញពីកម្ពុជានោះ លោកបាននិយាយថា “ខ្មែរក្រហម មិនបញ្ឈប់ត្រឹមហ្នឹងទេ។ នៅក្នុងខេត្តក្រចេះ ពួកគេបានវាយប្រហារ ហើយនិងសម្លាប់ជនជាតិវៀតណាម ១.៨០០<នាក់> នៅក្នុងឃុំពូលូ ដែលចាប់ផ្ដើមមកពីឡូកនិញ”។ តើលោកដឹងដូចម្ដេចអំពីការកាប់សម្លាប់ប្រជាជនវៀតណាម ១.៨០០នាក់ នៅក្នុងឃុំពូលូនេះ<?> តើលោកដឹងដោយរបៀបណា?

[១៣:៥៧:២៦]

**ឆ៖** បាទ ខ្ញុំដឹងក្រោយរំដោះ ១៩៧៩ ទេបាទ។

**ស៖** តើលោកបានដឹងរឿងហ្នឹងពីអ្នកណា?

**ឆ៖** ខ្ញុំបានដឹងពីជំនាញការវៀតណាមដែលប្រចាំ ធ្វើការជាមួយខ្ញុំបាទ។

**ស៖** តើលោកដឹងថាហេតុការណ៍ហ្នឹងកើតឡើងក្នុងឆ្នាំណាដែរឬទេ?

**ឆ៖** តាមដែលខ្ញុំដឹងប្រហែលជាឆ្នាំ -- មិនប្រហែលទេ គឺឆ្នាំ៧៨ ហ្នឹងបាទ។

**ស៖** តើឃុំពូលូនោះ នៅកន្លែងណា នៅក្នុងខេត្តក្រចេះ ឬក៏នៅក្នុងប្រទេសវៀតណាមទេ?

**ឆ៖** ទឹកដីវៀតណាម។

**ស៖** បាទ អ៊ីចឹងត្រឡប់មកខេត្តមណ្ឌលគិរីវិញ។ នៅក្នុងរបបខ្មែរក្រហម តើលោកអាចប្រាប់ខ្ញុំបានទេ ថាមានរឿងអ្វីកើតឡើងចំពោះមនុស្សដែលគេរកឃើញថាមានទំនាក់ទំនងជាមួយវៀតណាម ជាពិសេស ដូចជា អ្នកដែលមានបងប្អូននៅវៀតណាម អ្នកដែលមានទំនាក់ទំនងជាមួយប្រទេសហ្នឹង ឬកម្មាភិបាលដែលគេទទួលការបណ្ដុះបណ្ដាលនៅប្រទេសវៀតណាម។ តើលោកប្រាប់តុលាការបានទេ អ្នកទាំងអស់នោះមានរឿងអ្វីកើតឡើង ឬមានបញ្ហាអ្វីដែរឬទេ នៅក្នុងរបបនោះ?

**ឆ៖** បាទ បើតាមខ្ញុំដឹង អ្នកទៅរៀននៅវៀតណាមភាគខាងជើងហ្នឹង ក្នុងឆ្នាំ១៩៥១នោះ បានវិលត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ១៩៧០។ ពេលនោះ ក៏បានចូលរួមចលនាតស៊ូជាមួយគ្នានឹងខ្មែរក្រហម ហើយ គាត់ក៏មានតួនាទីខ្លះៗក្នុងស្ថាប័ននៅតាមស្រុក តាមខេត្តហ្នឹង។ ឧទាហរណ៍អ្នកជំនាញខាងទាហាន គេឲ្យទៅខាងទាហានទៅ អ្នកជំនាញពេទ្យគេឲ្យធ្វើពេទ្យទៅ អ្នកជំនាញនយោបាយគេឲ្យទៅខាងនយោបាយ។ នៅខេត្តមណ្ឌលគិរីវាមានបីនាក់ទេ គឺមានឈ្មោះ ស៊ីន មួយ, ម៉ាឡា ពីរ និង ភិន មួយ។ អ៊ីចឹង តាភិន គាត់ជំនាញខាងពេទ្យ គាត់បានទៅខាងពេទ្យ, ម៉ាឡា គាត់ខាងនយោបាយ គាត់គេឲ្យធ្វើ

លេខាស្រុកពេជ្រចិន្តាអ៊ីចឹងទៅ ជំនួស តាសារុន នេះ, ដល់ តាស៊ីន គាត់ជំនាញខាងយោធា ខាងកាំភ្លើងធំ គាត់បានទៅខាងនុ៎ង។ ដល់ឆ្នាំ៧៣ នេះពួកគាត់ត្រូវបានបាត់ខ្លួនហើយ។ បាទ ខ្ញុំសូមអស់យោបល់។

[១៤:០១:០៦]

**ស៖** ចំពោះមនុស្សដែលមានបងប្អូនរស់នៅក្នុងប្រទេសវៀតណាមវិញ តើមានហេតុការណ៍អ្វីកើតឡើងចំពោះអ្នកទាំងនោះដែរឬទេ?

**ឆ៖** បាទ អ្នក -- មានបងប្អូននៅវៀតណាម អ្នកខ្លះបានរត់ទៅវៀតណាមនោះ គឺមួយចំនួនបានវិលត្រឡប់មកវិញ ប្រហែលជា៦០នាក់បានមកវិញក្នុងពេលនោះ ដូចអត់មានបញ្ហាអីទេ។ ប៉ុន្តែអ្នកដែលវាយរងរត់ បុគ្គលរត់ម្នាក់ពីរនាក់ អាហ្នឹងដែលគេចាប់បាន គេសម្លាប់ហើយ។

**ស៖** ខ្ញុំចង់សួរលោកអំពីអ្វីដែលលោកឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីប្រធានបទនេះ គឺឯកសារ E3/5178 នៅខ្មែរ ERN 00197857, អង់គ្លេស <00274095> ដល់ 96, បារាំង 00485181។ នេះជាអ្វីដែលលោកបានឆ្លើយ<>ទៅអ្នកស៊ើបអង្កេត៖"ក្រោយមកនៅឆ្នាំ១៩៧៧ ជនរងគ្រោះត្រូវបានគេចោទថាជាអ្នកកាន់ជើងវៀតណាម។ កម្មាភិបាលខ្មែរក្រហមក៏ត្រូវបានគេសម្លាប់ដែរ។ ភាគច្រើននៃអ្នកទាំងនោះត្រូវបានទទួលការអប់រំនៅក្នុងប្រទេសវៀតណាម ហើយគេចោទប្រកាន់អ្នកទាំងនោះថាជាភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ។ ដូច្នេះមានមនុស្សជាច្រើនបានស្លាប់នៅក្នុងខេត្តនេះ។ សាច់ញាតិ ហើយនិងអ្នកដែលជាប់ខ្សែជាមួយ<>កម្មាភិបាលទាំងអស់នោះ ក៏<>ត្រូវបានគេសម្លាប់ដែរ។ បុគ្គលដែលមានបងប្អូនរស់នៅក្នុងប្រទេសវៀតណាមក៏ត្រូវបានគេកាប់សម្លាប់ផងដែរ នៅពេលដែលអង្គការបានដឹង។ ស្រុកកោះញែក ហើយនិងកែវសីមា គឺជាស្រុកដែលជនរងគ្រោះភាគច្រើនត្រូវបានគេសម្លាប់។ ការកាប់សម្លាប់ភាគច្រើនកើតឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ហើយជនរងគ្រោះត្រូវបានគេចោទប្រកាន់ថាជាប់ខ្សែវៀតណាម"។ ចប់សេចក្តីដកស្រង់។

លោកប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា "អ្នកដែលមានបងប្អូនរស់នៅប្រទេសវៀតណាម <នឹងត្រូវបាន>សម្លាប់<> បើអង្គការបានដឹងរឿងហ្នឹង"។ តើលោកដឹងដោយរបៀបណាថាមានរឿងបែបនេះ? ហើយលោកដឹងថាអ្នកណាដែលគេសម្លាប់នៅស្រុកខ្មែរ ព្រោះតែគេមានបងប្អូននៅប្រទេសវៀតណាមនោះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ អ្នកដែលគេសម្លាប់តាមរយៈខ្សែបងប្អូនមាននៅខាងវៀតណាមហ្នឹង គឺខ្សែខាង ខ្សែតាប៊ុន ណេត ហើយខ្សែតានេះ តាយុន អ៊ីចឹងក៏គេត្រូវសម្លាប់ពួកគាត់ដែរ។ តែអត់បាន

សម្លាប់រួមទេ ឃើញគេសម្លាប់ហ្នឹងគេសម្លាប់តាមខ្សែអ៊ីចឹងទៅ គេចាប់មួយជួរអ៊ីចឹងទៅ អស់មួយពេលអ៊ីចឹងទៅចប់។ ដល់ថ្ងៃក្រោយគេដឹងរឿងផ្សេងទៀត គេតាមចាប់អាកន្លែងនោះទៀត ទៅផ្សេងទៅ។ អ៊ីចឹងខ្ញុំពិបាកនឹងរៀបរាប់ដែរ ព្រោះវាអត់មែនដុំកំភួន ឬក៏ចាប់ជាខ្សែអីទេ ឬក៏ជាក្រុម អត់ទេ បាទ។

[១៤:០៥:០០]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំក៏ចង់សួរលោកអំពីបញ្ហាកម្មាភិបាល ឬក៏មនុស្សមួយចំនួនដែលគេចោទប្រកាន់ថា មានទំនាក់ទំនងឬក៏ជាប់ទំនាក់ទំនងអីជាមួយជនជាតិវៀតណាម។ នៅក្នុងរបបនោះ តើមនុស្សដែលពាក់ព័ន្ធ ឬក៏មានទំនាក់ទំនងអីជាមួយជនជាតិវៀតណាម គេចោទប្រកាន់ថាអ្នកនោះជាខ្មាំងដែរឬទេ?

**ឆ៖** បាទ បើមានគេសង្ស័យថា ទំនាក់ទំនងនឹងវៀតណាម គឺមានការសង្ស័យរហូតដល់មានការចាប់ខ្លួនអ៊ីចឹង បាទ។ ជាពិសេសឈ្មោះ ភីនិត ឈ្មោះ លើយ ក៏បានមានការសង្ស័យ។ នៅក្នុងការចាប់ខ្លួននេះ ដោយសារគាត់ចាប់ដៃវៀតណាម ហើយអត់ព្រមវ៉ៃវៀតណាម បាទ។

**ស៖** លោកបាននិយាយអំពីបញ្ហានេះនៅក្នុងបទសម្ភាសន៍។ សូមលោកពន្យល់តុលាការថា ហេតុអ្វីបានជាបុគ្គលពីរនាក់នេះ មិនវាយប្រហារប្រឆាំងនឹងវៀតណាម?

**ឆ៖** បាទ សូមជម្រាបដែរថា ពេលដែលពួកគាត់ទៅជួបនៅតាមព្រំដែន ពួកគាត់អត់វ៉ៃវៀត-ណាមទេ។ គាត់ចាប់ដៃហើយ សុំឲ្យវៀតណាមហ្នឹង ដកថយខិតឲ្យផុតពីព្រំដែន បើជួបថ្ងៃក្រោយបានវ៉ៃ។ ពេលនោះ ហម ឈ្មោះ ឡាំង នេះអត់ឯកភាពទេ គឺចាប់ពួកគាត់ ហើយចាប់ទាំងខ្សែហ្នឹង ទាំងកងៗយកទៅវ៉ៃចោលអស់។

[១៤:០៧:២៦]

**ស៖** ខ្ញុំនឹងសួរលោកបន្ថែមបន្តិចទៀតអំពីទំនាក់ទំនងជាមួយនឹងវៀតណាម។ លោកបានឆ្លើយថ្ងៃនេះថា មណ្ឌលគិរីត្រូវបានរំដោះនៅឆ្នាំ១៩៧០។ សូមលោករៀបរាប់ជូនតុលាការថា<>តើ<>ខេត្តមណ្ឌលគិរីហ្នឹងត្រូវបានរំដោះនៅឆ្នាំ១៩៧០ហ្នឹងដោយរបៀបណា? <ហើយជាពិសេស>ថា<តើមាន> កងទ័ពវៀតណាមខាងជើងចូលជួយខ្មែរក្រហម ដើម្បីរំដោះមណ្ឌលគិរី ហើយនិងខេត្តផ្សេងទៀតនៅកម្ពុជានៅក្នុងភូមិភាគឦសាន<ដែរទេ>?

**ឆ៖** បាទ សូមជម្រាបថា កាលឆ្នាំ៧៧ ក្រោយពីសម្ដេចឪបានយាងទៅប្រទេសចិន បានអំពាវនាវឲ្យតាមរយៈវៀតណាម ដែលខ្ញុំធ្លាប់នៅតាមព្រំដែនហ្នឹង គឺធ្លាប់រស់នៅជាមួយវៀតណាម បាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយពួកគាត់ថា សម្ដេចឪបានឯកភាពឲ្យពួកខ្ញុំជួយរំដោះកម្ពុជា។ បាទ អ៊ីចឹងរយៈពេលដែលគាត់ជួបនិយាយជាមួយខ្ញុំហ្នឹង អត់បានមួយខែទេ ក៏បានរំដោះខេត្តមណ្ឌលគិរីហ្នឹង ក្នុងខែមិថុនា ឆ្នាំ៧០ហ្នឹងឯង។ រំដោះហ្នឹងគឺ កម្លាំងកងទ័ពវៀតណាម ភាគខាងជើង អ្នករំដោះឲ្យ អត់មានខាងពួកខ្ញុំខ្មែរក្រហមទេ បាទ ប៉ុន្តែដល់ពេលគេរំដោះហើយ គេហៅយើងទៅគ្រប់គ្រង បាទ ឲ្យខ្មែរក្រហមគ្រប់គ្រង។ ដល់អ៊ីចឹងយើងទៅគ្រប់គ្រង ដកកាំភ្លើងពីទាហានចាស់ ដកតួនាទីពីមេឃុំមេអីហ្នឹង។ អ្នកខ្លះត្រូវចាប់ខ្លួន អ្នកខ្លះត្រូវសម្លាប់ អ្នកខ្លះទៅលត់ដំអីអ៊ីចឹងទៅ។ បាទ ហើយអ្នកខ្លះក៏ជម្លៀសឲ្យនៅជាមួយប្រជាជនធម្មតានៅក្នុងឆ្នាំ៧០។ សូមអស់។

[១៤:១០:០៥]

**ស៖** តើកងទ័ពវៀតណាម ឬក៏កម្មាភិបាលវៀតណាមហ្នឹងនៅខេត្តមណ្ឌលគិរីហ្នឹង រយៈពេលប៉ុន្មានបន្ទាប់ពីឆ្នាំ១៩៧០ហ្នឹង? តើពួកគេនៅប្រចាំការនៅក្នុងខេត្តរបស់លោកហ្នឹងរយៈពេលប៉ុន្មានបន្ទាប់ពីឆ្នាំ១៩៧០?

**ឆ៖** តាមខ្ញុំដឹងហ្នឹងគឺវៀតណាមបានចាប់ផ្ដើមមកទំនាក់ទំនងជាមួយនឹងទាហានខ្មែរឆ្នាំ១៩៦៦។ ដល់១៩៧០ហ្នឹង កម្លាំងរបស់វៀតណាមនៅពេញនៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែងហ្នឹងដែរ។ ពេលនោះ ខ្មែរក្រហមក៏បានមានកម្លាំងដូចថាអាចនឹងពឹងពាក់ខាងគេនោះខ្លះ ដើម្បីទប់ទល់ធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលពេលនោះ។

**ស៖** ខ្ញុំសូមសួរលោកពីអ្វីដែលលោកឆ្លើយ<ជាមួយ>មន្ត្រីស៊ើបអង្កេត គឺឯកសារ E3/5178, ខ្មែរ <00197860>, អង់គ្លេស 00274099, បារាំង 00485184។ លោកបានឆ្លើយ និងរៀបរាប់អំពីការងាររបស់លោកដែលលោកធ្វើឲ្យឪពុកមាររបស់លោក កាស៊ី តាំងពីឆ្នាំ១៩៧១ ហើយក្រោយមកលោកឆ្លើយថា "ពីឆ្នាំ៧៤ ដល់ ៧៥ លោកទទួលខុសត្រូវក្នុងការទទួលជំនួសពីវៀតណាម"។ តើលោកអាចជម្រាបជូនតុលាការបានទេ វៀតណាមបានផ្ដល់ជំនួយអ្វីខ្លះ<>ក្នុងបណ្ដាឆ្នាំទាំងនោះ?

[១៤:១២:២៦]

**ឆ៖** បាទ ក្នុងឆ្នាំ៧៤ ចុង៧៤ ចូល៧៥នេះ វៀតណាមបានទំនាក់ទំនងនៅស្រុកកែវសីមាបច្ចុប្បន្ន ហើយបានផ្ដល់ជំនួយខ្លះៗដល់ខ្មែរក្រហម ពេលនោះខ្ញុំបាទគ្រាន់តែអង្គរក្សទៅតាមគេទេ តាមឈ្មោះហម –ឈ្មោះឡាំង– ហ្នឹង គាត់ជាលេខាខេត្តដែលគាត់ទាក់ទងជាមួយឈ្មោះគណភូមិភាគរបស់វៀតណាមឈ្មោះទុង ឬក៏ឈ្មោះតាម៉ាយ, តាឌឹក។ ពេលនោះ វៀតណាមបានទំនាក់ទំនងថា គេនឹងផ្ដល់

ជំនួយខ្លះៗ ដូចជាប្រេង ហើយនិងថ្នាំពេទ្យ និងស្រូវពូជ ។ល។ និងគ្រាប់កាំភ្លើងផងដែរបាទ។ អ៊ីចឹងទេ ខ្ញុំបានទៅចូលរួម ហើយខ្ញុំក៏បានជួយលើកជួយសែងលើកដាក់ឡានហ្នឹងដែរ។ ពេលនោះ ខ្ញុំមិនដឹងចំនួនទេ ប៉ុន្តែសរុប ខ្ញុំដឹងប្រហែលជាមាន៦០ឡានដឹក។ បាទ អត់ដឹងចំនួនរបស់ទេ ប៉ុន្តែអាចមាន៦០ឡានដឹកបាទ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ នេះទទួលបានដោយសារតែទំនាក់ទំនងរវាងលេខា<តំបន់ ឡាំង> និងអាជ្ញាធរវៀតណាម តើអ៊ីចឹងមែនទេ? <>

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ទំនាក់ទំនងនឹងលេខាខេត្តទេ អត់មានលេខាស្រុកទេបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចុះជំនួយដែលខាងតំបន់ទទួលបានហ្នឹង គេចាត់ចែងយ៉ាងម៉េចទាក់ទងទៅនឹង<>ប្រេង ស្រូវអង្ករ ក៏ដូចជាសម្ភារៈផ្សេងៗទៀត?

[១៤:១៥:០០]

**ឆ៖** បាទ បើតាមខ្ញុំដឹង សម្ភារៈទាំងអស់នេះ កាលពេលដែលចរចាគ្នា វៀតណាមសុំដឹកជញ្ជូនទៅដល់កោះញែក។ ប៉ុន្តែ ហម នេះគាត់អត់ឲ្យ អត់ឲ្យវៀតណាមដឹកទេ គាត់ដឹកខ្លួនឯង ប៉ុន្តែដល់ពេលដឹកខ្លួនហ្នឹង គេ សុំគេឲ្យដឹកជូនទៅដល់ស្រុកពេជ្រាដា ពីកែវសីមាទៅដល់ស្រុកពេជ្រាដា។ វៀតណាមក៏ព្រម ប៉ុន្តែវៀតណាមអត់បានជួយលើកដាក់ឡានទេ។ គេឲ្យពួកខ្ញុំលើកខ្លួនឯង ពេលលើកបានហើយគេជូនដល់ស្រុកពេជ្រាដា គេយកទៅកោះញែកគឺ តាហម គាត់ដឹកទៅខ្លួនឯង។ តែទៅដល់កោះញែកហ្នឹង បើតាមខ្ញុំដឹងជាអង្ករ -- អ៎! ជាស្រូវពូជហ្នឹង គាត់បានឲ្យពូជស្រូវ អ៊ី.អែរ៧តឹក ដើម្បីឲ្យយើងធ្វើស្រែ។ ហើយចំណែកឯថ្នាំពេទ្យ គឺគាត់ជូនទៅពេទ្យតំបន់។ ហើយចំណែកគ្រាប់កាំភ្លើង គាត់ជូនឲ្យទាហាន។ ហើយពេលនោះគាត់មានខោអាវរបស់វៀតណាមសម្រាប់ទ័ព គាត់បានបើកឲ្យទាហានគាត់ស្លៀកពាក់ម្នាក់មួយសម្រាប់ដែរ បាទពេលនោះ។ សូមអស់។

**ស៖** ទាក់ទងទៅនឹងប្រេងដែលទទួលបាន តើលោកមានប្រើប្រាស់ប្រេងហ្នឹងដើម្បីយកមកជួយនៅក្នុងការលើកទំនប់អូរបួន<ក្រោម>នោះដែរទេ<>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១៦:៤៧]

**ឆ៖** បាទ ប្រេងហ្នឹងលើក បានទំនប់ពីរបីដែរបាទ។ ប្រេងហ្នឹងបានជួយលើកទំនប់អូរបួនក្រោម ទំនប់អូរបួនលើ និងទំនប់អូរយេះ តាមខ្ញុំដឹងប្រេងហ្នឹងច្រើនគួរសមដែរ ប៉ុន្តែវាមិនគ្រប់គ្រាន់ទេបាទ។

**ស៖** ទំនប់អូរបួនក្រោមដែលលោកបានប្រើប្រាស់ប្រេងសម្រាប់លើកហ្នឹង តើនេះគឺជាទំនប់ដែល ខៀវ សំផន គាត់បានទៅទស្ស<នកិច្ច>នៅក្នុងឆ្នាំ១៩៧៤ ហ្នឹងឬក៏មិនមែនទេ?

**ឆ៖** មានទំនប់ហ្នឹងមួយគត់បាទ អត់មានទំនប់ច្រើនទេ។

**ស៖** ខ្ញុំសុំសួរលោកមួយចំណុចទៀត។ លោកមានអ្វីត្រូវបន្ថែមឬ?

**ឆ៖** បាទ អត់ទេ។

**ស៖** ខ្ញុំចង់សួរលោកពាក់ព័ន្ធទៅហ្នឹងចម្លើយដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត E3/5178 ដដែល ត្រង់ខ្មែរ ERN 00197858, អង់គ្លេស 00274097, បារាំង 00485182។ លោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេតថា សូមដកស្រង់៖ “គឺខ្មែរក្រហមដែលបានវាយប្រយុទ្ធជាមួយវៀតណាម ហើយវៀតណាមអត់បានវាយមកលើយើងវិញទេ”។ ហើយក្នុងចម្លើយលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា <E3/5180> ខ្មែរ <00198718>, អង់គ្លេស 00274112, បារាំង 00403440 <> លោកបានឆ្លើយដូចតទៅ៖ “សួរ៖ តើវៀតណាមមានវាយយើងទេ ឬក៏យើងវាយវៀតណាម? ឆ្លើយ៖ យើងវាយវៀតណាម ហើយវៀតណាមមិនវាយយើងទេ។” តើលោកអាចបញ្ជាក់បានទេថា ហេតុអ្វីបានជាខ្មែរក្រហមវាយវៀតណាម តែវៀតណាមមិនវាយខ្មែរក្រហមវិញទេ?

**<ប្រធានអង្គជំនុំ៖>**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាសំណួរសុំការបញ្ជាក់ទេ ពីព្រោះខ្ញុំស្តាប់ឮ<លេខខុសគ្នាដាច់>។ លោកឥឡូវកំពុងនិយាយតែឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ឬក៏និយាយអំពីកំណត់ហេតុស្តាប់ចម្លើយ?

**លោក ឌេល លីសាក់៖**

ទាំងពីរ ទី១ គឺកំណត់ហេតុរបស់ E3/5178 ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ ឯកសារ<ទី២>មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/5180។ បាទ គឺត្រឹមត្រូវហើយ ឯកសារដែលសម្ភាសនៅ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មជ្ឈមណ្ឌលឯកសារកម្ពុជា E3/5180។

[១៤:២០:៣៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ហេតុអ្វីបានជាលោកឆ្លើយថា គឺខ្មែរក្រហមដែលជាអ្នកវ៉ៃវៀតណាម ឯវៀតណាមមិនវ៉ៃមកលើខ្មែរក្រហមវិញទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** ត្រង់នេះសូមឆ្លើយថា ពេលនោះវៀតណាមដកខ្លួនអត់ទាន់ផុតពីទឹកដីកម្ពុជាទេ ដល់ពេលអ៊ីចឹងទៅខ្មែរក្រហមដេញវៀតណាមឲ្យចេញឲ្យផុតពីទឹកដីខ្លួន។ ពេលនោះ ខ្មែរក្រហមទ្រាំមិនបាន ខ្មែរក្រហមវ៉ៃ។ វ៉ៃពីរលើកនៅស្រុកកែវសីមា។ វ៉ៃលើកទី១ ស្លាប់អស់ប្រហែលជា ខ្ទង់៣០នាក់។ វ៉ៃលើកទី២ ប្រហែលជា៦០នាក់ តែវៀតណាមអត់បានបាញ់តបទេបាទ។ ត្រង់នេះ ដែលខ្ញុំយករឿងនេះ មកអះអាងបាទ។ ចុងក្រោយមកបាននិយាយមីក្រូឆ្លងឆ្លើយគ្នា "ហេតុអីបានកម្ពុជាបាញ់វៀតណាម? វៀត-ណាមសួរ "ថាកាលមុនយើងសាមគ្គីគ្នា បារីមួយដើមកាច់ចែកគ្នាជក់ តែឥឡូវម៉េចបានបាញ់គ្នាអ៊ីចឹង?" ប៉ុល ពត ថា -- ខាងខ្មែរក្រហមថា "ពួកខ្ញុំមិនមែនវ៉ៃវៀតណាមដែលកុម្មុយនីស្តទេ គឺវ៉ៃវៀតណាមឈ្លានពាន បើវៀតណាមមិនឈ្លានពានមិនមែននៅទឹកដីពួកខ្ញុំទេ" ឆ្លើយទៅវិញអ៊ីចឹង។ ពេលនោះ រឿងកាន់តែមានតៗទៀត។ បាទ សូមអស់។

**ស៖** ហើយមុននេះបន្តិច លោកនិយាយពីកងទ័ពពីរនាក់ដែលត្រូវបានចាប់ខ្លួនដោយសារតែមិនបើកការបាញ់ប្រយុទ្ធទៅលើវៀតណាម ខ្ញុំឮសួរឈ្មោះថា មួយឈ្មោះ ភីនិត និងមួយទៀតឈ្មោះ លើយ។ <តើខ្ញុំចាំត្រឹមត្រូវទេ?> តើកងទ័ពទាំងពីរនាក់នេះ ជាកងទ័ពដែលធ្លាប់ធ្វើការជាមួយវៀតណាមដែរនោះឬ ក្នុងសង្គ្រាមចន្លោះ ពីឆ្នាំ៧០ ទៅ ៧៥? តើអ្នកទាំងពីរនេះ ស្គាល់កងទ័ពវៀតណាមហ្នឹងដែរ បានជាមិនបើកការវាយប្រយុទ្ធទៅលើវៀតណាម?

**ឆ៖** បាទ ពួកគាត់ពីមុនមកធ្លាប់ប្រយុទ្ធរួមគ្នា ធ្លាប់រស់នៅជាមួយគ្នា ធ្លាប់វ៉ៃខ្មាំងជាមួយគ្នា ដល់ពេលក្រោយមកគាត់ដឹងថា ជួបគ្នាអ៊ីចឹងដូចគាត់ចិត្តមិនដាច់នឹងវ៉ៃគ្នា នឹងសម្លាប់បាទ។ ពេលនោះ គាត់ក៏មិនបានវ៉ៃគ្នា ដល់ពេលក្រោយមក កម្លាំងទ័ពរបស់គាត់ គាត់បានរាយការណ៍ថ្នាក់លើ ថ្នាក់លើក៏ចាប់ថ្នាក់គាត់ ចាប់មិនមែនត្រឹមតែគាត់ទេ មួយកងគាត់ចង់អស់ទៅហើយ បាទ។

[១៤:២៣:៤៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សី ខ្ញុំជិតបញ្ចប់ការតាំងសំណួរទៅកាន់លោកហើយ។

លោកប្រធាន យើងខ្ញុំសុំការអនុញ្ញាតផ្ដល់ជូនសាក្សីនូវទម្រង់ផ្ដល់ព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ E3/6768 គឺជាបុគ្គលម្នាក់ដែលនឹងមកផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីនៅថ្ងៃមុខនេះ គាត់បានបញ្ជាក់អំពីមន្ទីរសន្តិសុខ ហើយគាត់បានផ្ដល់អំពីទីតាំងនៃមន្ទីរសន្តិសុខ។ អ៊ីចឹងខ្ញុំចង់ផ្ដល់ឯកសារនេះទៅជូនសាក្សីរូបនេះមើល <ទីតាំងនេះ និងថាតើគាត់អាចជួយយើងឲ្យយល់បានទេពីទីតាំងមន្ទីរសន្តិសុខនោះនៅកន្លែងណា។> គឺឯកសារ E3/6768។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកកុំបញ្ចេញឈ្មោះបុគ្គលម្នាក់នេះឲ្យសោះ បើលោកអានឃើញឈ្មោះនេះនៅលើឯកសារនេះ ហើយកុំនិយាយឈ្មោះគាត់។ ខ្ញុំមានដាក់ពណ៌នៅលើឯកសារនេះ នេះគឺជាដើមបណ្ដឹងរដ្ឋប្បវេណី ដែល<ជាកងទ័ព>កងពល៩២០ គាត់និយាយអំពីការឃុំខ្លួន<>នៅមន្ទីរសន្តិសុខពិសេសមួយ នៅក្បែរជើងភ្នំ នៅក្បែរអូរល្ពៅ នៅស្រុកកោះញែក។ បុគ្គលនេះ មិនមែនជាអ្នកមកពីមណ្ឌលគិរីទេ។ ដូច្នេះ សំណួររបស់ខ្ញុំសួរថា តើលោកស្គាល់ថាមន្ទីរសន្តិសុខមួយណា ដែលដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើង យើងអត់មានផែនទីបញ្ជាក់ទីតាំងលម្អិតអំពីទឹកដីនៃស្រុកកោះញែកនេះទេ។ តើលោកដឹងថា អូរល្ពៅនៅត្រង់កន្លែងណាដែរ? ហើយលោកដឹងថា មន្ទីរសន្តិសុខមួយនេះ នៅក្បែរជើងភ្នំជិតស្ទឹងហ្នឹងនៅត្រង់កន្លែងមួយណាដែរទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** ស្រុកកោះញែកអត់មានឈ្មោះអូរល្ពៅទេ បាទ។ អូរល្ពៅអត់មានទេ។

**ស៖** <អ៊ីចឹងលោក>មិនស្គាល់<>ឈ្មោះអូរ ឈ្មោះ<ទន្លេបែបហ្នឹងទេនៅស្រុកកោះញែកនោះតើត្រឹមត្រូវទេ>?

**ឆ៖** (ឮមិនច្បាស់) ។

**លោកស្រី សុក សុជាតា៖**

អំមិញគាត់សួរថានៅស្រុកកោះញែកហ្នឹង អត់មានអូរល្ពៅទេ មានអូរអីផ្សេងទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** មានអូរ -- សូមជម្រាប នៅស្រុកកោះញែកនេះ មានអូររយ៉ អូររវាក់ ហើយអូរយេះ។ អ៊ីចឹងអត់មានអូរល្ពៅទេ។

[១៤:២៨:០១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចុះមាន អូរ ស្ទឹង ព្រែក នៅក្បែរមន្ទីរ ក-១១ ឬក៏នៅក្បែរមន្ទីរសន្តិសុខភ្នំក្រោលអីដែរទេ? តើនៅក្បែរទីតាំងទាំងពីរនេះ មានអូរ មានស្ទឹង មានព្រែកណានៅក្បែរនោះដែរ?

**ឆ៖** នៅភ្នំក្រោលនេះ មានទំនប់កម្មករហ្នឹងតែមួយគត់បាទ។ ទំនប់នេះ គេហៅ ទំនប់តាសុទ១ នៅអបភ្នំក្រោលហ្នឹងតែម្តងបាទ អត់មានអូរទេ។ គុកដែលនេះក៏នៅហ្នឹងដែរ នៅជាប់គ្នាហ្នឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សីដែលឆ្លើយមកកាន់សំណួរទាំងឡាយរបស់ខ្ញុំ។

ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ជាបឋម សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ សូមគោរពលោកសាក្សី ខ្ញុំឈ្មោះទី ស្រ៊ីនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរតិចតួច ដើម្បីសួរទៅកាន់លោក។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំមានចំណុច មួយសូម ពាក់ព័ន្ធជាមួយនឹងករណី កាស៊ី។ ខ្ញុំសូមលើកយកឯកសារ E3/5178 ដែលមានលេខ ERN ជាភាសាខ្មែរ 00197863, ភាសាអង់គ្លេស 00274102 និងភាសាបារាំង 00485187។ នៅត្រង់ចំណុចមួយដែលលោកបានលើកឡើង ដែលលោកបានឆ្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត លោកបានលើកឡើងថា៖ “កាលពីបីបួនខែមុនចាប់ ស្វាយ, កាស៊ី

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ត្រូវបានទម្លាក់ពីតំណែងរួចហើយ"។ អ៊ីចឹង ខ្ញុំសូមសួរបញ្ជាក់លោកថា តើពេលដែល កាស៊ី ត្រូវបានគេទម្លាក់ពីតំណែងហ្នឹង នរណាជាអ្នកមានសិទ្ធិសម្រេចទម្លាក់ កាស៊ី ចេញពីតំណែង? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ទទួលបាន។ អ្នកទម្លាក់ កាស៊ី ចេញពីតំណែងគឺគ្មានក្រៅពីលេខាតំបន់ទេ ដែលមានសិទ្ធិធំជាងគេបាទ។

[១៤:៣១:៣៤]

**ស៖** សូមអរគុណ។ អ៊ីចឹងមានន័យថា រាល់ការតែងតាំង ឬក៏ការទម្លាក់បុគ្គលដែលនៅថ្នាក់ស្រុកអី គឺមានតែតំបន់ជាអ្នកមានសិទ្ធិ តើអ៊ីចឹងមែនឬ?

**ឆ៖** បាទ ធម្មតាតែងតាំងក៏គណៈតំបន់ បើនេះជាលេខាតំបន់ ឬក៏លេខាខេត្ត ទម្លាក់ក៏លេខាខេត្ត ក៏លេខាតំបន់ដែរបាទ។

**ស៖** សូមអរគុណ។ នៅក្នុងករណីហ្នឹង ខ្ញុំសូមសួរលោកថា តើខាងតំបន់ហ្នឹងគេមានត្រូវការសុំឆ្លងយោបល់ថ្នាក់លើបន្តទៀត ឬមួយក៏ជាការសម្រេចរបស់ខាងតំបន់ដោយខ្លួនឯង?

**ឆ៖** បាទ តាមខ្ញុំប្រហែលជាមិនប្រាកដដែរ ព្រោះថារយៈកាលកន្លងមក ការទាក់ទងថ្នាក់លើខ្ញុំមិនដែលដឹងដែរទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមលើក -- សូមបញ្ជាក់លោកមួយចំណុចទៀតពាក់ព័ន្ធជាមួយនឹងត្រពាំងព្រីងជាកន្លែងសម្លាប់មនុស្សដែលលោកបានជម្រាបជូនអង្គសវនាការកាលពីព្រឹកមិញ។ ខ្ញុំចង់សួរបញ្ជាក់លោកថាតើទីតាំងសម្លាប់មនុស្សចម្ការព្រីងហ្នឹងមានឈ្មោះហៅអ្វីផ្សេងទៀតដែរឬទេលោក?

**ឆ៖** បាទ ដូចជាអត់មានឈ្មោះអីផង មានតែៗផ្លូវៗពីរកោះញែកមកខេត្តក្រចេះ ឯជាប់ហ្នឹងមានត្រពាំងមួយគេហៅ "ត្រពាំងព្រីង"។ បាទ មានតែឈ្មោះតែប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមលើកពាក់ព័ន្ធជាមួយហ្នឹងទំនាក់ទំនងវិញម្តង ថាតើមន្ទីរក-១៥។ លោកក៏បានលើកអំពីមន្ទីរក-១៥ ហើយនិងបានលើកអំពីមន្ទីរក-១៦ និងក-១៧។ អ៊ីចឹងខ្ញុំសូមសួរលោកថា តើមន្ទីរទាំងហ្នឹងវាមានទំនាក់ទំនងជាមួយនឹងមន្ទីរ -- តំបន់១០៥ ហ្នឹងដោយរបៀបណា? ហើយគេប្រើប្រាស់មធ្យោបាយណាដើម្បីធ្វើការទំនាក់ទំនងគ្នា? ហើយពាក់ព័ន្ធនឹងការងារ តើគេប្រើប្រាស់របៀបបែបណាដែរ ដើម្បីទំនាក់ទំនងគ្នានោះ?

**ឆ៖** បាទ ក្នុងពេលដែលមន្ទីរទាំងប៉ុន្មាន បើតាមនិយាយចំ ជាមន្ទីររបស់អាណាព្យាបាលរបស់ខេត្តហើយ ជាអាណាព្យាបាលរបស់តំបន់។ មានដូចជាមន្ទីរក-១៦, មន្ទីរក-១១, មន្ទីរ៣៧អ៊ីចឹង។ មន្ទីរតាឡយ ជាមន្ទីរ៣៧ ប៉ុន្តែជាការដ្ឋានសម្រាប់បង្កបង្កើនផល។ ដល់អ៊ីចឹងក្នុងមន្ទីរទាំងអស់នោះ វាជាក្នុងក្របខ័ណ្ឌរបស់ខេត្តទាំងអស់។ អ៊ីចឹងទេ ការទាំងនាក់ទំនងក្នុងមធ្យោបាយឲ្យដំណឹងគ្នាទៅវិញទៅមកជំនាន់នោះអត់តេឡេហ្វូនទេ បាទ គឺធ្វើតាមក្រដាស -- លិខិត ឬក៏តាមនីរសារដែលជិះសេះ ឬក៏ជិះរទេះគោអ៊ីចឹង បាទ។ សូមអស់។

[១៤:៣៥:៤៩]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរលោកថា តើរវាងមន្ទីរទាំងអស់ហ្នឹងគឺ ជាទូទៅគឺគាត់តែងតែធ្វើការទំនាក់ទំនងគ្នាទៅលើរាល់ការងារទាំងអស់ គឺគាត់តែងតែទំនាក់ទំនងគ្នាតែអ៊ីចឹងមែនទេលោក?

**ឆ៖** បាទ គេទំនាក់ទំនងអ៊ីចឹង ព្រោះដូចខ្ញុំបានជម្រាបពីខាងលើមក។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកបន្តទៀតថា រាល់សកម្មភាព ឬក៏ហេតុការណ៍ដែលបានកើតឡើងនៅក្នុងតំបន់១០៥ទាំងមូល ដូចជាក្នុងករណីដែលលោកបានលើកកាលពីព្រឹកមិញ ដូចជា ករណីដែលមានមួយក្រុមដែលជាប់ខ្សែ កាស៊ី ហ្នឹង គាត់បាន -- មនុស្សមួយក្រុមចំនួន១៨នាក់ ដែលជាប់ខ្សែ កាស៊ីគាត់រត់ទៅវៀតណាម រត់អីហ្នឹង គឺរាល់ការងារ ទាំងព័ត៌មានដែលពាក់ព័ន្ធជាមួយនឹងការរត់ចេញអ៊ីចឹងមានន័យថា មន្ទីរទាំងអស់ហ្នឹងគឺពួកគាត់សុទ្ធតែដឹងរឿងទាំងអស់គ្នា ឬក៏យ៉ាងម៉េចលោក? ឬមួយក៏ដឹងគ្រាន់តែមានការលាក់ការណ៍សម្ងាត់ទៅលើតែកន្លែងណាដែលគាត់កាន់ខាងហ្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ ព្រោះធម្មតា តែមួយសភាពការណ៍អ៊ីចឹងគេរត់ប្រាប់គ្នា បាទ ប្រាប់ៗទូទៅ។ កន្លែងណាសំខាន់ៗគេ នីរសារគេរត់ប្រាប់គ្រប់កន្លែង បាទ។ យើងទេត្រូវដឹង ត្រូវមានការប្រុងប្រយ័ត្ន ឬក៏មានបញ្ហាដែលអាចមានវិធានការអីមួយដែលគេអាចធ្វើសកម្មភាពបាន។ សូមអស់។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកពាក់ព័ន្ធជាមួយនឹងកិច្ចប្រជុំវិញម្តង។ ទាក់ទងនឹងកិច្ចប្រជុំហ្នឹង លោកមានដែលធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាដែរឬទេ? ហើយការចូលរួមរបស់លោកហ្នឹង ចំនួនប៉ុន្មានដងដែរ តាំងពីលោកធ្វើការនៅកន្លែងតំបន់១៥ហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនដែលបានចូលរួមទេ។ បើសិនជាទៅក្នុងនាមជានីរសារ គ្រាន់តែត្រឹមម៉ាជូនទឹកជូនបាយគេបាន បាទ។

**ស៖** ចុះលោកមានដែលចូលរួមមីទ្ទិងអីដែរឬទេ?

**ឆ៖** បាទ មានចូល។ ខ្ញុំបានចូលរួមមីទ្ទិងនៅទំនប់អូរប្អូនក្រោម ដែលគេធ្វើមីទ្ទិងរួមនិងធ្វើបុណ្យឆ្នាំផង ហើយគេលើហេតុផលពីរឿងធ្វើសង្គ្រាមជាមួយវៀតណាមអត់ប្រកាស។ ខ្ញុំបានចូលរួមមិនមែនខ្ញុំម្នាក់ទេ ប៉ុនមនុស្សរាប់រយរាប់ពាន់នាក់ចូល បាទ។

[១៤:៣៩:២៩]

**សៈ** សូមអរគុណ។ តើមីទ្ទិងដែលលោកធ្លាប់ចូលរួមហ្នឹង តើមីទ្ទិងដែលគេធ្វើនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះហ្នឹង គេធ្វើប៉ុន្មានដងដែរលោក?

**ឆ៖** បាទ មីទ្ទិងគេធ្វើតូចតាច ដូចថាតាមមន្ទីរតាមអីហ្នឹង គេចាប់មនុស្សចាប់អីហ្នឹង ធ្វើតែញឹកញាប់។ បើមីទ្ទិងធំៗ ឬក៏ពិធីធំៗអ៊ីចឹង មានយូរៗម្តង បាទ។ គេហៅប្រជាជនគ្រប់ភូមិ គ្រប់ស្រុក អ៊ីចឹងមកជុំគ្នា គេធ្វើ។ តាមមន្ទីរ តាមអង្គភាព គេធ្វើមីទ្ទិងគេចាប់មនុស្សមួយប្រកាសអ៊ីចឹង គេធ្វើប្រាវ មួយម៉ោង ពីរម៉ោងអ៊ីចឹងទៅ គេចាប់ចង់មនុស្សកណ្តាលវាលអ៊ីចឹង អាហ្នឹងញឹកញាប់ណាស់។ សូមអស់។

**សៈ** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លើពាក្យក្នុងមីទ្ទិងតូចៗ លោកបានលើកឡើងថា មីទ្ទិងតូចៗគេធ្វើជាញឹកញាប់មួយម៉ោងមួយដង។ អ៊ីចឹងខ្ញុំចង់សួរថា អ្នកដែល ពេលដែលគេធ្វើមីទ្ទិងតូចៗហ្នឹងមានអ្នកណាគេខ្លះចូលរួម? ហើយអ្នកណាជាអ្នកដើរតួនាទីនៅក្នុងប្រកាស ការប្រកាសអំពីបញ្ហាដែលចាប់មនុស្ស ចាប់អីហ្នឹង អ្នកណាគេ?

**ឆ៖** បាទ បើតាមរកឃើញមកគឺ ប្រធានៗនៅអង្គភាពណា គឺប្រធានអង្គហ្នឹងគេធ្វើ គេប្រកាស។

**សៈ** សូមអរគុណ។ ខ្ញុំសុំសួរសំណួរចុងក្រោយមួយពាក់ព័ន្ធជាមួយហ្នឹង ពីមុនលោកបានលើកពាក់ព័ន្ធជាមួយហ្នឹង -- លោកបានទៅដល់កន្លែងមួយនៅមុខមន្ទីរក្រុមឃ្វាលគោរបស់លោកហ្នឹងនៅរយ៉សូមទោស នៅរយ៉លោកបានទៅឃ្វាលគោកន្លែងមួយ ហើយលោកក៏បានចុះទៅយកទឹកដើម្បីយកមកហូប។ អ៊ីចឹងពេលហ្នឹងលោកបានទៅមុខមន្ទីរមួយ ហើយដែលមន្ទីរហ្នឹងលោកបានឃើញឡានមួយចតនៅកន្លែងនោះ ដែលក្នុងហ្នឹងមានក្រុម មនុស្សមួយក្រុមដែលគេដាក់នៅក្នុងឡាននោះដែលបម្រុង លោកបានលើកឡើងចំណុចហ្នឹង។ ខ្ញុំចង់សួរបញ្ជាក់លោកថា លោកមានបានមើលក្នុងឡានហ្នឹងទេ តើក្នុងឡានហ្នឹងមានមនុស្សប្រុស ឬក៏ស្រី ហើយក៏មានកុមារដែរឬទេ?

[១៤:៤២:១៩]

**ឆ៖** បាទ ខ្ញុំគ្រាន់តែឮតែនិយាយទេ ពីព្រោះឡានហ្នឹងគេឃ្លុំបេជិត គេចងតង់ហ្នឹង ចងជិតមែនទែន។ ហើយកម្លាំងគេអ្នកយាម គេយាមនៅក្រោមហ្នឹង ខ្ញុំគ្រាន់តែថាដងទឹកដោយសារពុយទឹកគេនៅ

01225773



ជិតហ្នឹងឡានហ្នឹងបាទ។ ប៉ុន្តែខ្ញុំបានឮនេះ គឺជាគ្នាដែលធ្លាប់រស់នៅជាមួយខ្ញុំ ធ្វើការជាមួយគ្នានៅស្រុកកែវសីមាដែលសុំអង្ករខ្ញុំ ឲ្យខ្ញុំ សុំទឹកខ្ញុំនោះ។ ខ្ញុំថាខ្ញុំមិនអាចយកឲ្យគាត់បានទេ។ សូមគាត់អធ្យាស្រ័យផង ខ្ញុំថា ខ្ញុំឥឡូវគេឲ្យទៅឃ្វាលគោ ឃ្វាលក្របីនៅរយ៉។ គាត់បានសួរថា "តើបង កាស៊ី គាត់នៅរស់ដែរឬអត់? ថ្ងៃហ្នឹងតើ កាស៊ី នៅរស់ឬទេ?" បាទ ពីព្រោះខ្ញុំចេញមកខ្ញុំបានចាប់ដៃគាត់ហើយលាគ្នាពេលដល់រយ៉ហ្នឹង បានស្រាប់តែកូនទាហាន កូនចៅគេចាប់ដាក់ពេញឡានអស់ហើយហ្នឹង។ អ៊ីចឹងទេ ខ្ញុំក៏អត់ហ៊ានយកទឹកឲ្យគេ ក៏ខ្ញុំសុខចិត្តស្រូតចេញឲ្យផុតពីហ្នឹងទៅ កុំឲ្យមានបញ្ហា។

**ស៖** សូមអរគុណ។ ខ្ញុំសុំបញ្ជាក់ឡើងបន្តិច ថាតើក្រៅពីឡានដែលលោកឃើញហ្នឹង កន្លងមកដែលលោកដើរចេញចូលនៅក្នុងទីតាំងរយ៉ហ្នឹង តើលោកមានធ្លាប់ឃើញការដឹកជញ្ជូនជាលក្ខណៈឡានដូចលោកបានឃើញហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** បាទ មិនសូវមានប៉ុន្មានទេ។ ពីព្រោះ ម្យ៉ាងខ្ញុំក៏មិនសូវឧស្សាហ៍ចេញចូលប៉ុន្មានដែរបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមអភ័សទោស ខ្ញុំសូមបញ្ជាក់មួយសំណួរទៀត។ ទាក់ទងទៅហ្នឹង ក-១១ លោកបានលើកឡើងថា ក-១១ គឺជាកន្លែងឃុំខ្លួនបណ្ដោះអាសន្ន ហើយនិងជាកន្លែងដាក់អ្នកទោសសុទ្ធដែលមានកំហុសស្រាល។ អ៊ីចឹងខ្ញុំសុំសួរលោកថា ពេលដែលគេយកអ្នកទោសមកដាក់នៅ ក-១១ អ៊ីចឹង តើគេមានការសួរចម្លើយ ឬក៏ធ្វើទារុណកម្មទៅលើបុគ្គលហ្នឹងដែរឬក៏អត់?

**ឆ៖** បាទ ត្រង់នេះខ្ញុំមិនសូវច្បាស់ទេ ពីព្រោះធ្លាប់សំណេះសំណាល ឬក៏ធ្លាប់ជួបជាមួយអ្នកដែលធ្លាប់ចូលទៅកន្លែងនោះ ហើយគេបានរួចខ្លួនមកវិញហ្នឹងគេឧស្សាហ៍និយាយ។ ប៉ុន្តែខ្ញុំក៏មិនច្បាស់ដែរបាទ សូមទោស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីតុលាការសម្រុះសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ព្រមទាំងមេធាវីប្រឹក្សាមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដែលដំបូងនេះផ្តល់ទៅវេទិកាទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងសួរសំណួរលោកមួយចំនួននៅរសៀលនេះ ខ្ញុំជាមេធាវីការពារក្តីឲ្យលោក នួន ជា ខ្ញុំសួរសំណួរខ្លះៗបញ្ជាក់ពីសំណួរមុន។ ពាក់ព័ន្ធនឹងកងទ័ពវៀតណាមដែលបានឈ្លានពានចូល ឬក៏វាយប្រហារ <>ចូលមកក្នុងទឹកដីខ្មែរ <និងសំណួរទូទៅ> អ្នកណាអ្នកចាប់ផ្តើមបាញ់មុន? នៅក្នុងចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/5636, ERN ជាភាសាខ្មែរ 00042473, អង់គ្លេស 00711210, បារាំង 00727130។ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្តីលោក៖ "សួរ៖ តាមការយល់ឃើញរបស់លោក តើកត្តាអ្វីដែលបណ្តាលឲ្យខ្មែរក្រហម<ដួលរលំ>? លោកឆ្លើយថា៖ ខ្ញុំអាចឃើញជាមុនតាំងពី<គេប៉ុនប៉ងប្រឆាំង>ជាមួយនឹងវៀតណាម។ ពួកគេបានវាយប្រយុទ្ធយើងជាមួយនឹងការឃោសនា គេមិនអនុញ្ញាតឲ្យវៀតណាមឈ្លានពានចូលទឹកដីយើងទេ។ ជម្លោះនៅតាមព្រំដែននេះក៏វាជាកត្តាមួយដែរ។ ខាងវៀតណាមហាក់បីដូចជាញុះញង់។ <ផ្នែកម្ខាងរបស់> អូរហុចវៀច <ជារបស់ខ្មែរ ហើយផ្នែកខាង>ទៀតជា<របស់>វៀត-ណាម ប៉ុន្តែខាងវៀតណាមបែរជាមកស្នាក់នៅលើខាងទឹកដីខ្មែរ។ ហើយខ្មែរសួរ<ពួកគេ>ថាម៉េចបានជាអ្នកមិនត្រឡប់ទៅទឹកដីអ្នកឯងវិញ<តាំងពីឯករាជ្យបានទទួលជោគជ័យហើយ>? <កងទ័ព>កងពល៩២០ បាន<បាញ់សម្លាប់ពួកគេ៣០នាក់ ទៅ៦០នាក់ក្នុងម្តងៗ> ប៉ុន្តែ<ពួកគេ>មិនបាញ់តបតមកវិញទេ។" បញ្ចប់ការដកស្រង់។ តើលោកចង់និយាយថាម៉េច នៅពេលដែលលោកនិយាយថាខាងវៀត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាមហាក់បីដូចជាៗអ្នកញុះញង់?

[១៥:០៥:៤០]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ការដែលកងពលវ៉ៃវៀតណាមនេះ ដូចមានប្រសាសន៍ពីដើមអ៊ីចឹង វៀតណាមដូចជាអត់សូវចង់ដកខ្លួនចេញពីកន្លែងទីតាំងទេ។ ទីតាំងនៅសល់តែមួយកន្លែងហ្នឹងគត់ ប៉ុន្តែគ្រាន់តែម៉ៃពីរទេ គាត់ថាគាត់មិនទាន់ដឹកអីវ៉ាន់អស់ រង់ចាំដឹកអីវ៉ាន់ចេញឲ្យអស់បានគាត់ចេញ។ ប៉ុន្តែដោយសារខាងកងពល៩២០ហ្នឹង គាត់អត់ចាំទេ គាត់វ៉ៃតែម្តងបាទ។ អ៊ីចឹងទេគឺការដែលប៉ះទង្គិចនេះជាលើកដំបូងបំផុត ហើយម៉្យាងគឺកងពលហ្នឹងគាត់អត់ដឹងថា មានការរៀបចំពីថ្នាក់លើដែរឬអត់ អត់ទេ ប៉ុន្តែស្រាប់តែឃើញវ៉ៃថាគ្នាហ្មង។ ខ្ញុំសូមអស់ប៉ុណ្ណឹង។

**ស៖** តើត្រឹមត្រូវដែរទេដែលនិយាយថាខ្លួនលោកផ្ទាល់នេះមិនមែនជាកងទ័ព<ទេ លោកមិន> ពាក់ព័ន្ធនៅក្នុង<>កងពកល៩២០<ទេ> ឬក៏ថាលោកមិនមែនជាកងទ័ពរបស់<កងពល>ភូមិភាគ<ឦសាន>ទេ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ខ្ញុំមិនមែនជាកងទ័ពទេបាទ ប៉ុន្តែនៅក្នុងតំបន់ស្រុកកែវសីមា ខ្ញុំបានដឹងរឿងខ្លះៗ។

**ស៖** ខ្ញុំសុំអានឲ្យលោកស្តាប់ <នូវអ្វី>ដែល<>កងទ័ពកងពល៩២០<ម្នាក់> ដែលបានឆ្លើយជូន មន្ត្រីស៊ើបអង្កេត<នៃ>មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំនឹងអានសម្រង់ចេញពីចម្លើយរបស់គាត់ឲ្យលោកស្តាប់ ហើយខ្ញុំនឹងសួរលោកវិញមើល តើលោកយល់ដូចម្តេចដែរ។ ឯកសារ E3/7960, ERN ជាភាសាខ្មែរ 00851665 ដល់ 66, អង់គ្លេស 00450295, បារាំង 0073898<(*ស៊ីក*)> ដល់ 99។ បាទ គាត់នេះគឺជាកងទ័ពកងពល៩២០។ <សូមទោស>--

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសហព្រះរាជអាជ្ញារងអន្តរជាតិ?

[១៥:១០:០០]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែបញ្ជាក់សម្រាប់ប្រតិចារឹកនេះ គឺមិនមានជាប្រតិចារឹកដែលត្រឹមត្រូវនេះទេ នេះគឺគ្រាន់តែជាសេចក្តីសង្ខេបមួយ<ដែលត្រូវបានគេរៀបចំឡើង>។ ឥឡូវនេះមេធាវីការពារក្តី<បានដាក់ប្រតិចារឹកទៅក្នុង>កំណត់<ត្រាហើយ ប៉ុន្តែខ្ញុំគិតថា វាអត់ទាន់មានការបក

ប្រែទេ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់ថា នេះជាសេចក្តីសង្ខេបតែប៉ុណ្ណោះ មិនមែន>ជាសេចក្តីព្រាងនៃប្រតិចារឹក<របស់កិច្ចសម្ភាសន៍ពិតប្រាកដនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនបាច់ឆ្ងល់ទេ គឺអ៊ីចឹងមែន។ ជាចំណែកមួយនៃប្រតិចារឹកតែប៉ុណ្ណោះ។ <យើងបានស្នើសុំឲ្យមានការបកប្រែឯកសារនេះជាភាសាអង់គ្លេសឲ្យបានពេញលេញ។ ពីមុនមកខ្ញុំធ្លាប់បានសួរសំណួរដោយយោងទៅលើឯកសារសង្ខេបនេះរួចមកហើយ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <>លោកសាក្សី <គាត់នេះ>បានឆ្លើយថា "នៅក្នុងឆ្នាំ៧៧ មានការវាយប្រហារពីសំណាក់វៀតណាម គឺ វៀតណាមនេះឯងដែលចាប់ផ្តើមវាយយើងមុន"។ បាទ នេះគឺ<ពាក្យ>ពីរឃ្លា<នៅក្នុងសេចក្តីសង្ខេបរបស់គាត់។ ដូច្នេះ>កងពល៩២០នេះបានឆ្លើយថា គឺវៀតណាមដែលចាប់ផ្តើមវាយប្រយុទ្ធ<ដោយកងទ័ព>មុន<> គឺមិនមែនកងទ័ពកងពល៩២០ ឬក៏កងទ័ពនៃកងពលផ្សេងទេដែលវាយទៅលើវៀតណាមមុននោះ វៀតណាមទេ ដែលវាយមុន។ លោកយល់ដូចម្តេចដែរ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ចំណែក ខ្ញុំៗសូមបដិសេធ ព្រោះជារឿងការពិត ដែលខ្ញុំធ្លាប់រស់នៅហ្នឹង គឺមិនដែលយួនវ៉ៃម្តងទេ មានតែយើងទៅវ៉ៃគេមុនហ្នឹង។ មតិនេះ ខ្ញុំសូមបដិសេធបាទ។

[១៥:១១:៥៨]

**ស៖** អ៊ីចឹងខ្ញុំសូមសួរតទល់ជាមួយលោក មិនមែនសក្ខីកម្មពីសាក្សីណាម្នាក់ទេ ប៉ុន្តែជាព័ត៌មានពីសារទូរលេខ ដែលបានទទួលសម័យនោះ គឺឯកសារ E3/887, ERN អង់គ្លេស 00185223, ខ្មែរ 00021448, បារាំង 00283096។ នេះជាសារទូរលេខមកពី <សូ សារឿន> ឬក៏ហៅថា តា០៥ <ផ្ញើជូន>អ៊ំ ៨៩ គឺ សុន សេន។ ហើយសារទូរលេខនេះ និយាយដូចតទៅ៖ "នៅយប់ថ្ងៃទី២២ ខែមករា ៧៦ ខាងវៀតណាមបានចូល<ដោយសម្ងាត់>មកជំរំរបស់យើងនៅផ្លូវមុខ ក៏ដូចជាផ្លូវក្រោយ ហើយបានចាប់វាយប្រហារមកលើ<កងការពារ>យើង។" ចំណុចលេខ៣៖ "យើងមិនទាន់វាយវាទេ យើងនៅទាក់ទងដាច់ខាតព្រោះ<ទីនោះជា>ទឹកដីយើង។" ហើយនៅចុងបញ្ចប់នៃសារទូរលេខនេះ "នៅម៉ោងដប់មួយ<>ថ្ងៃទី២៣ ខែមករា ៧៦ ពួក<>វាបញ្ជូនកម្លាំងវាបន្ថែមមកវាយយើងទៀត។ យើងមិនទាន់ប្រយុទ្ធវាទៀត ចាំមើលវាទៀត។" បញ្ចប់ការដកស្រង់។

អ៊ីចឹង ខ្ញុំ<សូមអានឲ្យលោកស្ដាប់នូវឯកសារ>ដែល<>សុន សេន បាន<ប្រាប់ដល់សមាជិក> គណៈអចិន្ត្រៃយ៍ គឺឯកសារ E3/221 ជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី១៤ ឧសភា ៧៦ គឺរយៈពេលបីបួនខែក្រោយទទួលបានសារទូរលេខ ERN ជាភាសាខ្មែរ 00000813, អង់គ្លេស 00182696, បារាំង 00386178។ សុន សេន បានរាយការណ៍ ទៅប៉ុល ពត, នួន ជា <និងអ្នកផ្សេងទៀត> ដូចតទៅ សូមដកស្រង់៖ “នៅព្រំដែន វាចេះតែចូលជាប់ អត់មានឈប់ឈរទេ យើងអត់ទៅរករឿងហេតុវាសោះ។ តាមបទពិសោធន៍ បើវាចូលមក យើងមិនដេញ វាមិនទៅទេ ដល់តែយើងតឹងវិញ ទើបវាទៅ។ នេះខាងរតនគិរី ឯខាងមណ្ឌលគិរី យើងអត់វាយវាសោះ គឺយើងគោរពការណែនាំរបស់បក្សជាដាច់ខាត មិនឲ្យតឹងតែង។” ដូច្នេះ លោកសាក្សី ខ្ញុំបានដកស្រង់ចេញពីឯកសារដែលមាននៅក្នុងសម័យកាលនោះ គឺរបាយការណ៍ សុន សេន ផ្ញើជូនទៅដល់ថ្នាក់លើ។ <>ចំណុចនេះហាក់បីដូចជាបញ្ជាក់ឲ្យឃើញថា វៀតណាមទេដែលចាប់ផ្ដើមវាយប្រហារមុននោះ។ តើលោកយល់យ៉ាងដូចម្ដេច ឬមានប្រតិកម្មយ៉ាងណាដែរ ចំពោះកំណត់ហេតុគណៈអចិន្ត្រៃយ៍នេះ?

[១៥:១៥:៤៥]

**ឆ៖** បាទ សូមជម្រាបដែរថា រឿងនេះ ធម្មតាម្នាក់យកត្រូវ ហើយម្នាក់យកៗ ចំពោះអ្នកយកត្រូវ ចង់និយាយម៉េចក៏បាន។ ខ្ញុំវាមិនអាចឆ្លើយបានទេ បាទ។ សូមអស់។

**ប្រធានអង្គជំនុំ៖**

តាមការស្ដាប់របស់យើង ជាភាសាខ្មែរយើងយល់ខុសពីនេះ។ តាមស្ដាប់អ្វីដែលសាក្សីឆ្លើយដំបូងឡើយ ពាក់ព័ន្ធនឹងថាវាយចុងក្រោយ កុំសន្មត -- កំណត់ថាឲ្យចេញប៉ុន្មានថ្ងៃទៅនុ៎ង ដូចជារឿងហ្នឹងកើតនៅឆ្នាំ១៩៧៣ទេ នៅពេលដែលមានចរន្តមួយនៃការបណ្ដេញពួកវៀតណាមចាកចេញពី -- លែងទទួលជំនួយ។ ហើយចាកចេញពីប្រទេសកម្ពុជាវិញ បាទ។ ហើយថាមិនវាយពួកវៀតណាមខាងជើងទេ គឺវាយពួកណ្ឌានពាន។ ហើយនេះជាឯកសារដែលពីមុនមក អ៊ីចឹងបែបវា -- កាលបរិច្ឆេទនេះទំនងជាខុសគ្នាឆ្ងាយ។ ហើយចំណែកឯលោកមេធាវី វ៉ិចទ័រ កូប៉េ ផ្ទុះបញ្ចាំងអម្បាញ់មិញនេះ គឺរឿងកើតឡើងក្រោយ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយ។ ខ្ញុំយល់ថាសក្ខីកម្មរបស់គាត់ គឺគាត់បង្ហាញភស្ដុតាងថា ទទួលបានជំនួយពីវៀតណាមពីឆ្នាំ៧៤។ ឯសំណួរខ្ញុំនេះ <ច្បាស់ណាស់គឺ>ក្រោយ<ខែមេសា> ឆ្នាំ១៩៧៥។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បើមិនច្បាស់ទេ ខ្ញុំសូមបញ្ជាក់ឡើងវិញឲ្យបានច្បាស់ លោកសាក្សី។ លោកសាក្សី ខ្ញុំកំពុងតែសួរ<>លោក ពាក់ព័ន្ធទៅនឹងចម្លើយ<របស់>ទាហានម្នាក់មកកងពល៩២០ ក៏ដូចរបាយការណ៍របស់ សុន សេន <រាយការណ៍ជូន>គណៈអចិន្ត្រៃយ៍។ ខ្ញុំអាន<សម្រង់ចេញពី>សារទូរលេខមួយនៅ<ដើម>ឆ្នាំ១៩៧៦។ សំណួរខ្ញុំនេះ គឺវាពាក់ព័ន្ធទៅឆ្នាំ៧៦ និង ឆ្នាំ៧៧។ ខ្ញុំអត់សួរលោកអំពីអ្វីដែលកើតឡើងនៅឆ្នាំ៧៤ ឬក៏មុនឆ្នាំ៧៤នោះទេ។ អ៊ីចឹងសូមឲ្យច្បាស់ថា សំណួររបស់ខ្ញុំនេះ គឺតើលោកនៅតែរក្សាចម្លើយរបស់លោកថា ឆ្នាំ៧៦, ៧៧ <តើកងទ័ព>កងពលកម្ពុជាប្រជាធិបតេយ្យទេ ដែលចាប់ផ្ដើមវាយប្រយុទ្ធទៅលើវៀតណាមមុននោះ? លោកនៅតែប្រកាន់ជំហរ និងចម្លើយរបស់លោកនេះដដែលអ៊ីចឹងឬ?

[១៥:១៨:៤០]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ព្រោះត្រង់នេះ ខ្ញុំសូមជម្រាបនិយាយជាការពិត។ អ្នកដែលធ្លាប់រស់នៅជាមួយខ្ញុំ ក៏គាត់ធ្វើទាហានដែរ ហើយគាត់ពិការជើងម្ខាងទៀត នៅក្នុងពេលប្រយុទ្ធគ្នានោះឈ្មោះ លោក ជ្រិន ប៉ុន្តែគាត់ស្លាប់បាត់ហើយឥឡូវ។ គាត់បានទៅចូលវាយហ្នឹង គឺមិនមែនវៀតណាមវាយយើងទេ គឺយើងវាយបណ្ដេញវៀតណាមដែលយើងដេញពីរបីសគាត់មិនទៅ និយាយគ្នាឲ្យចំអ៊ីចេះ។ ដេញហើយ គាត់នៅតែនៅ គាត់ដូចថា ដីកអីវ៉ាន់គាត់មិនទាន់អស់។ ដេញហើយពីរបីដងហើយនៅតែនៅ។ អ៊ីចឹងដល់ពេលក្រោយមក គេវាយមែន។ នេះមិនមែនវៀតណាមមកវាយខ្មែរនៅក្នុងទឹកដីខ្មែរទេ ប៉ុន្តែគ្រាន់តែខ្មែរវាយវៀតណាមនៅក្នុងទឹកដីខ្មែរ បាទ។ ហ្នឹងទី១។ ទី២ នៅអូរហ៊ុច ក៏ដូចគ្នា។ ហើយទី៣នេះ គឺវាយនៅភ្នំចុងដាក់ដាំ អាហ្នឹងយើងក៏មានស្លាប់ខ្លះ គេមានស្លាប់ខ្លះ។ កន្លែងនុ៎ង ពិបាកសន្និដ្ឋានដែរ ព្រោះអស់លោកប្រហែលជាអត់ជ្រាបពីបញ្ហារឿងព្រំប្រទល់ដី ដីត្រង់កន្លែងនុ៎ងទេ។ ដីកន្លែងនុ៎ង គឺយើងបានធ្វើផ្លូវពីជំនាន់បារាំងមក គេហៅកន្លែងនុ៎ង ជាស្ពាបពងជា(?) ក្បាលអូរហ៊ុច និងក្បាលអូរតាង។ ឥឡូវកន្លែងហ្នឹងក៏នៅមានការពាក់ព័ន្ធពីរឿងដីធ្លីហ្នឹងដែរ ដោយសារអី? ដោយសារបារាំងគូរផែនទី គូរម្ដងដាក់អូរហ៊ុច អូរតាង។ អ៊ីចឹងបច្ចុប្បន្ននេះ ចូលទៅអូរតាង វាចូលដីខ្មែរយើងច្រើន។ កន្លែងហ្នឹងវានៅក៏គិតម្យ៉ាង វានៅក្នុងទឹកដីរបស់វាដែរ គិតម្យ៉ាង បើយើងប្រកាន់ថា អូរត្រាងជាទឹកដីរបស់យើង យើងថាវៀតណាមយកទឹកដីយើង។ ប៉ុន្តែខ្មែរក្រហមហេតុអីបានទៅវ៉ៃៗកន្លែងហ្នឹង? អ៊ីចឹងគេនៅហ្នឹង គេមាន

បន្ទាយគេ មានស្អីគេត្រឹមត្រូវ យើងទៅវ៉ៃគេ។ អ៊ីចឹងសួរថា តើគេមកវ៉ៃយើងដែរឬអី? ត្រង់នេះសូមអស់លោកជួយវិភាគ។ ខ្ញុំមិនមែនជាកាន់ជើងខាងណាទេ ប៉ុន្តែការពិតអ៊ីចឹង ខ្ញុំថាអ៊ីចឹងទៅ។ សូមអស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរបញ្ជាក់ចំណុចមួយទេ។ តាមពាក្យរបស់លោក តើអ្វីដែលលោកកំពុងតែនិយាយនេះនៅក្នុងឆ្នាំណា? សូមបញ្ជាក់ឆ្នាំ។ តើកងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយប្រហារទៅលើវៀតណាមហ្នឹង តើក្នុងឆ្នាំណា?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ឆ្នាំ -- ចុងឆ្នាំ៧៧ បាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <>ខ្ញុំសុំសួរបញ្ជាប់ត្រង់ចំណុចនេះ ដោយអានសម្រង់ចេញពីសារទូរលេខពីរផ្សេងទៀតទាក់ទងទៅនឹងព្រឹត្តិការណ៍នេះដែរ។ ទី១ គឺ E3/1099 ជាសារទូរលេខ ចុះថ្ងៃទី០៩ មិថុនា ឆ្នាំ៧៧ ចេញពីការិយាល័យនយោបាយនៃកងពល៩២០ ហើយក៏ចេញពី សុន សេន នេះ <ភាសាអង់គ្លេស> ERN 00509691, ខ្មែរ 00376547, បារាំង 00519863។ <> ឈ្មោះ សាន បានរាយការណ៍ទៅឲ្យ សុន សេន ដូចតទៅ៖ “ថ្ងៃទី០២ ខែមិថុនា <មុខសញ្ញា៩១> នៅអូរលាវ <>យន្ត<ហោះ>យួនធុនទ្រង់ជ្រូកបានហោះចូលដីយើងចម្ងាយ<ប្រហែល>បួន<គីឡូម៉ែត្រ>ពីព្រំដែន។ មុខសញ្ញា៩២ ក្រោយពីយើងវាយឡាន<វា>ឆេះ យន្តហោះវៀតណាមធុនជើង<ស្ពោក> បានមកទម្លាក់គ្រប់បែក និងបាញ់រះនៅកន្លែងនោះ។ យើងចាប់បានប្រជាជនជាវៀតណាមបួនគ្រួសារ និងដំរីបីក្បាល តែប្រគល់ឲ្យទៅមូលដ្ឋានហើយ។” នេះគឺជាសារទូរលេខចុះខែមិថុនា ៧៧។ មួយទៀតគឺ ឯកសារ E3/1030, អង់គ្លេស <00324806>, ខ្មែរ <><00033312> <និងភាសាបារាំង 00623150> គឺ៖ “<នៅអូរផ្លាយ ពួកវា>(វៀតណាម)ចូលមកចម្ងាយ ២០ម៉ែត្រ ចូលក្នុងដីយើង ដើម្បីកាប់ឫស្សី។ យើងបានវាយពួកវាស្លាប់ និងរបួសមួយចំនួន នៅថ្ងៃទី១៧ ខែ<មិថុនា> ៧៧។ ហើយយើងបន្តវាយនៅព្រឹកថ្ងៃទី ១៨ ខែ<មិថុនា> ៧៧ នេះទៀត <ដោយបានសម្លាប់ និងធ្វើឲ្យពួកវារងរបួសជាច្រើន>។ មានពួកវា<មាន>ជាង១០០នាក់ ហើយមកដល់ពេលនេះ ពួកវាអត់ទាន់ដកចេញទេ។ ហេតុដូច្នេះយើងចាត់ចែងកម្លាំងយើងថែម ហើយវាបានចូលដីយើងចំនួន ៥០០ម៉ែត្រ។ យើងអត់មានគ្រោះថ្នាក់អីទេ។” លោកសាក្សី សារទូរលេខទាំងពីរហាក់បង្ហាញឲ្យឃើញថា គឺវៀតណាមទេ ជាអ្នកឈ្លានពានចូលក្នុងដីខ្មែរ ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កងពល៩២០ហ្នឹង គឺជាអ្នកការពារទប់ស្កាត់កុំឲ្យ<វៀតណាម>ឈ្លានពានចូលមកកម្ពុជា។

[១៥:២៤:៤៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យមេធាវីសួរសំណួរដោយកុំអាលបកស្រាយទៅលើភស្តុតាងណាមួយ។ នេះ<អាច>ជា<ការបកស្រាយរបស់គាត់ទៅលើ>សារទូរលេខ<នោះ ប៉ុន្តែទូរលេខនោះសរសេរថា> "វៀតណាមបានចូលមកក្នុងដីខ្មែរ ២០ម៉ែត្រ ហើយកាប់ឫស្សី <ជាការឆ្លើយតប>ខ្មែរក្រហមក៏ចាប់ផ្តើមវាយប្រយុទ្ធហ្នឹងសម្លាប់<ពួកគេ>"។ <វាអត់មានន័យដូចដែលគាត់បកស្រាយនោះទេ។> អ៊ីចឹង គាត់អាចសួរ<សាក្សីអំពីអ្វីដែល>សារទូរលេខនេះ<និយាយ> ប៉ុន្តែមិនត្រូវយកឃ្លាមួយមកបញ្ជាក់អ៊ីចឹងទេ។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** <ទូរលេខនេះ>បញ្ជាក់ថា "<>ចូលដល់៥០០ម៉ែត្រឯណោះនៅក្នុងដីយើង"។ ខ្ញុំនឹងមិនសួរបញ្ជាក់អំពីភស្តុតាងនេះទេ តែសួរថាតើលោកយល់យ៉ាងដូចម្តេចចំពោះសារទូរលេខទាំងពីរនេះ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ រឿងនេះ រឿងសារទូរលេខនេះខ្ញុំអត់យល់បាទ។ ពីព្រោះខ្ញុំក៏មិនធ្លាប់ឮដែរ បើខ្ញុំនៅការដ្ឋានរយ៉ នៅហ្នឹងជួនកាលមានព័ត៌មានពីថ្នាក់លើដែលឲ្យដំណឹងបានទើបដឹង ហើយរឿងអ៊ីចឹងៗដូចជាមិនដែលដឹងទេ សូមទោស។

**ស៖** តើនេះដោយសារតែគេដកលោកចេញនៅខែកុម្ភៈ ឆ្នាំ១៩៧៧ ទើប<លោក>មិនដឹងអំពី<ព្រឹត្តិការណ៍អ្វីទាំងអស់>ពាក់ព័ន្ធទៅហ្នឹងការឈ្លានពានពីសំណាក់វៀតណាម?

**ឆ៖** អាចថាអ៊ីចឹងក៏បាន ពីព្រោះអត់សូវមានព័ត៌មាន អត់សូវមានអីប៉ុន្មានទេ។ បានបើគេមិនប្រកាស បើគេមិនធ្វើមីទីង យើងអត់ដឹងទេ។ បាទសូមអរគុណ។

[១៥:២៧:០១]

**ស៖** ខ្ញុំយល់ហើយលោក ក៏ប៉ុន្តែមុនខែកុម្ភៈ ៧៧ លោកមានតួនាទីមុខតំណែងគឺជាអនុប្រធានមន្ទីរស្រុក ប៉ុន្តែក្រោយខែកុម្ភៈ ៧៧ លោកក៏ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនខ្លួនឲ្យទៅធ្វើការ។ តើ<ជា

ការសមរម្យទេដែលនិយាយថា> ក្រោយរយៈពេលនេះមកលោកមិនដឹង<អំពីល្បិចកលរបស់កងទ័ពវៀតណាម>ឈ្លានពានចូលទៅក្នុងទឹកដីកម្ពុជា<ប្រជាធិបតេយ្យទេ>?

**ឆ៖** បាទ ដឹងតាមរយៈគេប្រាប់ជូលេង ឬតាមគ្នាឯងឬក៏តិចតួច ប៉ុន្តែឲ្យដឹងរឿងព័ត៌មានពិត វាមិនអាចទេបាទ ពីព្រោះអត់មានពីណាឲ្យដំណឹងយើងទេបាទ។

**ស៖** ខ្ញុំសូមបន្តទៅនិយាយអំពីឈ្មោះ ស្វាយ ហើយនិង ប្ញលី។ លោកបានឆ្លើយថាអ្នកទាំងពីរនេះត្រូវបានគេចោទប្រកាន់ថាចូលដៃជាមួយវៀតណាម។ ឥឡូវខ្ញុំសូមអានចម្លើយរបស់លោកផ្ទាល់ ហើយចាំសួរបញ្ជាក់តើលោកចង់និយាយថាម៉េចចំពោះចម្លើយទាំងនេះ។ ចម្លើយឆ្លើយជូន<>មជ្ឈមណ្ឌល<ឯកសារ>កម្ពុជា គឺខ្មែរ 00042477, អង់គ្លេស 00711216, បារាំង 00727134 លោកនិយាយអំពីឈ្មោះ ប្ញលី លោកបានឆ្លើយដូចតទៅ៖ “<>គាត់<ធ្វើគិលានុបដ្ឋាយិការហូត។ ចំពោះការ>ទំនាក់ទំនងជាមួយវៀតណាម ដូចដែលខ្ញុំនិយាយអីចឹង មានសកម្មភាពខ្លះគេឃើញថាអីចឹង។ ប្ដីរបស់គាត់ពិតណាស់ថាបាន<ធ្វើដូច្នោះ។ គាត់បាន>រៀបចំនូវការទាក់ទងគ្នា។ <គេបានតាមដានជនជាតិ>វៀតណាម<រហូតដល់>ព្រំដែន។ គាត់គឺជាមនុស្សម្នាក់ដែលលាក់ ដែលលួចបញ្ចូលយួនបង្កប់<ក្នុង>ខេត្ត ក៏ប៉ុន្តែរឿងដែលចាប់ប្រពន្ធ គឺមកពីប្ដីធ្វើបាបទេ រកបាញ់គេសម្លាប់។” តើលោកចង់មានន័យថាដូចម្ដេច <> លោកថា គឺឈ្មោះ ស្វាយ ដែលជាអ្នកបញ្ចូលបង្កប់យួន<ស៊ើបការណ៍>នៅក្នុងខេត្ត?

**ឆ៖** បាទខ្ញុំសូមឆ្លើយត្រង់ចំណុច ស្វាយ។ ស្វាយ គាត់ជាលេខាស្រុកកោះញែក ខ្ញុំអត់បានដឹងថា គាត់ជាអ្នកបង្កប់ទេ ប៉ុន្តែការណ៍ដែលចោទប្រកាន់របស់តាហម តាខាំ ភួន តាសារុន គឺចោទថាស្វាយ ជាអ្នកបង្កប់មនុស្សវៀតណាម។ ប៉ុន្តែដល់ក្នុងពេលនោះ បានសួរ ពេលគេប្រជុំសួរទៅ ស្វាយបានសារភាពថាអត់ទេ។ ពេលយប់ហ្នឹង ស្វាយ បានបាញ់សម្លាប់កម្មាភិបាលពីរនាក់ ហើយរបួសម្នាក់សម្លាប់ឈ្មោះគឺ មួយ ជាលេខាស្រុកអូររាំង, ដាំងមួយ គាត់ជាលេខា ឬក៏ជាប្រធាន ខ្ញុំអត់ដឹងដែរ ក្នុងស្រុកពេជ្រចិន្តា ព្រោះកាលមុនគេដូរច្រើនពេកខ្ញុំភ្លេចបាត់ហើយ។

[១៥:៣១:០៣]

ចុងក្រោយមក ស្វាយ ត្រូវរត់រួច បន្ទាប់មកបានបាញ់អ្នកកាន់ម៉ាស៊ីនភ្លើងមួយ។ អ្នកកាន់ម៉ាស៊ីនភ្លើងហ្នឹងក៏បាញ់តទល់វិញ ក៏គាត់ត្រូវរបួស ហើយគាត់ចងកខ្លួនគាត់ស្លាប់ទៅ។ តែបើតាមខ្ញុំសង្កេតមើល ស្វាយ ទាក់ទងនោះ គឺមិនមែនវៀតណាមបច្ចុប្បន្នទេ គឺជាហ្វុលរ៉ូទេ ព្រោះខ្ញុំដឹងតាមរយៈអ្នកធ្លាប់នៅជាមួយគាត់ ដោយនិយាយប្រាប់ខ្ញុំខ្លះថា គាត់ទាក់ទងពួកហ្វុលរ៉ូទេ ប៉ុន្តែហ្វុលរ៉ូហ្នឹង ក៏វៀតណាមដែរ

បាទ។ បាទ ប៉ុន្តែគេហ្នឹងគេអត់ដឹងថា គាត់ហ្នឹងទាក់ទងវៀតណាមកុម្មុយនីស្ត ឬក៏ទាក់ទងវៀតណាមសេរី ប៉ុន្តែគេចោទប្រកាន់ តែមិនទាន់អី គាត់បាញ់មុន។ អ៊ីចឹងបានន័យថា ជាគាត់ហ្នឹងក្បត់ពេញទីហើយបាទ។ សូមអស់។

**ស៖** នេះជាចម្លើយមួយដ៏វែង ប៉ុន្តែខ្ញុំខ្លាចតែលោកមិនទាន់ឆ្លើយនឹងសំណួរខ្ញុំឲ្យបានចំនៅឡើយ។ ឥឡូវខ្ញុំសួរឡើងវិញ តើលោកចង់មានន័យថាដូចម្ដេចនៅពេលដែលលោកថា គាត់គឺ ស្វាយ នេះ គឺជាអ្នកបញ្ចូលបង្កប់គិញយួននៅក្នុងខេត្ត។ តើ ស្វាយ បានធ្វើអ្វីនៅពេលហ្នឹង នៅពេលដែលលោកនិយាយថា គាត់ហ្នឹងបានបញ្ចូលបង្កប់គិញយួន នៅក្នុងខេត្តហ្នឹង? តើ ស្វាយ ហ្នឹងបានធ្វើអីខ្លះដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៣៣:០០]

**លោក ខេល លីសាក់៖**

លោកប្រធាន <>គឺថាខ្ញុំជំទាស់នឹងសំណួរនេះ សំណួរច្រំដែល។ គាត់បានឆ្លើយសំណួររួចហើយ គាត់ថា គេប្រាប់គាត់ ដោយឈ្មោះ ហម ហើយនិងសារុន <នោះ>គឺជាការចោទប្រកាន់ប្រឆាំងនឹង ស្វាយ ទេ។ នេះហើយជាចម្លើយទៅនឹងសំណួរនោះ។ ហើយ<>មេធាវីការពារក្ដី<មិនចង់បានចម្លើយនោះទេ ដូច្នេះហើយគាត់>សួរសំណួរដដែលហ្នឹងម្ដងទៀតទៅសាក្សី តាមពិតគាត់ឆ្លើយរួចហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាជាចម្លើយវែង ហើយខ្ញុំមិនបានឮចម្លើយនេះទេ។ ហើយខ្ញុំនឹងសួរគាត់ឲ្យគាត់បំភ្លឺចម្លើយរបស់គាត់ហាក់ដូចជាបញ្ជាក់ថា គាត់ដឹងដោយខ្លួនឯងអំពីរឿង ស្វាយ ដែលបានបង្កប់ជនជាតិវៀត-ណាមនៅក្នុងខេត្ត។

**ស៖** លោកសាក្សីតើលោកដឹងរឿងហ្នឹងដោយខ្លួនឯង ឬក៏<លោកដឹងរឿង>នេះ<ដោយសារតែ>ជាការចោទប្រកាន់ប្រឆាំងនឹង ស្វាយ ទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទសូមបញ្ជាក់ម្ដងទៀត សូមឲ្យច្បាស់។ ស្វាយ គឺជាអ្នកដែលទាក់ទងវៀតណាមមែន ប៉ុន្តែអ្នកស្រុកនៅកន្លែងហ្នឹងទាំងអស់គ្នា នៅមានការសង្ស័យដដែលហ្នឹង មិនទាន់ប្រាកដថា ស្វាយ ទាក់ទងវៀតណាមយៀកកុង ឬក៏ទាក់ទងវៀតណាមហ្ស៊ុលវ៉ូទេ ព្រោះបើតាមអ្នកនៅជាមួយគ្នា ដែលគេ

ធ្លាប់ជូនបាយ ជូនទឹកនោះ គឺប្រាប់ថា ពួកហ្នឹងជាជនជាតិរដែ ហើយមិនមែនយួនទេ”។ បាទ អ៊ីចឹងទេខ្ញុំក៏មិនច្បាស់ដែរ សូមលោកអធ្យាស្រ័យបាទ។

[១៥:៣៥:០០]

**សៈ** ខ្ញុំអានជូនលោក គឺសេចក្ដីដកស្រង់ពីទាហានរបស់កងពល៩២០ គឺសេចក្ដីសង្ខេបរបស់ចម្លើយរបស់គាត់ ដើម្បីឲ្យខ្ញុំអាច<ពិនិត្យពិច័យលើបញ្ហានេះបន្ថែមទៀត> គឺថា E3/7960។ លោកប្រធាន អង់គ្លេស ERN គឺ <00450295>, ខ្មែរ 00851666, បារាំង 0073899<*(ស៊ីក)*>។ <កងទ័ព>កងពល<៩២០> <>ម្នាក់<នេះ>បាននិយាយពីអ្វី<ដែលគាត់ហៅ>ថា ជាចលនា ខាំ ភូន។ ហើយគាត់បានពាក់ព័ន្ធក្នុងការបង្ក្រាបចលនាបះបោរ ទាក់ទងទៅនឹង ខាំ ភូន។ គាត់និយាយដូចខាងក្រោមនេះ៖ “ខាំ ភូន<> បានយកវៀតណាមមកតាមរយៈ ស្វាយ ហើយគេបានលាក់វៀតណាមដោយសម្ងាត់<>នៅជិតភូមិ។”

ដូច្នេះលោកសាក្សី តើលោកអាចមានប្រតិកម្មអ្វីទៅនឹងសេចក្ដីដកស្រង់អំពីចម្លើយរបស់យោធាម្នាក់មកពីកងពល៩២០។ គាត់និយាយថា <ចលនា> ខាំ ភូន <ឬក៏ថា ខាំ ភូន>ប្រើ ស្វាយ ដើម្បីយក<គិញ>វៀតណាម <>មកចូលដីកម្ពុជាប្រជាធិបតេយ្យ<?>

**ឆៈ** បាទ ចំណុចនេះ ខ្ញុំដូចជាអត់បានដឹងទេ បាទ។ អត់ច្បាស់។ អត់ដឹងថា ខាំ ភូន ជាមួយ ស្វាយ គាត់ទំនាក់ទំនងដែរឬក៏អត់។ ឬក៏គេចេះតែចោទ ស្វាយ ទៅតែម៉េចទៅ មិនដឹង។ រឿងនេះ ខ្ញុំអត់ដឹង។ សូមទោស។ ជាការចោទប្រកាន់ទៅវិញទៅមក ពិបាកសន្និដ្ឋាន ពីព្រោះខ្ញុំក៏ជាមនុស្សធម្មតា អត់អាចសន្និដ្ឋានបានទេ បាទ។

**សៈ** លោកសាក្សី លោកទើបតែបញ្ជាក់នៅក្នុងពេលលោកឆ្លើយទៅនឹងសំណួររបស់ខ្ញុំ និយាយអំពីហ្វុលរ៉ូ។ តើ ហ្វុលរ៉ូ ហ្នឹង យោង មានអ្វីជាប្រាកដដែលលោកដឹងនោះ?

**ឆៈ** បាទ បើតាមសភាពការណ៍នៅពេលនោះ ហ្វុលរ៉ូ មានសារចេញចូលតាមហ្នឹង បានទំនាក់ទំនងមកតំបន់១០៥ហ្នឹង។ ហើយរហូតបានដឹកនឹងកប៉ាល់ហោះមកភ្នំពេញម្ដងដែរ។ ខ្ញុំបាទបានចម្លងនៅអូរច្បារនេះ មានចំនួនបួន ដប់នាក់ដែរ។ ពេលមុនដំបូង គេចាប់ហ្វុលរ៉ូ ហ្នឹងជូនកាល មានសម្លាប់ចោល។ ដល់ក្រោយមក គេអត់សម្លាប់ទេ គេបែរយកហ្វុលរ៉ូហ្នឹង ដកមកតាមកប៉ាល់ហោះមកនេះ មកភ្នំពេញវិញ។ រយៈពេលមួយអាទិត្យ ឃើញពួកគាត់ហ្នឹងជូនទៅវិញ។ ជូនទៅវិញ ខ្ញុំទៅចម្លងឲ្យទៀត។ ចម្លងនឹងទូក បាទ ដោយសារខ្ញុំនៅកំពង់ទឹក ខ្ញុំក៏ចម្លងឲ្យគេទៅ។

01225784



[១៥:៣៨:៤៣]

ពេលនោះ ខ្ញុំឃើផង។ ហើយខ្ញុំឃើញពេលមកវិញហ្នឹង ឃើញពួកគាត់មានឯកសណ្ឋានសម្លៀកបំពាក់ត្រឹមត្រូវ និងមានពាក់នាឡិកា ពាក់អីវាងហំហានអីដែរ។ ពេលគាត់ទៅដំបូង គាត់ខោមិនខោ អាវមិនអាវអីចឹង បាទ។ ដល់អីចឹងចាប់ពីហ្នឹងមក បានគេដឹងថា គេលែងមានបញ្ហាទំនាស់ ឬក៏ប្រកាន់ពួកហ្វុលរ៉ូហ្នឹងហើយ។ ហ្វុលរ៉ូ ជាកម្លាំងតស៊ូរបស់វៀតណាម។ ប៉ុន្តែមិនមែនតស៊ូសម្រាប់កម្ពុជាយើងទេ បាទ។ គាត់ គឺតស៊ូប្រឆាំងវៀតណាម បាទ។ សូមអស់។

**ស៖** មូលហេតុដែលខ្ញុំសួរលោកអំពីហ្វុលរ៉ូនោះគឺថា<ដោយសារ>លោក<បាន>ផ្តល់ភស្តុតាងពាក់ព័ន្ធទៅនឹងសកម្មភាពដែល<គេចោទប្រកាន់> ស្វាយ ហើយនិង ខាំ ភួន ក្នុងឆ្នាំ១៩៧៧។ <ពេលដែលលោកនិយាយអំពីហ្វុលរ៉ូ> តើលោកសំដៅទៅរកសកម្មភាពក្នុងឆ្នាំ១៩៧៧ ឬក៏<និយាយសំដៅទៅ>ចលនារបស់ហ្វុលរ៉ូ តាំងពីឆ្នាំ១៩៧៣ ឬ១៩៧៤?

[១៥:៤០:០០]

**ឆ៖** បាទ សូមទោសត្រង់នេះ ហ្វុលរ៉ូ បើតាមការពិត ហ្វុលរ៉ូ គាត់បង្កប់នៅខេត្តមណ្ឌលគិរីតាំងយូរយាងណាស់ហើយ។ រហូតដល់កាលជំនាន់សម្តេចឪ បានទុកទឹកដីនៅខេត្តមណ្ឌលគិរីសម្រាប់ហ្វុលរ៉ូមួយកន្លែងដែរ។ តែ ហ្វុលរ៉ូ ក្រោយមកបានរត់ភៀសខ្លួនលាក់ជាមួយយៀកកុងនេះ នៅតាមព្រំប្រទល់ដែន។ ទីចុងក្រោយបំផុត យើងខ្ញុំអត់ដឹងថាហ្វុលរ៉ូហ្នឹង គេធ្វើសកម្មភាពទំនាក់ទំនងជាមួយខ្មែរក្រហមយ៉ាងនេះយ៉ាងនោះអត់ដឹងអីទេ បាទ។ សូមអស់។

**ស៖** ឥឡូវនេះ ខ្ញុំអានជូនលោកអំពីអ្វីដែលលោកនិយាយខ្លួនឯងអំពីហ្វុលរ៉ូនេះទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ជាចម្លើយរបស់លោក។ ខ្មែរ 00042468, អង់គ្លេស 00711204, បារាំង 00727126។ លោកនិយាយដូចខាងក្រោមនេះ ខ្ញុំសូមដកស្រង់៖ "នៅខេត្តរតនគិរី ប្រហែលជាមនុស្ស<និងកងទ័ពជាង>៣.០០០នាក់<>ត្រូវបានគេសម្លាប់ ដោយសារ<>ហ្វុលរ៉ូ<បានបញ្ជាឲ្យ>អាមេរិក<>ទម្លាក់គ្រាប់បែកបេ៥២<នៅកណ្តាលក្រុង>។ ពួកហ្វុលរ៉ូនេះ<ត្រូវ>បាន<>វៀតណាម<កម្ទេចចោល។ ទោះយ៉ាងណា ហ្វុលរ៉ូ បាន>វាយប្រយុទ្ធ<ឯករាជ្យ>វៀតណាម<កណ្តាល។ ពួកគេចង់ដណ្តើមយកទឹកដីចម្ប៉ាមកវិញ។ ពួកគេមិនចង់ឲ្យ>វៀតណាម<ជិះជាន់ពួកគេទេ>។ <ក្នុងអតីតកាលចម្ប៉ា ជាកម្មសិទ្ធិរបស់ជនជាតិចាម ចារ៉ាយ និងរដែ អស់រយៈពេលជាង>៥០០ឆ្នាំ<>។ <ដោយសារតែគ្មាន>ឯកសារ<រក្សាទុក ពួក>គេ<បានក្លាយ>ជា<ជនជាតិវៀតណាម។ ពួកនេះ>ប្រហែល<ជាង>

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

៣.០០០ ទៅ៤.០០០ <ហៅថាមួយវរសេនាតូច បានបោះ>ទីតាំងនៅកម្ពុជា <>នៅ<ភ្នំ>ដោះក្រមុំ។ <ពួកគេគាំទ្រដោយអាមេរិក។>" តើនេះជាអ្វីដែលលោកបាននិយាយទៅអ្នកស្រាវជ្រាវរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាដែរឬទេ លោកសាក្សី?

[១៥:៤២:៥៣]

**ឆ៖** បាទ សូមជម្រាបដែលថា គាត់អ្នកយកព័ត៌មានប្រហែលជាគាត់និយាយអត់សូវចំទេ។ ខេត្តរតនគិរីគឺជាខេត្តរតនគិរី។ ខេត្តមណ្ឌលគិរីគឺជាខេត្តមណ្ឌលគិរី។ អ៊ីចឹងហ្វូលរ៉ូវានៅពីរកន្លែងហ្នឹង។ បើគាតនិយាយរួមអ៊ីចឹង វាដូចជាជាន់ ឃើញតែមួយកន្លែងទេ ហើយអាវានឹងបាត់មួយកន្លែងទៀត។ អ៊ីចឹងខ្ញុំសុំអត្ថាធិប្បាយបន្តិចកន្លែងនេះ។ ឆ្នាំ៧០ ពេលដែលវៀតណាមចូលវ៉ៃខេត្តរតគិរី គឺមានហ្វូលរ៉ូនៅហ្នឹង ហើយបានគាំទ្រទាហាន លន់ នល់ ទប់ទល់ជាមួយនឹងវៀតណាមយៀកកុង។ អ៊ីចឹងទេ ពេលហ្នឹងទាហាន លន់ នល់ ថាទាហានខ្មែរ គាត់ថាមិនបាច់យើងតតាំងទេ បើតតាំងក៏យើងអត់ឈ្នះគេដែរ។ ប៉ុន្តែហ្វូលរ៉ូថាអត់ទេ ត្រូវតែវ៉ៃ។ អ៊ីចឹងហ្វូលរ៉ូហ្នឹង គឺគាត់គាំទ្រអាមេរិកាំង។ គាត់ហៅកាប៉ាល់ហោះអាមេរិកាំងរោយបេ៥២ ទម្លាក់គ្រប់បែកនៅក្នុងទីក្រុងហ្នឹងតែម្តង។ អ៊ីចឹងបូកទាំងគាត់ បូកទាំងវៀត-ណាម បូកទាំងប្រជាជន ត្រូវស្លាប់ច្រើនណាស់។ អ៊ីចឹងទេ ផ្ទះសម្បែងឡើងអស់រលីង អត់មានសល់ទេនៅខេត្តរតនគិរីហ្នឹង។ ឯចំណែកហ្វូលរ៉ូ នៅខេត្តមណ្ឌលគិរីភ្នំដោះក្រមុំនេះ គឺមួយប៉ាត់យ៉ុង បើយើងនិយាយថា មួយវរសេនាតូចទេ។ គាត់ប្រហែលជាមាន ៣០០នាក់ជាង ឬក៏៤០០ នាក់ជាង។ អ៊ីចឹងពួកគាត់ហ្នឹង មានលោកតា ខៀវ ប៊ុន បានផ្តល់ទីតាំងមួយនៅខេត្តមណ្ឌលគិរី បាទ។ ពេលដែលវៀតណាមចូលវ៉ៃ ពួកគាត់ដកខ្លួនមុនបាត់ អត់បានតតាំងជាមួយនឹងយៀកកុងទេ។ ហើយតា ខៀវ ប៊ុន នៅហ្នឹងគាត់បានតតាំងតិចតួច ក៏គាត់ដកខ្លួនចេញទៅ អ៊ីចឹងមនុស្សស្លាប់ក៏វាតិច។ អ៊ីចឹងមណ្ឌលគិរីស្លាប់មិនដល់ ៦០០ផងហ្នឹង ពេលវ៉ៃគ្នា វាមិនដូចរតនគិរីទៅជាផេះបណ្តោយបាទ។ អ៊ីចឹងលោកស្តាប់ឲ្យបានពាក្យដែលខ្ញុំនិយាយនេះ។ បើនិយាយរួមៗអ៊ីចឹង ឃើញតែដោះក្រមុំ ឃើញតែមណ្ឌលគិរី អត់មានរតនគិរីទេ ពីព្រោះគេពេលហ្នឹង គេមានពីរកន្លែងដែលគេតាំងទ័ពហ្វូលរ៉ូហ្នឹង តាមដែលខ្ញុំដឹងពីព្រោះខ្ញុំអាយុទើប ១៧ឆ្នាំបាទ។

[១៥:៤៥:៣៧]

**ស៖** ខ្ញុំយល់ គឺមាន<អង្គការ>ហ្វូលរ៉ូ <មួយ ដែលគាំទ្រដោយអាជ្ញាធរអាមេរិក។> គឺគេវាយប្រហារប្រឆាំងនឹងវៀតណាម មុនឆ្នាំ<១៩៧៥។ ខ្ញុំដឹងរឿងនេះ>។ ប៉ុន្តែលោកនិយាយពីពាក្យហ្វូលរ៉ូ

នៅពេលដែលលោកឆ្លើយសំណួរខ្ញុំទាក់ទងទៅហ្នឹងហេតុការណ៍ឆ្នាំ១៩៧៧ ដែលធ្វើឲ្យខ្ញុំភ័ន្តច្រឡំ។ ខ្ញុំសួរថាតើ ចលនាហ្វុលរ៉ូ វាមានទំនាក់ទំនងអ្វីជាមួយនឹង ស្វាយ ហើយនិង ខាំ ភួន ដែលគេចោទថាពួកគាត់នាំគិញវៀតណាមចូលមកដែនដីកម្ពុជា<ប្រជាធិបតេយ្យ>កាលនោះនុះ?

**ធះ** ដូចខ្ញុំមានប្រសាសន៍អំម្បាញ់មិញខ្ញុំ ខ្ញុំអត់បានយល់ បាទត្រង់ ខាំ ភួន ជាមួយ ស្វាយ ទំនាក់ទំនងជាមួយវៀតណាមអត់ដឹងទេ។ ប៉ុន្តែដោយការចោទប្រកាន់របស់គេហ្នឹង គឺគេថា ខាំ ភួន ជាមួយ ស្វាយ ទាក់ទងដូចលោកមេធាវីមានប្រសាសន៍ ប៉ុន្តែចំណែកខ្ញុំ ខ្ញុំអត់ច្បាស់ទេបាទ។

**សះ** ខ្ញុំនឹងអានជូនលោក<នូវព័ត៌មាន>មកពី យោធា<>កងពល៩២០ គាត់និយាយអំពីហ្វុលរ៉ូក្នុងឆ្នាំ១៩៧៨ គឺថាឯកសារ <E3/7960>, ERN អង់គ្លេស 00450296, ERN ភាសា<បារាំង> 00763900, <ខ្មែរ> ERN 00851667។ គាត់និយាយថា "នៅក្នុងឆ្នាំ១៩៧៨ ចលនាហ្វុលរ៉ូ <បានទាក់ទងពួកយើង។> ឆ្នាំ១៩៧៨ គឺគេបានចាប់ពួក<ពួកហ្វុលរ៉ូ ហើយ>បញ្ជូនទៅភ្នំពេញ។ ពួកគេត្រឡប់មកវិញ គេមានមនុស្សច្រើន <ហើយ>នៅក្នុងក្រាំងតេះ<ពួកគេ>មាន<ទាហាន>ជាង ១០០ នាក់។ <វានឹង>មាន<ការលំបាកសម្រាប់>វៀតណាម<>ក្នុងការ<ចូលមក បើសិនជាប៉ុល ពត> បំពាក់អាវុធ<ឲ្យពួកហ្វុលរ៉ូទាន់ពេលវេលា។ ពួកគេខ្លាំង>។ <>ហ្វុលរ៉ូ គឺជាជនជាតិភាគតិចវៀត-ណាម។ <ខ្ញុំបានជួបពួកនៅឆ្នាំ១៩៧៩។ ពួក>គេមានបំណងចង់រំដោះប្រទេសជាតិ<របស់ពួកគេ> ហើយពួកហ្វុលរ៉ូក៏មាន រដែ ចារ៉ាយ និងជនជាតិកាហាផងដែរ"។ តើអ្វីដែលខ្ញុំអានធ្វើឲ្យលោកចង់ចាំឬដឹង<>ពីសកម្មភាពរបស់ហ្វុលរ៉ូក្នុងឆ្នាំ១៩៧៨ ដែរឬទេ?

[១៥:៤៨:២៤]

**ធះ** បាទខ្ញុំចង់ចាំខ្លះដែរ ពីព្រោះពួកគាត់ ពួកហ្វុលរ៉ូនេះអត់ឆ្ងាយពីមណ្ឌលគិរីទេ។ គាត់នៅក្នុងទឹកដីមណ្ឌលគិរីហ្នឹងតែម្តង ជាបោះទីតាំងនៅក្នុងព្រៃ ខ្មែរក្រហមនៅក្នុងព្រៃក៏ពួកហ្វូរ៉ូនៅក្នុងព្រៃជាមួយគ្នា។ គាត់ បើនិយាយឲ្យចំទៅគាត់នៅព្រំប្រទល់ជិតទៅខាងពាមអូរប្តាយ ភ្នំដំលៀងណោះបាទ។ សព្វថ្ងៃហ្នឹងកន្លែងទីតាំងរបស់គាត់ហ្នឹង ភាគច្រើន ដំរី គោព្រៃ យើងហ្នឹងអស់ដោយសារពួកគាត់ហ្នឹងច្រើនណាស់។ ប៉ុន្តែសកម្មភាពរបស់ហ្វុលរ៉ូដូចអត់មានធ្វើអ្វីជាមួយហ្នឹងខ្មែរក្រហមទេ ខ្ញុំអត់ដឹងដែរ។ សូមអស់។

**សះ** ឥឡូវនេះខ្ញុំទៅប្រធានបទផ្សេងទុកបញ្ហាហ្វុលរ៉ូត្រឹមនេះសិន ហើយនិយាយអំពីបញ្ហាដែលជាទាក់ទងទៅ<នឹង> អរិភាពដែលគេហៅថា "ក្រុមខ្មែរស"។ <លោកបានបញ្ជាក់ពី>ខ្មែរស នៅក្នុង

ឯកសារ E3/5178 កំណត់ហេតុស្តាប់ចម្លើយរបស់លោក។ ហើយក៏លោកបាននិយាយអំពី<ខ្មែរសនៅក្នុង>ឯកសារមួយ<>ដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ បាទ ឯកសារ E3/5636, អង់គ្លេស 00711205, ខ្មែរ <00042468> ដល់ 9, បារាំង 00727127 ហើយនិយាយ<អំពីខ្មែរសហើយលោក>ថា៖ “<នៅ>ឆ្នាំ១៩៧៣ <មានការបះបោររបស់ខ្មែរស>”។ តើលោកអាចជម្រាបតុលាការបាន<ទេ>ថាតើ<>ខ្មែរសហ្នឹង<ជាអ្វី?> តើ<ពួក>គេនៅមានសកម្មភាពដែរឬទេ ក្រោយឆ្នាំ១៩៧៥?

**ឆ៖** បាទ ចំណុចនេះ ខ្មែរស បើតាមខ្ញុំដឹង ដូចធ្វើសកម្មភាពពីឆ្នាំ៧៣ ដល់ ៧៥ ហ្នឹងឯង។ មកពី ៧៥ មកដល់ ៧៦-៧៧ ហ្នឹង ដូចអត់ឃើញមានខ្មែរសទេ វាចេញឃ្លួន ចេញ កា.ហ្សេ.បេ ឯណាឯណោះទៀត ដែលខ្ញុំមិនដែលធ្លាប់ឮ ធ្លាប់ស្គាល់ហ្នឹង បាទ។ ហ្នឹងត្រង់នេះ ខ្ញុំសូមជ្រាបតែប៉ុណ្ណេះ។

[១៥:៥១:៣០]

**ស៖** តើ<នរណាជា>ខ្មែរស? <>តើក្រុមខ្មែរសហ្នឹង<មាន>អ្វីខ្លះ? <តើនរណាជាសមាជិក? តើលោកដឹងអ្វីខ្លះអំពីរឿងនេះ>?

**ឆ៖** បាទ ខ្ញុំក៏មានការឆ្ងល់ៗ រហូតដល់ថ្ងៃហ្នឹង ព្រោះខ្មែរសអត់ឃើញមេ ឃើញកោយមិនដឹងកើតមកពីណាផង តាមការពិត ខ្មែរសកើតមកពីទាហានចាស់។ ប៉ុន្តែមិនដឹងជាមេកោយរបស់គេហ្នឹងជាអ្នកណា ខ្ញុំទល់រាល់ថ្ងៃនេះក៏មិនបានជ្រាបដែរបាទ។

**ស៖** តើលោកយល់ដូចម្តេច ដែលថាគោលបំណងរបស់ខ្មែរសហ្នឹង គេធ្វើអី? តើមានផែនការអី? តើគោលបំណងរបស់គេហ្នឹងធ្វើអ្វី លោកយល់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំដូចអត់យល់ ព្រោះកាលហ្នឹងគេបង្កើតជាសហករណ៍ ជាសហគមន៍ សហករណ៍គេហ្នឹង ដល់ពេលហ្នឹងមានភាពបះបោរ មានសភាពបះបោរខ្លះរត់ចូលព្រៃអ៊ីចឹងទៅ ប្រដាប់ដោយអាវុធមានតាមបាញ់ តាមចាប់អ៊ីចឹងទៅ កាប់សម្លាប់តាមភូមិ ជួនកាលចាប់បានតាមរយៈអ្នកភូមិហ្នឹងផងមានកាប់សម្លាប់ជាច្រើនទៅ។ ប៉ុន្តែ ដូចលោកបានសួរអ៊ីចឹងថា តើគោលបំណងរបស់គាត់នោះ ខ្ញុំបាទអត់ៗជ្រាបទេ អត់ដឹងទាល់តែថ្ងៃហ្នឹង មិនដឹងមេកោយគេហ្នឹងអ្នកណាផងបាទ។ យើងអត់ដឹង អត់ជ្រាប ចង់សួរគេសួរឯងដែរថា ខ្មែរសហ្នឹងវាកើតមកពីណា តើអ្នកណាអ្នកចលនា? អត់ដឹងទេ។ អ៊ីចឹងសូមជ្រាបលោកប៉ុណ្ណេះ។

**ស៖** សំណួរមួយចុងក្រោយអំពីប្រធានបទនេះ លោកសាក្សី បន្ទាប់មក ខ្ញុំនឹងត្រឡប់ទៅនឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចម្លើយរបស់លោកវិញ បទសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត គឺ E3/5178, ខ្មែរ ERN 00197857, បារាំង 00485181, អង់គ្លេស 00274096។ លោកនិយាយអំពី ជ័យ <សាថន> ជាមេឃុំ ហើយលោកនិយាយថា៖ "មេឃុំ ត្រូវចាត់ទុកថាជាជនប្រតិកិរិយា ហើយក៏ជាខ្មែរស"។ តើនេះជាអ្វីដែលលោកបានឮ? ក្នុងករណីដែលលោកឮ តើលោកឮអ្វីខ្លះក្រៅពីហ្នឹង ដែលនាំឲ្យលោកឆ្លើយបែបនោះ?

[១៥:៥៥:00]

**ឆ៖** ខ្ញុំសូមជម្រាបថា លោក ជ័យ សាថន មិនមែន ជ័យ សាតាន់ ទេ។ ជ័យ សុថន -- សាថន។ លោក ជ័យ សាថន ជាអតីត ជាកូនរបស់មេឃុំ អ៊ុត។ ពីដើមមក គេនៅខេត្តមណ្ឌលគិរី គឺឃុំដេអេ ស្រុកអូររាំង ខេត្តក្រចេះ អត់មែនខេត្តមណ្ឌលគិរីទេ។ ទើបនឹងកើតឆ្នាំ១៩៦២នេះ ទើបយកឃុំដេអេនេះជាឃុំដដែល ហើយស្រុកច្បារវិញ។ អ៊ីចឹងលោក ជ័យ សាថន គាត់អតីត គាត់ជាកូនមេឃុំខ្មែរក្រហមបានចាប់គាត់ដាក់ខ្នោះឃ្នាងទាំងពីរបីនាក់បងប្អូន។ គាត់ក៏បានធាក់ខ្នោះរួចទៅ រត់បានពីរនាក់ ម្នាក់ត្រូវស្លាប់នៅនឹងកន្លែងដែលគ្នារត់មិនរួច។

អ៊ីចឹងទេ ខ្ញុំសូមជម្រាបលោកថា លោក ជ័យ សាថន នុ៎ងដែលគេចោទគាត់ជាខ្មែរសនោះ សព្វថ្ងៃគាត់នៅរស់ទេ។ គាត់មិនទាន់យល់ថា ខ្មែរសជាស្អីផង។ ខ្លួនគាត់នេះ ក៏មិនដឹងថាខ្មែរសហ្នឹងជាស្អីផង។ កុំថាឡើយដល់តែខ្ញុំ ដូចគាត់ថាអ៊ីចឹង គេចេះតែចោទថាគាត់ជាខ្មែរស ប៉ុន្តែគាត់មិនដឹងថា ខ្មែរសហ្នឹងជាស្អីផង បាទ។ ហើយគេចេះតែចាប់គាត់។ អ៊ីចឹងសូមជម្រាបតែប៉ុណ្ណឹង។ អ៊ីចឹងរឿងរ៉ាវខ្មែរសដូចអត់មានពីណាដឹងមេកោយអីផង។ សូមអស់។

**ស៖** តើលោកធ្លាប់ឮឈ្មោះ ចាន់ ចក្រី ដែរឬទេ, ឈ្មោះ ឈូក, ឈ្មោះ យ៉ា, កែវ មាស? តើលោកធ្លាប់ឮឈ្មោះមនុស្សទាំងអស់នេះទេ ទាំងនេះទេ?

**ឆ៖** អត់ទេ ខ្ញុំឮតែឈ្មោះ យ៉ា មួយ ក្នុងចំណោមទាំងអស់នេះ។

**ស៖** <តើ> យ៉ា ជាអ្នកណា<>?

**ឆ៖** បាទ យ៉ា ជាប្រធានភូមិភាគព្រៃសាន បាទ។

**ស៖** តើលោកធ្លាប់ឮមនុស្សម្នាក់ឈ្មោះ កុយ ធួន ហៅថា <>ធុច <ឬឃួនទេ>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី សំណួរលោកមេធាវី ខ្ញុំមិនស្តាប់ឮសំណួរលោកសោះ។ លោកលឿនពេក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកធ្លាប់ឮឈ្មោះ កុយ ធួន ហៅ ធុច ឬក៏ហៅ ឃួន ដែរឬទេ?

[១៥:៥៨:០៦]

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ខ្ញុំធ្លាប់ឮតាមដែលគេធ្វើមីទិ្ទង គេប្រកាសនៅតាមតំបន់។ គេប្រកាសថា គេចាប់តាធុច, តាយ៉ា ប៉ុន្តែខ្ញុំអត់ដែលស្គាល់គាត់ទេ បាទ។

**ស៖** តើលោកឮដូចម្តេចខ្លះ អំពីការចាប់ខ្លួន តាយ៉ា ហើយនិង តាធុច ហ្នឹង? តើគេចោទប្រកាន់ពួកគាត់ពីបទល្មើសអី កំហុសអី? ហេតុអីបានជាគេចាប់ពួកគាត់?

**ឆ៖** បាទ ដូចជាអត់ដឹងទេ។ មានអ្នកខ្លះ ជាចចាមអារ៉ាមនៅក្រៅៗ គេថាគាត់ទាមទារចាយប្រាក់ បាទ។ ហើយខ្លះទៀត គេថាគាត់តាមយួន។ មានតែប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំទេ នៅពេល<ណា>ដែលលោកឮថា កុយ ធួន, យ៉ា ត្រូវគេចាប់ខ្លួន? តើគេចាប់ខ្លួនអ្នកទាំងពីរហ្នឹងប៉ុន្មានខែមុនពេលគេឃាត់ខ្លួនលោក ឬក៏<ថារយៈពេលប៉ុន្មានមុន>ពេលដែលលោកត្រូវគេឃាត់ខ្លួន?

**ឆ៖** ខ្ញុំបានឮមុនប្រហែលជាពីរខែជាងហើយ បាទ។ ក្រោយគេឃាត់ខ្លួនខ្ញុំមកនៅតំបន់ នៅក-១៦។

**ស៖** តើអាចខែធ្នូ ឆ្នាំ១៩៧៦ ទេ នៅពេលដែលលោកឮរឿងនេះ?

**ឆ៖** បាទ ប្រហែលជាក្រោយខែធ្នូ បន្តិច បាទ។

**ស៖** លោកប្រធាន ខ្ញុំនឹងចូលទៅប្រធានបទផ្សេងទៀត <ខ្ញុំមើលទៅឃើញថាម៉ោងជិតបួនហើយ>។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៩ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ប៊ុន ឡឹងចូយ ហើយនិងធ្វើការសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្ស-

នាម 2-TCW-1012 តាមប្រព័ន្ធសោតទស្សន៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ប៊ុន ឡឹងចូយ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលទំនងជាចំណាយពេលតែមួយព្រឹកទៀតប៉ុណ្ណោះ។ ហើយអរគុណលោកស្រីមេធាវីប្រឹក្សាសាក្សី មេធាវី សុខ សុជាតា នៅពេលនេះលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឱ្យអញ្ជើញគាត់ត្រឡប់មកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកដែលចាប់នឹង ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែក ឱ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២នាទី)*